# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការយុទ្ធសាស្ត្រ

## ដើម្បីបណ្តុះបណ្តាលកម្លាំងសេវាសង្គម

ផ្តោតលើកិច្ចការពារកុមារ

## ២០២១-២០២៥

**រៀបចំដោយ**

**វិទ្យាស្ថានជាតិសង្គមកិច្ច**

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

**ឆ្នាំ២០២០**

# អារម្ភកថា

ការងារសង្គមកិច្ចនៅក្នុងកម្ពុជាចាប់ផ្តើមមានស្ថាប័នដឹកនាំដំបូងមានឈ្មោះថាក្រសួងព័ត៌មាន និងសង្គមកិច្ច នៅឆ្នាំ១៩៤៧ និងបានផ្លាស់ប្តូរឈ្មោះស្ថាប័ននិងឈ្មោះថ្នាក់ដឹកនាំជាបន្តបន្ទាប់ទៅតាមសម័យកាលនៃរបបដឹកនាំនីមួយៗ ដែលបច្ចុប្បន្ននេះមានឈ្មោះថាក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រោមការដឹកនាំរបស់ឯកឧត្តម **វង សូត** ជារដ្ឋមន្ត្រី ស្ថិតក្នុងរាជរដ្ឋាភិបាលអាណត្តិទី៦ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតី **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។ នៅប៉ុន្មានទសវត្សរ៍កន្លងមកនេះ វិស័យសង្គមកិច្ចមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់នៅកម្ពុជាទាក់ទងទៅនឹងអ្នកផ្តល់ជំនួយតាមបែបទំលាប់ និងការផ្តល់សេវាសង្គមកិច្ច។ ចាប់តាំងពីមានវត្តមានរបស់អ៊ុនតាក់ បុគ្គលិករបស់អង្គការមិនមែនរដ្ឋាភិបាលបានដើរតួនាទីជាអ្នកផ្តល់សេវាសង្គមកិច្ចដ៏សំខាន់នៅក្នុងវិស័យជាច្រើន ខណៈពេលដែលកម្ពុជាបានចាប់ផ្តើមធ្វើការកសាងឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធ និងសមត្ថភាពរបស់ខ្លួន។

ដើម្បីពង្រឹងសមត្ថភាពរបស់មន្ត្រីរាជការ និងអ្នកផ្តល់សេវាសង្គមកិច្ច "កម្លាំងសេវាសង្គម" ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានបង្កើតវិទ្យាស្ថានជាតិសង្គមកិច្ចកាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ ដើម្បីអប់រំបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្ររង បរិញ្ញាបត្រលើមុខជំនាញសង្គមកិច្ច វិស្វកម្មឧបករណ៍សិប្បនិម្មិតនិងរណប និងវិជ្ជាជីវៈសង្គមកិច្ចរួមទាំងធ្វើការស្រាវជ្រាវលើផ្នែកសង្គមកិច្ចឆ្លើយតបទៅនឹងតម្រូវការរបស់ស្ថាប័ន។ ទន្ទឹមនឹងនេះ ក្រសួងក៏បានសហការជាមួយដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធធ្វើការបណ្តុះបណ្តាលកម្រិតជំនាញវិជ្ជាជីវៈសង្គមកិច្ចដល់មន្ត្រីរាជការនិងអ្នកពាក់ព័ន្ធឱ្យមានសមត្ថភាពក្នុងការបំពេញការងារសង្គមកិច្ច។ ខណៈពេលដែលការបណ្តុះបណ្តាលទាំងនេះមានប្រយោជន៍ក្នុងការកសាងសមត្ថភាពកម្លាំងសេវាសង្គមដើម្បីបំពេញមុខងារជាក់លាក់ ហើយចាំបាច់ត្រូវមានរចនាសម្ព័ន្ធល្អប្រសើរ ជាផ្នែកមួយនៃផែនការកសាងសមត្ថភាពរយៈពេលវែងរបស់មន្ត្រីរាជការដែលមានទំនួលខុសត្រូវលើសេវាសង្គមនិងការងារសង្គមកិច្ច។ ជាពិសេសតម្រូវការទាំងនេះដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរថ្មីៗនៃកំណែទម្រង់រដ្ឋបាលដូចជាតាមរយៈអនុក្រឹត្យលេខ ១៨២, ១៨៣, ១៨៤ និងអនុក្រឹត្យ ៣៤ និងការអនុម័តសេចក្តីណែនាំស្តីពីសមត្ថភាពមូលដ្ឋានសម្រាប់កម្លាំងសេវាសង្គមនៅកម្ពុជា និងក្របខ័ណ្ឌគុណវុឌ្ឍិជាតិ។ ដូច្នេះក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយអង្គការយូនីសេហ្វ និងស្ថាប័នពាក់ព័ន្ធបានរៀបចំផែនការយុទ្ធសាស្ត្របណ្តុះបណ្តាលកម្លាំងសេវាសង្គមនៅកម្ពុជា។

ផែនការយុទ្ធសាស្ត្រដើម្បីបណ្តុះបណ្តាលកម្លាំងសេវាសង្គម ២០២១-២០២៥ គឺជាផែនការដំបូងដែលមានគោលដៅរយៈពេលប្រាំឆ្នាំដោយផ្តោតលើការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈជំនាញសង្គមកិច្ច ក្នុងគោលបំណងពង្រឹងសមត្ថភាពកម្លាំងសេវាសង្គមឱ្យមានកម្រិតចំណេះដឹង និងកម្រិតជំនាញពិតប្រាកដ ប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈដើម្បីផ្តល់សេវាសង្គមកិច្ចជូនអតិថិជនដែលជាជនរងគ្រោះ និងងាយរងគ្រោះជានាបាននូវប្រសិទ្ធិភាពខ្ពស់។ ផែនការយុទ្ធសាស្ត្រនេះ គ្របដណ្តប់លើគោលដៅយុទ្ធសាស្ត្រ៣គឺ៖ **១.អភិវឌ្ឍកម្មវិធីសិក្សានិងកញ្ចប់មេរៀនបណ្តុះបណ្តាលកម្លាំងសេវាសង្គម ២.បណ្តុះបណ្តាលកម្លាំងសេវាសង្គម និងបង្កើនប្រសិទ្ធភាព ៣.ពង្រឹងសមត្ថភាពគ្រឹះស្ថានអប់រំបណ្តុះបណ្តាលកម្លាំងសេវាសង្គម** ដើម្បីធ្វើឱ្យសម្រេចបាននូវទស្សនវិស័យ បេសកកម្ម និងលទ្ធផលរំពឹងទុកដែលបានលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្រនេះ។

ខ្ញុំសូមកោតសរសើរដល់វិទ្យាស្ថានជាតិសង្គមកិច្ច អង្គការ UNICEF អង្គការមិនមែនរដ្ឋាភិបាល គ្រឹះស្ថានអប់រំ និងអ្នកពាក់ព័ន្ធនានា ដែលបានខិតខំចូលរួមកសាងផែនការយុទ្ធសាស្ត្រដើម្បីអប់រំបណ្តុះបណ្តាលកម្លាំងសេវាសង្គម និងបន្តការគាំទ្របន្ថែមទៀតដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រនេះឱ្យទទួលបានជោគជ័យ និងសង្ឃឹមយ៉ាងមុតមាំថាអ្នកពាក់ព័ន្ធទាំងអស់រួមសហការគ្នាអនុវត្តផែនយុទ្ធសាស្ត្រនេះប្រកបដោយស្មារតីទទួលខុសត្រូវ។

ថ្ងៃ អង្គារ ១៣រោច ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី៩ ខែ កុម្ភៈ ឆ្នាំ២០២១

រដ្ឋមន្ត្រី

វង សូត

# មាតិកា


**អារម្ភកថា** ..... i

**មាតិកា** ..... iii

**អក្សរកាត់** ..... vi

**និយមន័យ** ..... vii

**១. សេចក្តីផ្តើម** ..... ១

**១.១. សាវតា និងបរិបទ** ..... ១

**១.២.ការអប់រំបណ្តុះបណ្តាលកម្លាំងសេវាសង្គមកម្រិតឧត្តម** ..... ២

១.២.១.សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP) ..... ២

១.២.២.វិទ្យាស្ថានជាតិសង្គមកិច្ច (NISA) ..... ២

១.២.៣.វិទ្យាស្ថានសន្ទប៉ូល (SPI) ..... ៣

**១.៣.ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ** ..... ៣

១.៣.១.ការបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញសង្គមកិច្ច ..... ៣

១.៣.២.ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិលនៅថ្នាក់ក្រោមជាតិ ..... ៥

**១.៤.ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា** ..... ៥

១.៤.១.កម្រិតគុណវុឌ្ឍិ ..... ៦

១.៤.២.ក្រេឌីត ..... ៦

១.៤.៣.លទ្ធផលសិក្សា ..... ៨

**១.៥.ការវិភាគប្រភេទកម្លាំងសេវាសង្គម និងមុខងារ** ..... ១០

១.៥.១.ការត្រួតពិនិត្យឡើងវិញលើការអនុវត្តការងារសង្គមកិច្ចនៅកម្ពុជា ..... ១១

១.៥.២.គោលការណ៍ណែនាំស្តីពីសមត្ថភាពមូលដ្ឋានសម្រាប់កម្លាំងសេវាសង្គម ..... ១១

១.៥.៣.គោលការណ៍ណែនាំដើម្បីពង្រឹងកម្លាំងសេវាសង្គម ..... ១២

១.៥.៤.សេចក្តីថ្លែងការណ៍អាស៊ានស្តីពីការលើកកម្ពស់ការងារសង្គមកិច្ច ..... ១៤

**១.៦.ទំនាក់ទំនងរវាងផែនការយុទ្ធសាស្ត្រ ជាមួយនឹងឯកសារពាក់ព័ន្ធ** ..... ១៥

**១.៧.ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រ** ..... ១៥

**១.៨.ទម្រង់ផែនការយុទ្ធសាស្ត្រ** ..... ១៦

**២. ផែនទីស្ថាប័នផ្តល់សេវាសង្គម និងយន្តការកិច្ចការពារកុមារ** ..... ១៦

**២.១.ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ..... ១៧

**២.២.មន្ទីរ សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត** ........ ១៧
**២.៣.ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម ក្រុង ស្រុក ខណ្ឌ** ........ ១៧
**២.៤.យន្តការសម្របសម្រួលកិច្ចការពារកុមារ** ........ ២០
២.៤.១.ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ........ ២០
២.៤.២.អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ........ ២១
២.៤.៣.ក្រុមការងារដើម្បីកុមារនៅតាមក្រសួង ស្ថាប័ន ........ ២១
២.៤.៤.ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមាររាជធានី ខេត្ត ........ ២១
២.៤.៥.គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររាជធានី ខេត្ត ........ ២៣
២.៤.៦.គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្រុង ស្រុក ខណ្ឌ ........ ២៤
២.៤.៧.គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់ ........ ២៥
២.៤.៩.គណៈកម្មាធិការពាក់ព័ន្ធដឹកនាំ និងសម្របសម្រួលដោយក្រសួងស្ថាប័ន ........ ៣១
**២.៥.អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស** ........ ៣១
**៣. វឌ្ឍនភាព និងបញ្ហាប្រឈម** ........ ៣៣
**៣.១.វឌ្ឍនភាព** ........ ៣៣
**៣.២.បញ្ហាប្រឈម** ........ ៣៤
៣.២.១.ការរៀបចំកម្មវិធីនិងកញ្ចប់មេរៀនបណ្តុះបណ្តាលកម្លាំងសេវាសង្គម ........ ៣៤
៣.២.២.ការបណ្តុះបណ្តាលកម្លាំងសេវាសង្គមកិច្ចការពារកុមារ ........ ៣៤
៣.២.៣.ការពង្រឹងសមត្ថភាពគ្រូបង្គោល គ្រូជំនាញ និងគ្រឹះស្ថានអប់រំបណ្តុះបណ្តាល ........ ៣៤
**៤. ទស្សនៈវិស័យ បេសកកម្ម និងគោលដៅយុទ្ធសាស្ត្រ** ........ ៣៥
**៤.១. ទស្សនៈវិស័យ** ........ ៣៥
**៤.២. បេសកកម្ម** ........ ៣៥
**៤.៣. គោលបំណងគោលនយោបាយ** ........ ៣៥
**៤.៤. គោលបំណងរួមនៃយុទ្ធសាស្ត្រ** ........ ៣៥
**៤.៥. គោលដៅយុទ្ធសាស្ត្រ** ........ ៣៨
គោលដៅយុទ្ធសាស្ត្រទី១៖អភិវឌ្ឍកម្មវិធី និងកញ្ចប់មេរៀនសម្រាប់បណ្តុះបណ្តាលកម្លាំងសេវាសង្គម ........ ៣៨
គោលដៅយុទ្ធសាស្ត្រទី២៖បណ្តុះបណ្តាលកម្លាំងសេវាសង្គម និងបង្កើនប្រសិទ្ធភាព ........ ៣៩
គោលដៅយុទ្ធសាស្ត្រទី៣៖ពង្រឹងសមត្ថភាពគ្រឹះស្ថានអប់រំ បណ្តុះបណ្តាលកម្លាំងសេវាសង្គម ........ ៤០
**៥. ការរៀបចំស្ថាប័នសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រ** ........ ៤១

៦. យុទ្ធសាស្ត្រគៀរគរហិរញ្ញប្បទាន និងតម្រូវការថវិកា ........ ៤២
៦.១. យុទ្ធសាស្ត្រគៀរគរហិរញ្ញប្បទាន ........ ៤២
៦.២. តម្រូវការថវិកាសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រ ........ ៤២
៧. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ........ ៤៣
៧.១. ត្រួតពិនិត្យតាមដាន ........ ៤៣
៧.២. ការវាយតម្លៃ ........ ៤៣
៨. សេចក្តីសន្និដ្ឋាន ........ ៤៣
ឧបសម្ព័ន្ធ ........ ៤៣

# អក្សរកាត់

| | |
|---|---|
| ក.ក.ជ | ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ |
| ក.ជ.ក | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |
| គ.ជ.អ.ប | គណៈកម្មាធិការសម្រាប់ការអភិវឌ្ឍបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| គ.ក.ស.ក | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ |
| គ.ក.ន.ក | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ |
| គ.ជ.ព | គណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ |
| គ.ជ.ប.ជ | គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស |
| គ.ជ.គ.ក | គណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍន៍កុមារតូច |
| គ.ជ.ប.ទ | គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើឃោឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម |
| ស.អ.យ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| GSWA | សម្ព័ន្ធភាពកម្លាំងសេវាសង្គមសកល |
| IFSW | សហព័ន្ធការងារសង្គមកិច្ចអន្តរជាតិ |
| IASSW | សមាគមសាលាសង្គមកិច្ចអន្តរជាតិ |
| RUPP | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| NISA | វិទ្យាស្ថានជាតិសង្គមកិច្ច |
| SPI | វិទ្យាស្ថានសន្តប៉ូល |
| SSC | អង្គការសេវាសង្គមកម្ពុជា |
| TPO | អង្គការចិត្តសង្គមអន្តរវប្បធម៌ |
| TWG | ក្រុមការងារបច្ចេកទេស |
| BSST | ការបណ្តុះបណ្តាលសេវាសង្គមកិច្ចមូលដ្ឋាន |
| PSST | ការបណ្តុះបណ្តាលសេវាសង្គមកិច្ចជំនាញ |
| MSST | ការបណ្តុះបណ្តាលគ្រប់គ្រងសេវាសង្គមកិច្ច |
| UNICEF | មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ |
| FI | អង្គការហ្វេនអន្តរជាតិ |
| NASLA | សាលាជាតិរដ្ឋបាលមូលដ្ឋាន |
| MoSVY | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| MoI | ក្រសួងមហាផ្ទៃ |
| NASLA | សាលាជាតិរដ្ឋបាលមូលដ្ឋាន |
| RPL | កាត់បន្ថយតាមរយៈការវាយតម្លៃជាផ្លូវការសម្រាប់ការទទួលស្គាល់ការរៀនមុន |
| RCC | ការទទួលស្គាល់សមត្ថភាពបច្ចុប្បន្ន |

## និយមន័យ

និយមន័យនៃការងារសង្គមកិច្ច កម្លាំងសេវាសង្គម និងប្រភេទកម្លាំងសេវាសង្គមប្រើសម្រាប់ផែនការយុទ្ធសាស្ត្រដើម្បីអប់រំបណ្តុះបណ្តាលកម្លាំងសេវាសង្គមផ្តោតលើកិច្ចការពារកុមារ មានដូចខាងក្រោម៖

**ការងារសង្គមកិច្ច** គឺជាវិជ្ជាជីវៈមួយដែលលើកកម្ពស់ឱ្យមានការផ្លាស់ប្តូរនៅក្នុងសង្គម ការដោះស្រាយបញ្ហានៅក្នុងទំនាក់ទំនងមនុស្ស និងការផ្តល់សិទ្ធិអំណាចដល់ប្រជាពលរដ្ឋ សំដៅលើកកម្ពស់សុខុមាលភាព។ ដោយប្រើប្រាស់ទ្រឹស្តីនៃឥរិយាបថរបស់មនុស្ស និងប្រព័ន្ធសង្គម ការងារសង្គមកិច្ចចូលធ្វើអន្តរាគមន៍នៅពេលណាមួយដែលមនុស្សប្រាស្រ័យទាក់ទងជាមួយបរិយាកាសជុំវិញខ្លួនរបស់ពួកគេ។ គោលការណ៍សិទ្ធិមនុស្ស និងយុត្តិធម៌ សង្គមគឺជាមូលដ្ឋានគ្រឹះនៃការងារសង្គមកិច្ច[1]។ សម្រាប់ផែនការនេះផ្តោតលើការងារសង្គមកិច្ចពាក់ព័ន្ធកិច្ចការពារកុមារ។

> ការងារសង្គមកិច្ចដើរតួនាទីដ៏សំខាន់ក្នុងការលើកកម្ពស់សុខុមាលភាពកុមារ និងកិច្ចការពារកុមារ ហើយការងារនេះ មានការពាក់ព័ន្ធទៅនឹងសមាភាពផ្សេងៗទៀត នៃប្រព័ន្ធសុខុមាលភាពសង្គម និងប្រព័ន្ធយុត្តិធម៌ដែលមានភាពទូលំទូលាយព្រមទាំងវិស័យពាក់ព័ន្ធដទៃទៀតដូចជាវិស័យអប់រំ និងសុខាភិបាលសម្រាប់មនុស្សពេលវ័យ កុមារ និងគ្រួសារ។ បុគ្គលិកសង្គមកិច្ចទទួលខុសត្រូវលើការថែទាំ និងគាំទ្រដល់កុមារ និងគ្រួសារងាយរងគ្រោះតាមរយៈការបន្តកំណត់រកការបញ្ជូនទៅកាន់សេវាឯកទេស បង្ការទប់ស្កាត់ និងការថែរក្សានៅក្នុងគ្រួសារ ការផ្តល់កិច្ចគាំទ្រចិត្តសង្គម ការគាំទ្រដល់ដំណើរការសមាហរណកម្ម និងការធ្វើជាតំណាងឱ្យរដ្ឋនៅក្នុងរយៈពេលនៃដំណើការនីតិវិធីតុលាការ។

**កម្លាំងសេវាសង្គម** សំដៅដល់អ្នកទាំងឡាយណាដែលធ្វើការដើម្បីធានាបាននូវការអភិវឌ្ឍសុខុមាលភាពរបស់ជនរងគ្រោះ និងជនងាយរងគ្រោះ ទាំងមន្ត្រីរដ្ឋាភិបាល ទាំងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ទោះជាអ្នកទាំងនោះមានអាជីព ឬគ្មានអាជីព ហើយធ្វើការដោយយកកម្រៃ ឬមិនយកកម្រៃក៏ដោយ។ កម្លាំងសេវាសង្គមផ្តោតការយកចិត្តទុកដាក់លើកម្មវិធីបង្ការ ឆ្លើយតប និងកម្មវិធីលើកកម្ពស់កិច្ចគាំទ្រដល់ជនរងគ្រោះ និងជនងាយរងគ្រោះនៅក្នុងសហគមន៍តាមរយៈការលុបបំបាត់ភាពក្រីក្រ ការកាត់បន្ថយការរើសអើង ការសម្របសម្រួលឱ្យទទួលបានសេវា ការលើកកម្ពស់យុត្តិធម៌សង្គម ព្រមទាំងការបង្ការ និងឆ្លើយតបចំពោះអំពើហិង្សា ការរំលោភបំពាន ការកេងប្រវ័ញ្ច ការមិនអើពើ និងការបំបែកពីគ្រួសារ។[2] ផែនការយុទ្ធសាស្ត្រដើម្បីបណ្តុះបណ្តាលកម្លាំងសេវាសង្គមផ្តោតលើកិច្ចការពារកុមារបានជ្រើសរើសប្រភេទកម្លាំងសេវាសង្គមពីចំណុច ១.៥.ដើម្បីស្នើឡើងសម្រាប់ប្រើជាផ្លូវការមានដូចខាងក្រោម៖

- **អ្នកអាជីពសង្គមកិច្ច(បុគ្គលិកសង្គមអាជីព)**សំដៅដល់អ្នកដែលបានបញ្ចប់ការសិក្សា ដោយជោគជ័យលើសង្គមកិច្ចវិទ្យាពីគ្រឹះស្ថានអប់រំណាមួយ ហើយប្រើប្រាស់ចំណេះដឹង និងជំនាញរបស់ខ្លួន ដើម្បីផ្តល់សេវាសង្គមជូនអតិថិជន(អាចជាបុគ្គល គ្រួសារ ក្រុម សហគមន៍ ឬមួយសង្គមជារួម)។ បុគ្គលិកសង្គមអាជីពជួយប្រជាពលរដ្ឋបង្កើនសមត្ថភាពរបស់គាត់សម្រាប់ដោះស្រាយ និងទប់ទល់ជាមួយបញ្ហាជួយឱ្យប្រជាពលរដ្ឋទទួលបានប្រភពធនធានចាំបាច់ សម្របសម្រួលអន្តរកម្មរវាងបុគ្គលនិងបុគ្គល និងរវាងប្រជាពលរដ្ឋជាមួយបរិស្ថាន ធ្វើឱ្យស្ថាប័នពាក់ព័ន្ធឆ្លើយតបចំពោះប្រជាពលរដ្ឋ ហើយរួមចំណែកក្នុងការបង្កើត អនុវត្ត និងវាយតម្លៃគោលនយោបាយសង្គម។ បុគ្គលិកសង្គមអាជីពអាចធ្វើការជាមួយអតិថិជនផ្ទាល់ ដើម្បីដោះស្រាយបញ្ហាបុគ្គល បញ្ហាគ្រួសារ និងបញ្ហាសហគមន៍។ ម្យ៉ាងទៀតអ្នកសង្គមកិច្ចវិទ្យា

[1] យោងតាមការកំណត់និយមន័យដោយសមាគមសាលាសង្គមកិច្ចអន្តរជាតិ IASSW និងសហព័ន្ធបុគ្គលិកសង្គមកិច្ចអន្តរជាតិ IFSW

[2] គោលការណ៍ណែនាំស្តីពីសមត្ថភាពមូលដ្ឋានសម្រាប់កម្លាំងសេវាសង្គមនៅកម្ពុជាចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ និងសម្ព័ន្ធភាពកម្លាំងសេវាសង្គមសកល Global Social Service Workforce Alliance **(GSWA)**.

អាចធ្វើការកម្រិតជាប្រព័ន្ធដោយផ្តោតទៅលើការអភិវឌ្ឍក្របខ័ណ្ឌច្បាប់និងគោលនយោបាយ ឬមួយជាអ្នករដ្ឋបាល ឬជាអ្នកកសាងផែនការក្នុងប្រព័ន្ធសេវាសង្គមទាំងមូល។(គោលការណ៍ណែនាំស្តីពីសមត្ថភាពមូលដ្ឋានសម្រាប់កម្លាំងសេវាសង្គមនៅកម្ពុជាចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩)

- **អ្នកអាជីពសង្គមកិច្ចរង(បុគ្គលិកសង្គមប៉ារ៉ាអាជីព)** នឹងធ្វើការនៅក្បែរឬគាំទ្រការងារជំនាញក្នុងវិស័យតែមួយ។ ប៉ារ៉ាអាជីពត្រូវបានបណ្តុះបណ្តាលឱ្យអនុវត្តមុខងារជាក់លាក់ ប៉ុន្តែមិនតម្រូវមានការបញ្ជាក់ឬមានការអនុញ្ញាតត្រឹមត្រូវដើម្បីអនុវត្តជាអ្នកមានវិជ្ជាជីវៈពេញលេញ ដែលនៅក្នុងមុខវិជ្ជាខ្លះត្រូវការមហាវិទ្យាល័យ ឬមហាវិទ្យាល័យសាកលវិទ្យាល័យឬការបណ្តុះបណ្តាលជំនាញ។ (UNICEF និងសម្ព័ន្ធភាពកម្លាំងសេវាសង្គមសកល ឆ្នាំ២០១៩ គោលការណ៍ណែនាំដើម្បីពង្រឹងកម្លាំងសេវាសង្គម)
- **អ្នកសង្គមកិច្ចមិនអាជីព(បុគ្គលិកសង្គមប៉ារ៉ាវិជ្ជាជីវៈ)** គឺត្រួតពិនិត្យអ្នកអាជីពសង្គមកិច្ចរងបុគ្គលិក ឬអ្នកស្ម័គ្រចិត្តដែលធ្វើការនៅតាមសហគមន៍បម្រើសេចក្តីត្រូវការរបស់ជនរងគ្រោះ និងងាយរងគ្រោះរួមទាំងកុមារនិងគ្រួសារ ជាពិសេសនៅពេលដែលប្រព័ន្ធសុខុមាលភាពសង្គមកំពុងអភិវឌ្ឍ។ (UNICEFនិងសម្ព័ន្ធភាពកម្លាំងសេវាសង្គមសកល ឆ្នាំ២០១៩ គោលការណ៍ណែនាំដើម្បីពង្រឹងកម្លាំងសេវាសង្គម)
- **អ្នកសង្គមកិច្ចសម្ព័ន្ធ(បុគ្គលិកសម្ព័ន្ធសង្គមកិច្ច)** គឺជាអ្នកដែលផ្តល់សេវាសង្គមប៉ុន្តែត្រូវបានផ្សាភ្ជាប់ជាមួយនឹងវិស័យផ្សេងទៀតដូចជាការអប់រំ សុខភាព ឬយុត្តិធម៌។ ឧទាហរណ៍រួមមានគិលានុបដ្ឋាក មេធាវី វេជ្ជបណ្ឌិត និងគ្រូបង្រៀននិងអ្នកផ្សេងទៀត។ អ្នកសង្គមកិច្ចសម្ព័ន្ធអនុវត្តមុខងារជាច្រើនដែលធ្វើឱ្យប្រសើរឡើង ការគាំទ្រ ឬ សម្របសម្រួលមុខងារដែលអនុវត្តដោយកម្លាំងសេវាសង្គមផ្សេងទៀត។(UNICEFនិងសម្ព័ន្ធភាពកម្លាំងសេវាសង្គមសកល ឆ្នាំ២០១៩ គោលការណ៍ណែនាំដើម្បីពង្រឹងកម្លាំងសេវាសង្គម)

## កម្រិតគុណវុឌ្ឍិ

កម្រិតគុណវុឌ្ឍិសម្រាប់ការអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈមានចំនួន៨កម្រិត។ ចំពោះគុណវុឌ្ឍិបួនកម្រិតដំបូងដែលអាចទទួលបានជាវិញ្ញាបនបត្រវិជ្ជាជីវៈ ឬសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ(កម្រិត១,២ និង៣) ត្រូវបានផ្តល់តម្លៃសមមូលទៅនឹងការអប់រំមធ្យមសិក្សាតាមស្តង់ដារ។ កម្រិតបួនដែលនៅសល់ត្រូវបានចាត់ទុកថាជាការអប់រំក្រោយមធ្យមសិក្សាហើយនាំឱ្យមានបរិញ្ញាបត្ររង បរិញ្ញាបត្រ អនុបណ្ឌិត ឬបណ្ឌិត។ ទាំងនេះ គឺជាផ្នែកមួយនៃស្តង់ដារផ្លូវការនៃមហាវិទ្យាល័យ/សាកលវិទ្យាល័យហើយមិនមែនជាគុណវុឌ្ឍិការអប់រំវិជ្ជាជីវៈ/បច្ចេកទេស។

នៅក្នុងការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ គុណវុឌ្ឍិកំណត់ឡើងដើម្បីបញ្ជាក់អំពីការទទួលបាននូវសមត្ថភាពច្បាស់លាស់តាមតម្រូវការការងារ ពិសេសគុណវុឌ្ឍិវិញ្ញាបនបត្រវិជ្ជាជីវៈ សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១ ២ ៣ និងសញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស(បរិញ្ញាបត្ររង បរិញ្ញាបត្រ អនុបណ្ឌិត ឬបណ្ឌិត)គឺជាគុណវុឌ្ឍិផ្អែកលើសមត្ថភាព។ កំរិតវិញ្ញាបនបត្រ ឬសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ នីមួយៗត្រូវមានកម្រិតអប្បបរមាចំនួន ៣០ ក្រេឌីត(១ក្រេឌីត=១៥ម៉ោង, ១៥ម៉ោងសម្រាប់បង្រៀននិងណែនាំ, ៣០ម៉ោងសម្រាប់១ក្រេឌីតគឺត្រូវបានយកជារង្វាស់នៃចំនួនសកម្មភាពពិសោធន៍/សិក្ខាសាលាបង្រៀន ហើយ ៤៥ម៉ោង សម្រាប់ ១ក្រេឌីត គឺជារង្វាស់នៃចំនួនអនុវត្តផ្ទាល់ ឬកម្មសិក្សា)។ កម្រិតនីមួយៗត្រូវបានបង្កើតឡើងនៅលើកម្រិតមុន។

# ១. សេចក្តីផ្តើម

## ១.១. សាវតា និងបរិបទ

ការងារសង្គមកិច្ចបានចាប់ផ្តើមកើតឡើងនៅចុងឆ្នាំ១៨០០ នៅសហរដ្ឋអាមេរិក និងអឺរ៉ុប នៅពេលដែលសង្គមគាំទ្រឱ្យមានការផ្លាស់ប្តូរបានកើតឡើងជាមួយនឹងបដិវត្តឧស្សាហកម្ម។ ជាច្រើនសតវត្សរ៍មកនេះបុគ្គលិកសង្គមកិច្ចនៅក្នុងប្រទេសទាំងនេះបានចាប់ដំណើរការមួយដ៏វែងឆ្ងាយសំដៅបង្កើតបទដ្ឋានសម្រាប់ការអប់រំ និងរៀបចំធ្វើឱ្យការងារសង្គមកិច្ចមានវិជ្ជាជីវៈ គឺសំដៅអភិវឌ្ឍចំណេះដឹងឯកទេសដែលប្រើប្រាស់ព័ត៌មានទ្រឹស្តី និងការអនុវត្តផ្ទាល់ដើម្បីដោះស្រាយបញ្ហាមនុស្ស និងបញ្ហាសង្គម។[3] ដោយឡែកការងារសង្គមកិច្ចនៅក្នុងកម្ពុជា ចាប់ផ្តើមមានស្ថាប័នដឹកនាំដំបូងមានឈ្មោះ "ក្រសួងព័ត៌មាន និងសង្គមកិច្ច នៅឆ្នាំ១៩៤៧ និងបានផ្លាស់ប្តូរឈ្មោះស្ថាប័ន និងឈ្មោះថ្នាក់ដឹកនាំជាបន្តបន្ទាប់ទៅតាមសម័យកាលនៃរបបដឹកនាំនីមួយៗ[4] ដែលបច្ចុប្បន្ននេះមានឈ្មោះក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា[5] មានឯកឧត្តម **វង សូត** ជារដ្ឋមន្ត្រីនៅក្នុងរាជរដ្ឋាភិបាលអាណត្តទី៦ នៃរដ្ឋសភាដែលមានសម្តេចអគ្គមហាសេនាបតី **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

នៅប៉ុន្មានទសវត្សរ៍កន្លងមកនេះវិស័យសង្គមកិច្ចមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់នៅកម្ពុជាទាក់ទងទៅនឹងអ្នកផ្តល់ជំនួយតាមបែបទំលាប់ និងការផ្តល់សេវាសង្គមកិច្ចនាពេលបច្ចុប្បន្ន។[6] នៅពេលអតីតកាល គ្រូខ្មែរ និងស្ថាប័នសាសនានានា ព្រមទាំងស្ថាប័នដទៃទៀត ដែលមានមូលដ្ឋានផ្អែកលើទំនាក់ទំនងបានដើរតួនាទីមួយដ៏សំខាន់ក្នុងការដោះស្រាយបញ្ហាសង្គមកិច្ច។ ចាប់តាំងពីមានវត្តមានរបស់អ៊ុនតាក់[7] បុគ្គលិករបស់អង្គការមិនមែនរដ្ឋាភិបាលបានដើរតួនាទីជាអ្នកផ្តល់សេវាសង្គមកិច្ចដ៏សំខាន់នៅក្នុងវិស័យជាច្រើន ខណៈពេលដែលកម្ពុជាបានចាប់ផ្តើមធ្វើការកសាងឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធ និងសមត្ថភាពរបស់ខ្លួន។ បច្ចុប្បន្នមានអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេសចំនួន១៣៨ ដែលបានចុះកិច្ចព្រមព្រៀងនៅមានសុពលភាពជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលមានថវិកាសរុបប្រមាណ ១៦១.៥៧៣.៤១៥.៦៣ ដុល្លារអាមេរិក[8] កំពុងតែផ្តល់សេវាសង្គមកិច្ចដោយផ្ទាល់យ៉ាងទូលំទូលាយ និងការអនុវត្តមិនផ្ទាល់ដូចជាការតស៊ូមតិ អភិវឌ្ឍន៍គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងអភិវឌ្ឍន៍កម្លាំងសេវាសង្គម។

ការងារសង្គមកិច្ច គឺជាការងារមួយថ្មីស្រឡាងនៅក្នុងប្រទេសកម្ពុជា និងមិនទាន់ត្រូវបានកំណត់វិសាលភាពការងារនេះនៅឡើយ។ ទោះបីជាពាក្យថា "ការងារសង្គមកិច្ច" អាចបកប្រែក្នុងន័យត្រង់ជាភាសាខ្មែរក៏ដោយ ប៉ុន្តែមិនមានអត្ថន័យដូចគ្នាទៅនឹងនិយមន័យអន្តរជាតិឡើយដូចជានិយមន័យការងារសង្គមកិច្ច[9]ដែលកំណត់ដោយសហព័ន្ធការងារសង្គមកិច្ចអន្តរជាតិ(IFSW)[10]ឬសមាគមសាលាសង្គមកិច្ចអន្តរជាតិ(IASSW)[11]។យោងតាម(IFSW) និង(IASSW) វិជ្ជាជីវៈការងារសង្គមកិច្ចជំរុញឱ្យមានការផ្លាស់ប្តូរនៅក្នុងសង្គម ការដោះស្រាយបញ្ហានៅក្នុងទំនាក់

---

[3] http://ifsw.org/what-we-do/governance/constitution-and-by-laws/

[4] ឯកសារស្រាវជ្រាវដោយលោក ពុយ គា រាជរដ្ឋាភិបាលកម្ពុជាពីឆ្នាំ១៩៤៥ ដល់ឆ្នាំ២០១០ ចេញផ្សាយថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០។

[5] ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួង ស.អ.យ

[6] Harachi, et. Al 2011

[7] United Nations Transitional Authority of Cambodia (UNTAC)

[8] របាយការណ៍បូកសរុបប្រចាំឆ្នាំ២០១៩ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

[9] **ការងារសង្គមកិច្ច** គឺជាវិជ្ជាជីវៈមួយដែលលើកកម្ពស់ឱ្យមានការផ្លាស់ប្តូរនៅក្នុងសង្គម ការដោះស្រាយបញ្ហានៅក្នុងទំនាក់ទំនងមនុស្ស និងការផ្តល់សិទ្ធិអំណាចដល់ប្រជាពលរដ្ឋ សំដៅលើកកម្ពស់សុខុមាលភាព។ ដោយប្រើប្រាស់ទ្រឹស្តីនៃឥរិយាបថរបស់មនុស្ស និងប្រព័ន្ធសង្គម ការងារសង្គមកិច្ចចូលធ្វើអន្តរាគមន៍នៅពេលណា មួយ ដែលមនុស្សប្រាស្រ័យទាក់ទងជាមួយបរិយាកាសជុំវិញខ្លួនរបស់ពួកគេ។ គោលការណ៍សិទ្ធិមនុស្ស និងយុត្តិធម៌ សង្គម គឺជាមូលដ្ឋានគ្រឹះនៃការងារសង្គមកិច្ច (យោងតាមការកំណត់និយមន័យដោយ IASSW និង IFSW)។

[10] International Association of Schools of Social Work (IASSW)

[11] International Federation of Social Workers (IFSW)

ទំនងមនុស្ស និងការផ្តល់សិទ្ធិអំណាច ព្រមទាំងសេរីភាពដល់ប្រជាពលរដ្ឋដើម្បីលើកកម្ពស់សុខុមាលភាព។ ការប្រើទ្រឹស្តីឥរិយាបទរបស់មនុស្ស និងប្រព័ន្ធសង្គម ការងារសង្គមកិច្ចធ្វើអន្តរាគមន៍នៅត្រង់ចំណុចដែលប្រជាពលរដ្ឋប្រាស្រ័យទាក់ទងជាមួយបរិយាកាសជុំវិញខ្លួនរបស់ពួកគេ។ គោលការណ៍សិទ្ធិមនុស្ស និងយុត្តធម៌សង្គមគឺជាគោលការណ៍គ្រឹះនៃការងារសង្គមកិច្ច[12] ជាវិជ្ជាជីវៈមួយដែលជាដៃគូដ៏សំខាន់សម្រាប់ឱ្យរាជរដ្ឋាភិបាល និងសង្គមស៊ីវិលបង្កើតនិងជានានិរន្តភាពចំពោះសហគមន៍ឱ្យមានយុត្តិធម៌នៅក្នុងសង្គមដែលលើកកម្ពស់គុណភាពជីវិតរបស់ជនគ្រប់រូប។ ដូច្នេះការងារសង្គមកិច្ចដែលមានលក្ខណៈវិជ្ជាជីវៈ មិនមែនគ្រាន់តែជាសកម្មភាពសប្បុរសធម៌ ឬចេតនាល្អប៉ុណ្ណោះទេ ប៉ុន្តែជាសកម្មភាព និងអន្តរាគមន៍នានាដែលមានប្រភពចេញពីមូលដ្ឋាននៃចំណេះដឹង និង ការស្រាវជ្រាវ សម្រាប់ធ្វើការបណ្តុះបណ្តាល និងការកសាងសមត្ថភាពកម្លាំងសេវាសង្គមដើម្បីអនុវត្តការងារសង្គមកិច្ចប្រកបដោយវិជ្ជាជីវៈ។

## ១.២. ការអប់រំបណ្តុះបណ្តាលកម្លាំងសេវាសង្គមកម្រិតឧត្តម

### ១.២.១.សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP)

សាកលវិទ្យាល័យភូមិន្ទភ្នំពេញត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៦០ ដែលមានឈ្មោះដើមគឺសាកលវិទ្យាល័យភូមិន្ទខ្មែរ។ ក្នុងកំឡុងឆ្នាំ១៩៧៥-១៩៧៩ នៃរបបប៉ុលពតសាកលវិទ្យាល័យបានឆ្លងកាត់ការបំផ្លិចបំផ្លាញហើយត្រូវបានបិទទាំងស្រុង។ នៅឆ្នាំ១៩៨០ សាកលវិទ្យាល័យនេះត្រូវបានបង្កើតឡើងវិញជាសាកលវិទ្យាល័យធម្មតាដែលមានឈ្មោះ(Ecole Normale Superieure) និងបានរួមបញ្ចូលគ្នាជាមួយវិទ្យាស្ថានភាសាបរទេស (បានបង្កើតឡើងវិញនៅឆ្នាំ ១៩៨១) នៅក្នុងឆ្នាំ១៩៨៨ បានបង្កើតសាកលវិទ្យាល័យភ្នំពេញ ហើយត្រូវបានដាក់ឈ្មោះសាជាថ្មីថាសាកលវិទ្យាល័យភូមិន្ទភ្នំពេញក្នុងឆ្នាំ១៩៩៦។

វគ្គសិក្សានៃការងារសង្គមត្រូវបានណែនាំមុខវិជ្ជា/ប្រធានបទសម្រាប់ដាក់បញ្ចូលនៅក្នុងកម្មវិធីបរិញ្ញាបត្រផ្នែកសង្គមវិទ្យាចាប់តាំងពីឆ្នាំ១៩៩៤។ បន្ទាប់ពីកិច្ចសហប្រតិបត្តិការរយៈពេល៣ឆ្នាំជាមួយសាកលវិទ្យាល័យវ៉ាស៊ីនតោននៅទីក្រុងស៊ីថល នាយកដ្ឋានកិច្ចការសង្គមនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញត្រូវបានបង្កើតឡើង[13] ហើយបានជ្រើសរើសក្រុមការងារដំបូងរបស់ខ្លួន។ នៅឆ្នាំ២០០៧ សាកលវិទ្យាល័យភូមិន្ទភ្នំពេញក៏បានផ្តួចផ្តើមកិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យ Ewha Womans University(EWU) នៅទីក្រុងសេអ៊ូល នៃសាធារណរដ្ឋកូរ៉េ ដើម្បីបង្កើតថ្នាក់អនុបណ្ឌិតសិល្បៈក្នុងការងារសង្គម ដែលមាន៥៤ក្រេឌីដ។ រហូតមកដល់បច្ចុប្បន្ននេះនិស្សិតដែលបានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកសិល្បៈក្នុងការងារសង្គម(Bachelor of Arts in Social Work)ចំនួន ១៩៨ នាក់ និងថ្នាក់អនុបណ្ឌិតផ្នែកសិល្បៈក្នុងការងារសង្គម (Master of Art in Social Work)ចំនួន ៨២ នាក់ ដែលកំពុងបំរើការនៅក្នុងស្ថាប័នរដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេសដែលធ្វើការងារក្នុងវិស័យសង្គមកិច្ច។

### ១.២.២.វិទ្យាស្ថានជាតិសង្គមកិច្ច (NISA)

នៅខែតុលា ឆ្នាំ២០១១ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានទទួលការអនុញ្ញាតពីរាជរដ្ឋាភិបាលឱ្យបើកវិទ្យាស្ថានជាតិសង្គមកិច្ច (NISA)តាមរយៈអនុក្រឹត្យលេខ ២៣៣ អនក្រ.បក ។ រចនាសម្ព័ន្ធវិទ្យាស្ថានជាតិសង្គមកិច្ចរាប់បញ្ចូលមហាវិទ្យាល័យសង្គមកិច្ចដែលរួមមានដេប៉ាតឺម៉ង់សង្គមកិច្ច ដេប៉ាតឺម៉ង់គ្រប់គ្រងកិច្ចគាំពារសង្គម និងដេប៉ាតឺម៉ង់សង្គមវិទ្យា មហាវិទ្យាល័យវិស្វកម្មឧបករណ៍សិប្បនិម្មិតនិងរណប ដែលរួមមានដេប៉ាតឺម៉ង់វិស្វកម្មឧបករណ៍សិប្បនិម្មិតនិងរណប[14]ដេប៉ាតឺម៉ង់វិស្វកម្មឧបករណ៍ជំនួយចលនា និងដេប៉ាតឺម៉ង់វិទ្យាសាស្ត្រព្យាបាល

---

[12] http://ifsw.org/policies/definition-of-social -work/

[13] ក្រសួងអប់រំ យុវជន និងកីឡាបានអនុម័តកម្មវិធីថ្នាក់បរិញ្ញាបត្រផ្នែកសង្គមកិច្ចនៅឆ្នាំ២០០៨។

[14] កាលពីមុនកកម្មវិធីនេះស្ថិតក្រោមប្រតិបត្តិការរបស់សាលាបច្ចេកទេសអវយវៈសិប្បនិម្មិតនិងរណបកម្ពុជាពីឆ្នាំ១៩៩៣ ដល់ឆ្នាំ ២០១២។

ដោយចលនា សាលាបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការ[15] ដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ការិយាល័យសិក្សានិងស្រាវជ្រាវ ការិយាល័យរដ្ឋបាលនិងបុគ្គលិក និងការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុ។

វិទ្យាស្ថានជាតិសង្គមកិច្ច(NISA)បានទទួលការអនុម័តពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងអប់រំ យុវជន និងកីឡា ដើម្បីផ្តល់កម្មវិធីថ្នាក់បរិញ្ញាបត្រសង្គមកិច្ច សម្រាប់អប់រំកម្រិតឧត្តម និងកម្រិតបច្ចេកទេសនិងវិជ្ជាជីវៈដល់និសិត្ស មន្ត្រីរាជការ និងអ្នកពាក់ព័ន្ធឱ្យក្លាយជាបុគ្គលិកសង្គម អ្នកជំនាញវិជ្ជាជីវៈផ្តល់សេវាសង្គម ប្រកបដោយគុណតម្លៃនិងក្រមសីលធម៌ ចំណេះដឹង និងជំនាញលើការងារសង្គមកិច្ច។ វិទ្យាស្ថានជាតិសង្គមកិច្ចបានធ្វើសហប្រតិបត្តិការជាមួយសកលវិទ្យាល័យ គ្រឹះស្ថានអប់រំជាតិនិងអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេស ផ្លាស់ប្តូរបទពិសោធន៍ និងទស្សនកិច្ចសិក្សាដើម្បីពង្រឹងសមត្ថភាពគ្រូបង្រៀន និងកែលម្អកម្មវិធីសិក្សាឱ្យស្របតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជានិងអន្តរជាតិ។ រហូតមកដល់បច្ចុប្បន្ននេះនិស្សិតដែលបានបញ្ចប់បរិញ្ញាបត្រផ្នែកសង្គមកិច្ចវិទ្យាចំនួន ៩៣ នាក់(ស្រី៣៨នាក់) ហើយបច្ចុប្បន្នកំពុងធ្វើការនៅស្ថាប័នរាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេស និងវិស័យឯកជន។ និស្សិតទើបបញ្ចប់ការសិក្សាបរិញ្ញាបត្រសង្គមវិទ្យាចំនួន២០នាក់ត្រូវបានជ្រើសរើសជាបុគ្គលិកសង្គមកិច្ចជាប់កិច្ចសន្យាដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តាមរយៈការគាំទ្រពី **UNICEF** និង **USAID** ។ NISA ត្រូវបានបង្កើតឡើងដោយផ្អែកលើអនុសាសន៍ពីការបណ្តុះបណ្តាលទាក់ទងនឹងការងារសង្គមកិច្ចមុនៗ (សូមមើល ១.៣) ដើម្បីបង្កើតការអប់រំការងារសង្គមកិច្ចជាផ្លូវការ។

### ១.២.៣.វិទ្យាស្ថានសន្តប៉ូល (SPI)

វិទ្យាស្ថានសន្តប៉ូល (**The Saint Paul Institute**) គឺជាវិទ្យាស្ថានឧត្តមសិក្សាកាតូលិកតែមួយគត់នៅកម្ពុជាដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០៩ ដោយ **Bishop Olivier Schmitthaeusler** ក្រោមការគាំទ្រពីលោកស្រី Peggy Goh ជនជាតិសាំងហ្គាពួរ។ វិទ្យាស្ថានបានផ្តល់ជូននិស្សិតអាហារូបករណ៍និងនិស្សិតបង់ថ្លៃសិក្សាច្រើនជាង ៣២៩នាក់នៅទូទាំងកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រ។ វិទ្យាស្ថានសន្តប៉ូលបានផ្តល់ជូននូវសញ្ញាបត្រជំនាញលើមុខជំនាញរួមមានវិស័យកសិកម្ម បច្ចេកវិទ្យាព័ត៌មាន ការគ្រប់គ្រងទេសចរណ៍ អក្សរសាស្ត្រអង់គ្លេស និងការងារសង្គម។ នៅឆ្នាំ២០១៣ បរិញ្ញាបត្រសង្គមកិច្ចត្រូវបានចាប់ផ្តើម ហើយនាពេលថ្មីៗនេះអាជ្ញាប័ណ្ណថ្មីសម្រាប់ការអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈបច្ចេកទេសត្រូវបានអនុម័ត។ រហូតមកដល់បច្ចុប្បន្ននេះ និស្សិតដែលបានបញ្ចប់បរិញ្ញាបត្រសង្គមកិច្ចចំនួន ៣៥នាក់(ស្រី១៨នាក់) គឺនិសិត្សចំនួន ៨០% កំពុងបំរើការជាមួយអង្គការមិនមែនរដ្ឋាភិបាល និង ២០% ធ្វើការជាមួយក្រុមហ៊ុនឯកជន។[16] ដោយសារតែសមិទ្ធិផលជាច្រើនរបស់ខ្លួនបានធ្វើឱ្យវិទ្យាស្ថានសន្តប៉ូលជាគ្រឹះស្ថានឧត្តមសិក្សាតែមួយគត់នៅកម្ពុជាដែលបានចូលជាសមាជិកពេញសិទ្ធនៃសមាគមមហាវិទ្យាល័យ និងសាកលវិទ្យាល័យកាតូលិកអាស៊ីប៉ុព៌ា។

## ១.៣. ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

### ១.៣.១.ការបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញសង្គមកិច្ច

ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៩០ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេសបានបោះជំហានចូលមកផ្តល់ការបណ្តុះបណ្តាលប៉ារ៉ាវិជ្ជាជីវៈដល់បុគ្គលិកដែលទើបជ្រើសរើសឱ្យចូលបម្រើការងារនៅក្នុងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេសដើម្បីឱ្យមន្ត្រី និងបុគ្គលិកទាំងនោះអាចបំពេញការងារ និងក្លាយជាអ្នកផ្តល់សេវាសង្គមកិច្ច ឬប្រតិបត្តិករនៅក្នុងការងារសង្គមកិច្ច។ អង្គការសេវាសង្គម

[15] កាលពីមុនស្ថិតក្រោមប្រតិបត្តិការរបស់អង្គការមិនមែនរដ្ឋាភិបាលផ្សេងៗគ្នា

[16] របាយការណ៍វិទ្យាស្ថានសន្តប៉ូលឆ្នាំ២០២០

កម្ពុជា(SSC) អង្គការចិត្តសង្គមអន្តរវប្បធម៌(TPO) គឺជាអង្គការមិនមែនរដ្ឋាភិបាលសំខាន់ដែលបានផ្តល់ការបណ្តុះបណ្តាលទូលំទូលាយសម្រាប់សេវាសង្គមកិច្ចជូនអ្នកផ្តល់សេវាជាច្រើន ក្នុងនោះរាប់បញ្ចូលមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទាផងដែរ។ មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ (UNICEF) សហការជាមួយអង្គការដៃគូធ្វើការកសាងសមត្ថភាពមន្ត្រីពាក់ព័ន្ធនៅក្នុងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានៅថ្នាក់ជាតិ និងថ្នាក់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន រាជធានី ខេត្តមានរយៈពេលពីឆ្នាំ២០០០ ដល់ឆ្នាំ២០១០ តាមកម្មវិធីបណ្តុះបណ្តាលចំនួនបីរួមមាន៖១.ការបណ្តុះបណ្តាលសេវាសង្គមកិច្ចមូលដ្ឋាន (BSST) ២.ការបណ្តុះបណ្តាលសេវាសង្គមកិច្ចជំនាញ(PSST) និង៣.ការបណ្តុះបណ្តាលគ្រប់គ្រងសេវាសង្គមកិច្ច (MSST)[17] ដើម្បីនិរន្តរភាពយូរអង្វែងកម្មវិធីបណ្តុះបណ្តាលនេះត្រូវបានប្តូរទៅជាវិទ្យាស្ថានជាតិសង្គមកិច្ច។

ការបណ្តុះបណ្តាលសេវាសង្គមកិច្ចមូលដ្ឋាន(BSST)៖ គឺជាវគ្គបណ្តុះបណ្តាលរយៈពេល២សប្តាហ៍លើចំណេះដឹងដែលទាក់ទងទៅនឹងវិស័យការងារសង្គមកិច្ច៖ តួអង្គ ស្ថាប័ន និងបច្ចេកទេស។ វគ្គនេះរួមមាន១១មេរៀន និងការអនុវត្តផ្ទាល់៖ សេចក្តីផ្តើម និងគោលការណ៍នៃការងារសង្គមកិច្ច ការស្គាល់ខ្លួនឯង សេចក្តីត្រូវការរបស់មនុស្ស សិទ្ធិកុមារ និងឥរិយាបថចំពោះកុមារ យេនឌ័រ អំពើហិង្សាក្នុងគ្រួសារ ការរំលោភបំពានផ្លូវភេទ ពិការភាព អាណត្តិការងាររបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អនុក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួង និងប្រកាសស្តីពីរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យមន្ទីរថ្នាក់រាជធានី ខេត្ត កុមារដែលមានតម្រូវការពិសេស និងការគ្រប់គ្រងករណី។

ការបណ្តុះបណ្តាលសេវាសង្គមកិច្ចជំនាញ(PSST)៖ គឺជាវគ្គបណ្តុះបណ្តាលការងារសង្គមកិច្ចដែលមានរយៈពេល៤សប្តាហ៍ដើម្បីពង្រឹងបន្ថែមទៅលើវគ្គ (BSST) និងផ្តល់ចំណេះដឹង និងជំនាញបន្ថែម ព្រមទាំងការយល់ដឹងពីឥរិយាបថទាក់ទងទៅនឹងតួនាទី និងការទទួលខុសត្រូវរបស់សិក្ខាកាម។ វគ្គនេះរួមមាន១២មេរៀន និងការអនុវត្តផ្ទាល់៖ ការគ្រប់គ្រងករណី ជំនាញសម្ភាសន៍ ការត្រួតពិនិត្យ ការរក្សាសៀវភៅព័ត៌មាន អាសយដ្ឋានទំនាក់ទំនង ការលើកកម្ពស់ការយល់ដឹងមេរោគអេដស៍ ជំងឺអេដស៍ ការប្រើប្រាស់សារជាតុញៀន យុត្តិធម៌អនីតិជន បណ្តាញការពារកុមារ ការថែទាំជំនួស និងការផ្តល់ប្រឹក្សាយោបល់។

ការបណ្តុះបណ្តាលគ្រប់គ្រងសេវាសង្គមកិច្ច (MSST)៖គឺជាការបណ្តុះបណ្តាលរយៈពេល១២ សប្តាហ៍ដែលពង្រឹងបន្ថែមលើវគ្គ (BSST) និងវគ្គ (PSST) ព្រមទាំងផ្តល់ចំណេះដឹង និងជំនាញបនថែមទាក់ទងទៅនឹងតួនាទី និង ការទទួលខុសត្រូវរបស់ពួកគេ ការអនុវត្ត និងការចូលរួមនៅក្នុងសកម្មភាពការងារសង្គមកិច្ចជាក់ស្តែង។ ការបណ្តុះបណ្តាលនេះផ្តោតការយកចិត្តទុកដាក់លើ៖ ការអនុវត្ត ការលើកកម្ពស់ និងការចែករំលែកបទពិសោធន៍ក្នុងអំឡុងពេលបណ្តុះបណ្តាលក្នុងថ្នាក់រៀន ការទទួលបានជំនាញដែលទាក់ទងទៅនឹងស្ថានភាពជាក់លាក់មួយចំនួន។

ការវាយតម្លៃនៅឆ្នាំ២០០៥ បានរកឃើញថាវគ្គបណ្តុះបណ្តាលទាំងបីបានបង្កើនចំណេះដឹង និងជំនាញរបស់សិក្ខាកាម ព្រមទាំងបានបង្ហាញឱ្យឃើញនៅការរីកចម្រើនជាវិជ្ជមានចំពោះឥរិយាបថនៅចុងបញ្ចប់វគ្គបណ្តុះបណ្តាល។ មិនសូវមានការកើនឡើងចំពោះជំនាញអនុវត្តនៅក្នុងវគ្គ PSST និងទិដ្ឋភាពមួយចំនួននៃវគ្គ MSST។ ខណៈពេលដែលកំពុងធ្វើការចង្អុលបង្ហាញភាពរីកចម្រើនជាវិជ្ជមានដែលសម្រេចបាន ជាពិសេសនៅក្នុងវគ្គបណ្តុះបណ្តាល និងលទ្ធផលនៃវគ្គ BSST ការវាយតម្លៃបានផ្តល់អនុសាសន៍ថា គួរផ្តល់ការត្រួតពិនិត្យបច្ចេកទេសរយៈពេលវែងជូនដល់មន្ត្រីមន្ទីរ ដែលជាមន្ត្រីជួរមុខអនុវត្តផ្ទាល់សម្រាប់ការងារសុខុមាលភាពកុមារ និងសុខុមាលភាពសង្គម ។

[17] ជាលទ្ធផលមន្ត្រីចំនួន ៧១៨ នាក់បានបញ្ចប់វគ្គ (BSST) ៨៤៧នាក់បានបញ្ចប់វគ្គ(PSST)និង៣៦នាក់បានបញ្ចប់វគ្គ(MSST)។

ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈកម្លាំងសេវាសង្គមដែលធ្វើឡើងដោយ ក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេសរៀងៗខ្លួន ដាច់ដោយឡែកពីគ្នាទៅតាមតម្រូវការសម្រាប់ផ្តល់សេវាមុខសញ្ញា មិនទាន់បានកំណត់កញ្ចប់មេរៀន និងកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាសង្គមកិច្ចរួមនៅឡើយ។ ទន្ទឹមនឹងនេះមិនទាន់មានបទដ្ឋានវិជ្ជជីវៈសង្គមកិច្ចសម្រាប់វាស់វែងសូចនាករគុណតម្លៃ ក្រមសីលធម៌ កម្រិតចំណេះដឹង និងកម្រិតជំនាញសម្រាប់កម្លាំងសេវាសង្គម។ បញ្ហាទាំងនេះតម្រូវឱ្យមានការរៀបចំផែនការយុទ្ធសាស្ត្រដើម្បីបណ្តុះបណ្តាលកម្លាំងសេវាសង្គមសម្រាប់អនុវត្តតួនាទី និងមុខងាររបស់ខ្លួនប្រកបដោយក្រមសីលធម៌ និងមានវិជ្ជាជីវៈ។

### ១.៣.២.ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិលនៅថ្នាក់ក្រោមជាតិ

អនុក្រឹត្យលេខ១៩២អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការបង្កើតសាលាជាតិរដ្ឋបាលមូលដ្ឋាន រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតសាលាជាតិរដ្ឋបាលមូលដ្ឋាន (ហៅកាត់ជាភាសាខ្មែរថា «ស.ជ.រ.ម» និងជាភាសាអង់គ្លេសថា«NASLA»)ឱ្យស្ថិតនៅក្រោមឱវាទក្រសួងមហាផ្ទៃក្នុងគោលបំណងផ្តល់ការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីរាជការ ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ សិស្ស និស្សិត និងអ្នកពាក់ព័ន្ធដទៃទៀត ព្រមទាំងសិក្សាស្រាវជ្រាវអំពីអភិបាលកិច្ច ការអភិវឌ្ឍមូលដ្ឋាន ការលើកកម្ពស់ស្វ័យភាពមូលដ្ឋាន និងការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ។ សាលាជាតិរដ្ឋបាលមូលដ្ឋាន (NASLA) ប្រៀបដូចជា សាលាភូមិន្ទរដ្ឋបាលសម្រាប់មន្ត្រីថ្នាក់ក្រោមជាតិ ពោលគឺជាយន្តការជានានិរន្តភាព នៃការបណ្តុះបណ្តាលដល់មន្ត្រីថ្នាក់ក្រោមជាតិដោយពង្រឹងសមត្ថភាពដល់មន្ត្រីគ្រប់ក្របខ័ណ្ឌ «ក» «ខ» និង «គ»[18] ចាប់ពីមន្ត្រីថ្មីរហូតដល់ថ្នាក់អគ្គនាយក និងអភិបាលរាជធានី ខេត្ត ដែលមានជំនាញគ្របដណ្តប់លើប្រធានបទពាក់ព័ន្ធការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនិងការផ្តល់សេវានៅមូលដ្ឋាន។

សាលាជាតិរដ្ឋបាលមូលដ្ឋាន លើកម្ពស់វិជ្ជាជីវៈរបស់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិនិងជាវិទ្យាស្ថានទាន់សម័យដែលអាចផ្តល់ការបណ្តុះបណ្តាលមានគុណភាព ហើយសិក្ខាកាមអាចមានមោទនៈភាពនៅពេលបញ្ចប់ការសិក្សានៅ ស.ជ.រ.ម នេះ។ កម្មវិធីសិក្សាចែកជា៤ប្រភេទ៖(១)វគ្គបឋមសម្រាប់មន្ត្រីថ្មី (២)វគ្គអាជីពការងារសម្រាប់មន្ត្រីឡើងឋានន្តរស័ក្តិ (៣)វគ្គក្រឹត្យការ សម្រាប់បំប៉នសមត្ថភាពប្រចាំឆ្នាំ និង(៤)វគ្គជំនាញ សម្រាប់មន្ត្រីជំនាញនៅតាមអង្គភាព។ វគ្គបឋម និងវគ្គអាជីពការងារ ជាវគ្គមធ្យមដែលអាចមានរយៈពេលរហូតដល់បីខែ។ ដោយឡែកវគ្គក្រឹត្យការនិងវគ្គជំនាញមានរយៈពេលខ្លីជាង។ ផ្អែកតាមតម្រូវការនេះតាមការប៉ាន់ស្មានបឋមបន្ទប់សិក្សារបស់សាលាជាតិរដ្ឋបាលមូលដ្ឋាននឹងត្រូវប្រើប្រាស់ពេញម៉ោងចាប់ពី ៣៥-៤០សប្តាហ៍ក្នុងមួយឆ្នាំ។ មុខងារស្នូល២របស់សាលាជាតិរដ្ឋបាលមូលដ្ឋាន គឺការបណ្តុះបណ្តាល និងការស្រាវជ្រាវ។

## ១.៤. ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា

ប្រព័ន្ធធានាគុណភាពអប់រំនៅកម្ពុជារៀបចំឡើងដើម្បីធ្វើឱ្យការអប់រំនិងការបណ្តុះបណ្តាលមានគុណភាពខ្ពស់ស្របតាមស្តង់ដារអន្តរជាតិ និងមានការទទួលស្គាល់យ៉ាងទូលំទូលាយនៅក្នុងសហគមន៍សិក្សានិងវិជ្ជាជីវៈអន្តរជាតិ។ ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា (ក.គ.ជ.ក) ជាធាតុសំខាន់ចាំបាច់មួយនៅក្នុងប្រព័ន្ធធានានិងទទួលស្គាល់គុណភាពអប់រំដែលធានាឱ្យមានសង្គតិភាពនៃការអប់រំ និងការបណ្តុះបណ្តាលនៅកម្ពុជា។[19]

---

[18] ប្រភេទក្របខណ្ឌ "ក" មន្ត្រីគ្រប់គ្រងរដ្ឋបាល(រដ្ឋបាលទូទៅ) មន្ត្រីរដ្ឋបាលជាន់ខ្ពស់(មហាផ្ទៃ) មន្ត្រីការទូតជាន់ខ្ពស់(ការទូត)គ្រូបង្រៀនកម្រិតឧត្តម(អប់រំ) មន្ត្រីសុខាភិបាលជាន់ខ្ពស់(សុខាភិបាល) និងមន្ត្រីបច្ចេកទេសជាន់ខ្ពស់(បច្ចេកទេស)"ខ"មន្ត្រីក្រមការ មន្ត្រីការបរទេស គ្រូបង្រៀនកម្រិតមូលដ្ឋាន មន្ត្រីសុខាភិបាលមធ្យម និងមន្ត្រីបច្ចេកទេសមធ្យម "គ" លេខាធិការរដ្ឋបាល ឬភ្នាក់ងាររដ្ឋបាល អនុរក្សពន្ធនាគារ គ្រូបង្រៀនកម្រិតបឋម មន្ត្រីសុខាភិបាលបឋម មន្ត្រីបច្ចេកទេសបឋម ឬភ្នាក់ងារបច្ចេកទេស។

[19] ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា

### ១.៤.១.កម្រិតគុណវុឌ្ឍិ

កម្រិតគុណវិឌ្ឍិអប់រំបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈមាន៨។ ចំពោះគុណវិឌ្ឍបួនកម្រិតដំបូងដែលអាចទទួលបានជាវិញ្ញាបនបត្រវិជ្ជាជីវៈ និងសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ១ ២ និង៣ ត្រូវបានផ្តល់តម្លៃសមមូលទៅនឹងការអប់រំមធ្យមសិក្សា។ ចំណែកឯបួនគុណវុឌ្ឍិបន្តពីនេះត្រូវចាត់ទុកជាគុណវុឌ្ឍិដែលសិក្សាក្រោយមធ្យមសិក្សា។ កម្រិតចូលទៅការអប់រំឧត្តមសិក្សាគឺការបញ្ចប់ដោយជោគជ័យនៅមធ្យមសិក្សាទុតិយភូមិ។ ក្របខ័ណ្ឌអប់រំឧត្តមសិក្សាមាន៤កម្រិតគុណវុឌ្ឍិដែលកម្រិតខ្ពស់បំផុតគឺសញ្ញាបត្រកម្រិតបណ្ឌិត។ សញ្ញាបត្រកិត្តិយសមិនរាប់បញ្ចូលទៅក្នុងក្របខ័ណ្ឌនេះទេ ប៉ុន្តែមានផ្តល់ជាគោលការណ៍ណែនាំសម្រាប់ការផ្តល់សញ្ញាបត្រនិងគោរម្យងារកិត្តិយសដោយផ្អែកទៅលើអនុសញ្ញាអន្តរជាតិ និងអនុក្រឹត្យលេខ១៥១ អនក្រ.បក ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការបណ្តុះបណ្តាលកម្រិតបណ្ឌិត។

ការបញ្ចប់ការសិក្សាដោយជោគជ័យនៅកម្រិតគុណវុឌ្ឍិណាមួយ មិនបញ្ជាក់ពីលក្ខណៈសម្បត្តិចាំបាច់របស់បុគ្គលដើម្បីដើម្បីចូលសិក្សាបន្តនៅកម្រិតគុណវុឌ្ឍិបន្ទាប់ឡើយ។ លក្ខខណ្ឌចូល ឬបន្តការសិក្សាអាចនឹងរៀបចំឡើងដោយផ្អែកទៅលើសំណុំសមត្ថភាពនៃគុណវុឌ្ឍិដែលមាន ឬនិទ្ទេស(ចំណាត់ថ្នាក់)ឬលក្ខណវិនិច្ឆ័យផ្សេងទៀតដើម្បីទទួលបានគុណវុឌ្ឍិខ្ពស់ជាង។ កម្រិតគុណវុឌ្ឍិសម្រាប់ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ការអប់រំកម្រិតឧត្តមសិក្សា និងទំនាក់ទំនងរវាងវិស័យទាំងពីរមានបង្ហាញជារចនាសម្ព័ន្ធដូចខាងក្រោម៖

តារាងទី១៖រចនាសម្ព័ន្ធក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា

| កម្រិត | ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ | ការអប់រំឧត្តមសិក្សា |
|---|---|---|
| ៨ | បណ្ឌិតបច្ចេកវិទ្យា/ឯកទេស | បណ្ឌិត |
| ៧ | បរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេស | សញ្ញាបត្រជាន់ខ្ពស់ |
| ៦ | បរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេសសញ្ញាបត្រវិស្វករ | បរិញ្ញាបត្រ |
| ៥ | សញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររងបច្ចេកទេស/ឯកទេស | បរិញ្ញាបត្ររង |
| ៤ | សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ៣ | |
| ៣ | សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ២ | |
| ២ | សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ១ | |
| ១ | វិញ្ញាបនបត្រវិជ្ជាជីវៈ | |

### ១.៤.២.ក្រេឌីត

ជាគោលការណ៍ ការកំណត់ចំនួនក្រេឌីតក្នុងក្របខ័ណ្ឌគុណវុឌ្ឍិនេះគឺ១៥ម៉ោងស្មើនឹង១ក្រេឌីតសម្រាប់ការបង្រៀនក្នុងកម្រិតធម្មតា ៣០ម៉ោងស្មើនឹង១ក្រេឌីតសម្រាប់ការសិក្សាប្រតិបត្តិ និងចំនួន៤៥ម៉ោងស្មើនឹង១ក្រេឌីតសម្រាប់ការអនុវត្តជាក់ស្តែង។ ចំពោះនិស្សិតសិក្សាពេញម៉ោងនៅកម្រិតគុណវុឌ្ឍិបរិញ្ញាបត្រក្នុងរយៈពេល១ឆមាសត្រូវសិក្សាយ៉ាងតិចចំនួន១៥ក្រេឌីតនិងយ៉ាងតិចចំនួន ៣០ក្រេឌីត ក្នុងរយៈពេលមួយឆ្នាំសិក្សា។[20] កម្មវិធីបណ្តុះ

[20] សម្រាប់ព័ត៌មានលម្អិតសូមមើលសេចក្តីសម្រេចលេខ០៤/០៤ គ.ទ.ក.សសរ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការអនុវត្តកម្មវិធីបណ្តុះបណ្តាលតាមប្រព័ន្ធក្រេឌីតនិងការផ្ទេរឌីត

បណ្តាលដែលប្រើឈ្មោះគុណវុឌ្ឍិដូច ឬប្រហាក់ប្រហែលគ្នាអាចប្រើរយៈពេល(និងចំនួនក្រេឌីតដែលត្រូវបែងចែក) ខុសគ្នាសម្រាប់កម្មវិធីបណ្តុះបណ្តាលទាំងនោះ។ ឧទាហរណ៍កម្មវិធីបណ្តុះបណ្តាលសម្រាប់កម្រិតបរិញ្ញាបត្រអាចមានរយៈពេល៤ឆ្នាំ ៥ឆ្នាំ ឬ៦ឆ្នាំ អាស្រ័យទៅតាមលទ្ធផលសិក្សាដែលបានរំពឹងទុក។ កម្មវិធីបណ្តុះបណ្តាលក្រោយមធ្យមសិក្សារាប់បញ្ចូលទាំងការចុះអនុវត្តផ្ទាល់នៅការដ្ឋាន(កន្លែងការងារ)ឬការចុះកម្មសិក្សាដែលអាចនឹងត្រូវកំណត់ជាចំនួនក្រេឌីត។ ប៉ុន្តែចំនួនក្រេឌីតដែលបានបែងចែកត្រឹមត្រូវ ឬសមស្របទៅតាមលទ្ធផលសិក្សារបស់និស្សិតដែលរំពឹងទុកពីបទពិសោធន៍នោះ។

នៅក្នុងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ គុណវុឌ្ឍិកំណត់ឡើងដើម្បីបញ្ជាក់អំពីការទទួលបាននូវសមត្ថភាពច្បាស់លាស់តាមតម្រូវការការងារពិសេសគុណវុឌ្ឍិវិញ្ញាបនបត្រវិជ្ជាជីវៈ សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ១ ២ ៣ និងសញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេសជាគុណផ្អែកលើសមត្ថភាព។ ប៉ុន្តែទោះជាយ៉ាងណា ក៏មានរយៈពេលកំណត់ជាមធ្យមសម្រាប់អ្នកសិក្សាក្នុងការអភិវឌ្ឍសមត្ថភាពទាំងនោះដោយអាស្រ័យទៅតាមពេលវេលាតម្រូវ។ តម្រូវការចំនួនក្រេឌីត គឺអាស្រ័យទៅតាមរយៈពេល និងបទពិសោធន៍ដែលនិស្សិតទទួលយកនៅក្នុងកម្មវិធីបណ្តុះបណ្តាលរបស់ខ្លួន។ សម្រាប់កម្មវិធីអប់រំ និងបណ្តុះបណ្តាលកម្រិតវិញ្ញាបនបត្រវិជ្ជាជីវៈ សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ១ ២ និង៣ ត្រូវមានចំនួនក្រេឌីតសរុបយ៉ាងតិច ៣០ក្រេឌីតសម្រាប់គុណវុឌ្ឍិនីមួយៗ។ ប៉ុន្តែអាចប្រើយន្តការសម្រាប់វាយតម្លៃសមត្ថភាពដែលមានស្រាប់រយៈបទពិសោធន៍នៅកន្លែងការងារ រយៈពេលដែលនិស្សិតត្រូវសិក្សាអាចនឹងត្រូវកាត់បន្ថយ តាមរយៈការវាយតម្លៃជាផ្លូវការលើការទទួលស្គាល់ការសិក្សាដែលមានពីមុន និងសមត្ថភាពបច្ចុប្បន្ន។

នៅកម្រិតគុណវុឌ្ឍិក្រោយមធ្យមសិក្សាតម្រូវឱ្យមានចំនួនក្រេឌីតសរុបយ៉ាងតិច៣០ក្រេឌីតសម្រាប់កម្មវិធីបណ្តុះបណ្តាលកម្រិតសញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកតេស/ឯកទេស(កម្រិតគុណវុឌ្ឍិ៥) បូកបន្ថែមចំនួន៣០ក្រេឌីត(ចំនួនក្រេឌីតអប្បបរមាសរុប៦០ក្រេឌីត) សម្រាប់កម្មវិធីបណ្តុះបណ្តាលកម្រិតគុណវុឌ្ឍិបរិញ្ញាបត្រនិងសញ្ញាបត្រវិស្វករ(កម្រិតគុណវុឌ្ឍិ៦)ត្រូវបូកបន្ថែមចំនួន៦០ ក្រេឌីតទៀតសរុបចំនួនក្រេឌីតអប្បបរមា១២០ក្រេឌីត។ គុណវុឌ្ឍសម្រាប់កម្មវិធីបណ្តុះបណ្តាល ពិសេសអាចតម្រូវឱ្យមានចំនួនក្រេឌីតបន្ថែមច្រើនជាងចំនួនក្រេឌីតអប្បបរមាដែលបានកំណត់។ ចំពោះគុណវុឌ្ឍបរិញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេសដែលនៅក្នុងផ្នែកអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈត្រូវសិក្សាបន្តពីគុណវុឌ្ឍិបរិញ្ញាបត្របច្ចេកទេស/ឯកទេសរយៈពេល២ឆ្នាំតាមរយៈមុខវិជ្ជាសិក្សាក្នុងថ្នាក់ ការសេសេរនិក្ខេបបទ និងការសិក្សាស្រាវជ្រាវសរសេរគម្រោងដែលមានក្រេឌីតអប្បបរមាសរុប៤៥ក្រេឌីត។

ចំពោះកម្រិតគុណវុឌ្ឍិបណ្ឌិតបច្ចេកទេស/ឯកតេសដែលមាននៅក្នុងផ្នែកអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈគឺជាលទ្ធផលនៃការសិក្សាដែលរួមបញ្ចូលទាំងស្វ័យអភិវឌ្ឍ និងអនុវត្តទូលំទូលាយទាំងចំណេះដឹងទ្រឹស្តីវិជ្ជាជីវៈនិងជំនាញក្នុងវិស័យផ្សេងៗនិង/ឬឯកតេសកម្រិតខ្ពស់បន្ថែមពីគុណវុឌ្ឍិបរិញ្ញាបត្រជាន់ខ្ពស់តាមរយៈការសិក្សាការស្រាវជ្រាវផ្ទាល់ខ្លួន និងការសរសេរនិក្ខេបបទ។ គុណវុឌ្ឍិបណ្ឌិតបច្ចេកវិទ្យា/ឯកតេសត្រូវសិក្សាយ៉ាងហោចណាស់៣ឆ្នាំ ហើយក្រេឌីតដែលកំណត់អប្បបរមាសរុប៥៤ក្រេឌីតដើម្បីស៊ីគ្នាទៅនឹងការពិពណ៌នាគុណវុឌ្ឍិកម្រិត៨។ នៅក្នុងការអប់រំឧត្តមសិក្សា ការតម្រូវឱ្យមានចំនួនក្រេឌីតអប្បបរមាសរុប៦០ក្រេឌីត(ឬ២ឆ្នាំសិក្សា)សម្រាប់គុណវុឌ្ឍិបរិញ្ញាបត្ររង (គុណវុឌ្ឍិកម្រិត៥) និងចំនួនក្រេឌីតអប្បបរមាសរុប១២០ក្រេឌីត សម្រាប់គុណវុឌ្ឍិបរិញ្ញាបត្រដែលមានកម្មវិធីបណ្តុះបណ្តាល៤ឆ្នាំ ១៤០ក្រេឌីតសម្រាប់គុណវុឌ្ឍិបរិញ្ញាបត្រដែលមានកម្មវិធីបណ្តុះបណ្តាល៥ឆ្នាំ និង១៦០ក្រេឌីតសម្រាប់គុណវុឌ្ឍិបរិញ្ញាបត្រដែលមានកម្មវិធីបណ្តុះបណ្តាល៦ឆ្នាំ(កម្រិតគុណវុឌ្ឍិ៦)។

នៅកម្រិតគុណវុឌ្ឍិបរិញ្ញាបត្រជាន់ខ្ពស់ត្រូវសិក្សាបន្ថែមពីគុណវុឌ្ឍិបរិញ្ញាបត្រចំនួន៣៩ក្រេឌីតបូកនឹងការសរសេរគម្រោងមួយ(ចំនួនក្រេឌីត៤៥ក្រេឌីតសម្រាប់គុណវុឌ្ឍិបរិញ្ញាបត្រជាន់ខ្ពស់ដែលមានកម្មវិធីបណ្តុះបណ្តាល២ឆ្នាំនិង៥៧ក្រេឌីតសម្រាប់គុណវុឌ្ឍិបរិញ្ញាបត្រជាន់ខ្ពស់ដែលមានកម្មវិធីបណ្តុះបណ្តាល៣ឆ្នាំ)។ ប្រសិនបើនិស្សិតចង់បន្តការសិក្សាពីគុណវុឌ្ឍិបរិញ្ញាបត្រជាន់ខ្ពស់ទៅគុណវុឌ្ឍិបណ្ឌិតមានជម្រើសពីរ ដែលតម្រូវឱ្យមានចំនួនមុខវិជ្ជាសិក្សាក្នុងថ្នាក់( Course work)ផ្សេងគ្នា) ជម្រើសទី១តម្រូវឱ្យមានចំនួនក្រេឌីតសរុបយ៉ាងតិច១២ក្រេឌីត សិក្សាបន្ថែមពីគុណវុឌ្ឍិបរិញ្ញាបត្រជាន់ខ្ពស់បូកនឹងនិក្ខេបបទ និងជម្រើសទី២ តម្រូវឱ្យមានចំនួនក្រេឌីតសរុបយ៉ាងតិច៥៤ក្រេឌីតបូកនឹងនិក្ខេបបទ។ តម្រូវការផ្សេងគ្នាក្នុងការស្រាវជ្រាវនិងការសេសេរនិក្ខេបបទបានថ្លឹងថ្លែង ឬទូទាត់សម្រាប់តម្រូវការសិក្សាចំនួនមុខវិជ្ជាក្នុងថ្នាក់ផ្សេងគ្នា ហើយជម្រើសទាំងពីរនេះស្ថិតនៅក្នុងកម្រិតគុណវុឌ្ឍិដូចគ្នា។

តារាងទី២៖ចំនួនក្រេឌីតអប្បបរមាដែលជាការតម្រូវសម្រាប់គុណវុឌ្ឍិនីមួយៗ

| កម្រិត | ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ | ការអប់រំឧត្តមសិក្សា | ចំនួនក្រេឌីត[21] អប្បបរមា |
|---|---|---|---|
| ៨ | បណ្ឌិតបច្ចេកវិទ្យា/ឯកទេស | បណ្ឌិត | ៥៤ |
| ៧ | បរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេស | សញ្ញាបត្រជាន់ខ្ពស់ | ៤៥ |
| ៦ | បរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេសសញ្ញាបត្រវិស្វករ | បរិញ្ញាបត្រ | ១២០ |
| ៥ | សញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររងបច្ចេកទេស/ឯកទេស | បរិញ្ញាបត្ររង | ៦០ |
| ៤ | សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ៣ | | ៣០ |
| ៣ | សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ២ | | ៣០ |
| ២ | សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ១ | | ៣០ |
| ១ | វិញ្ញាបនបត្រវិជ្ជាជីវៈ | | ៣០ |

### ១.៤.៣.លទ្ធផលសិក្សា

លទ្ធផលសិក្សារំពឹងទុករបស់និស្សិតកំណត់ដោយសំណុំសមត្ថភាពធំៗពីរគឺសមត្ថភាពមូលដ្ឋាននិងសមត្ថភាពស្នូលដោយចែកចេញជា៥ផ្នែកធំៗដែលអាចអនុវត្តបានគ្រប់កម្មវិធីបណ្តុះបណ្តាលទាំងអស់ក្នុងវិស័យអប់រំបច្ចេកទេសនិងវិជ្ជាជីវៈ ដោយឡែកក្នុងវិស័យអប់រំឧត្តមសិក្សាត្រូវបានចែកចេញជា៤ផ្នែកធំៗ និងផ្នែកជំនាញចិត្តចលនាដែលទាក់ទងតែទៅនឹងកម្មវិធីបណ្តុះបណ្តាលមួយចំនួន។ ផ្នែកទាំង៥នោះគឺ៖

**ក. ចំណេះដឹង**

សមត្ថភាពចងចាំ យល់ដឹង និងបកស្រាយព័ត៌មានរួមមាន៖

- ចំណេះដឹងពីហេតុការណ៍ជាក់លាក់
- ចំណេះដឹងខាងគំនិត(ទស្សនាទាន) គោលការណ៍និងទ្រឹស្តី
- ចំណេះដឹងពីទម្រង់ការ ឬនីតិក្រម ឬរបៀបរបបការងារ។

[21] សំដៅទៅលើក្រេឌីត មិនមែនម៉ោងក្រេឌីត ប៉ុន្តែត្រូវបានលើកឡើងជាម៉ោងក្រេឌីតនៅទីនេះដើម្បីឱ្យស្របតាមតារាងនៅក្នុងឯកសារផ្លូវការ

**ខ. ជំនាញក្នុងការគិត(ចំណេះដឹងវិភាគ)៖**

- សមត្ថភាពអនុវត្តការយល់ដឹងផ្នែកទស្សនទាន គោលការណ៍ ទ្រឹស្តី និងទម្រង់ការនៅក្នុងការគិតវិភាគ និងការប៉ិនប្រសប់ ឬច្នៃប្រឌិតក្នុងការដោះស្រាយបញ្ហាទាំងនៅពេលគេប្រាប់ឱ្យធ្វើនិងនៅពេលជួបប្រទះស្ថានការណ៍ថ្មីដែលមិនគ្រោងទុកជាមុន។

**គ. ជំនាញទំនាក់ទំនងអន្តរបុគ្គលនិងការទទួលខុសត្រូវ**

សមត្ថភាព រួមមាន៖

- ទទួលខុសត្រូវក្នុងការសិក្សារបស់ខ្លួន និងបន្តអភិវឌ្ឍបុគ្គលិកលក្ខណៈនិងមុខរបរ
- ធ្វើជាក្រុមប្រកបដោយប្រសិទ្ធភាពនិងប្រើប្រាស់ភាពជាអ្នកដឹកនាំបានត្រឹមត្រូវ
- ដើរតួប្រកបដោយភាពជឿទុកចិត្តបានក្នុងទំនាក់ទំនងបុគ្គលនិងការងារ
- ប្រកាន់ខ្ជាប់នូវក្រមសីលធម៌ខ្ពស់ក្នុងបុគ្គលភាពនិងវេទិកាសាធារណៈ។

**ឃ. ជំនាញលេខនព្វន្ត ព័ត៌មានវិទ្យា និងទំនាក់ទំនង**

សមត្ថភាព រួមមាន៖

- ធ្វើទំនាក់ទំនងប្រកបដោយប្រសិទ្ធិភាពក្នុងទម្រង់និយាយនិងសរសេរ
- ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនង
- ប្រើបច្ចេកទេសគណិតវិទ្យាមូលដ្ឋាននិងស្ថិតិវិទ្យា

**ង. ជំនាញចិត្តចលនា**

- សមត្ថភាពប្រតិបត្តិជំនាញមួយ ឬច្រើនដោយងាយ និងជាស្វ័យប្រវត្តិប្រើទាំងរូបសាស្ត្រនិងបញ្ញាញាណ
- សមត្ថភាពប្រតិបត្តិជំនាញផ្សេងៗ រួមបញ្ចូលគ្នាទៅតាមលំដាប់លំដោយនៃការងារប្រកបដោយសង្គតិភាព
- សមត្ថភាពបង្កើតជាថ្មីនូវជំនាញប្រកបដោយសមាមាត្រភាពយ៉ាងត្រឹមត្រូវនិងជាក់លាក់ ហើយជារឿយៗអាចប្រតិបត្តិការងារដែលប្រគល់ឱ្យដោយឯករាជ្យភាព
- ប្រតិបត្តិជំនាញភាគច្រើនអាស្រ័យទៅនឹងការសិក្សា ឬការណែនាំច្រើនជាងការពិនិត្យសង្កេត។

ជំនាញចិត្តចលនាទាក់ទងទៅនឹងភាពស្ទាត់ជំនាញខាងហត្ថកម្ម(ធ្វើដោយដៃ) ដែលអនុវត្តភាគច្រើនទៅលើកម្មវិធីបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ ចំពោះការអប់រំឧត្តមសិក្សាអនុវត្តតែទៅលើកម្មវិធីបណ្តុះបណ្តាលមួយចំនួនប៉ុណ្ណោះ។ ជំនាញចិត្តចលនាមានសារៈសំខាន់ខ្លាំងបំផុតនៅក្នុងអាជីព និងមុខរបរបច្ចេកទេស និងក្នុងជំនាញមួយចំនួននៅក្នុងការអប់រំឧត្តមសិក្សាទូទៅ។ ឧទាហរណ៍ ធុរជន ការី បរិក្ខារកិច្ច (អ្នកបញ្ជាឧបករណ៍ បរិក្ខារសំខាន់ៗ) ពេទ្យវះកាត់ វិចិត្រករ ឬតន្ត្រីករ ចាំបាច់ត្រូវមានជំនាញចិត្តចលនាកម្រិតខ្ពស់។ ដោយសារជំនាញខាងចិត្តចលនាទាំងនោះ ភាគច្រើនប្រើតែនៅក្នុងជំនាញមួយចំនួននិងមានលក្ខណៈប្រែប្រួលយ៉ាងទូលំទូលាយ លទ្ធផលសិក្សារំពឹងទុកសម្រាប់កម្រិតគុណវុឌ្ឍិនីមួយៗ មិនមានពិពណ៌នានៅក្នុងវិស័យអប់រំឧត្តមសិក្សានៃក្របខ័ណ្ឌគុណវុឌ្ឍិឡើយថ្វីបើជំនាញចិត្តចលនាទាំងនោះមានរៀបរាប់នៅក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ ទោះជាយ៉ាងនេះក្តី គ្រឹះស្ថានណាដែលមានកម្មវិធីបណ្តុះបណ្តាលទាក់ទងនឹងជំនាញចិត្តចលនា គួរតែពិពណ៌នាឱ្យបានច្បាស់លាស់ពីជំនាញនេះនៅក្នុងស្តង់ដារនៃលទ្ធផលសិក្សា ហើយវិធីសាស្ត្រនៃការបង្រៀននិងការវាយតម្លៃការសិក្សាគួរដាក់បញ្ចូលទៅក្នុងកម្មវិធីបណ្តុះបណ្តាលនិងមុខវិជ្ជាជំនាញ។

## ១.៥. ការវិភាគប្រភេទកម្លាំងសេវាសង្គម និងមុខងារ

បច្ចុប្បន្នមិនទាន់មានស្តង់ដារនិយមន័យ និងគ្មានការផ្តល់ចំណាត់ថ្នាក់សម្រាប់មន្ត្រីរាជការដោយក្រសួងមុខងារសាធារណៈនៃបុគ្គលិកសង្គមនៅកម្ពុជា។ ចំពោះការកំណត់ស្តង់ដារនិយមន័យនិងចំណាត់ថ្នាក់បុគ្គលិកសង្គមមានសារៈសំខាន់ណាស់សម្រាប់កម្លាំងសេវាសង្គមលើការងារផ្តល់សេវាសុខុមាលភាពសង្គមនិងកិច្ចការពារកុមារ។ នៅក្នុងឯកសារផែនការយុទ្ធសាស្ត្រនេះនឹងប្រើប្រាស់ស្តង់ដារនិយមន័យ និងចំណាត់ថ្នាក់បុគ្គលសង្គមដោយផ្អែកលើគោលការណ៍ណែនាំស្តីពីសមត្ថភាពមូលដ្ឋានសម្រាប់កម្លាំងសេវាសង្គមនៅកម្ពុជា ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ និងសេចក្តីណែនាំស្តីពីការពង្រឹងកម្លាំងសេវាសង្គមដើម្បីការពារកុមារចុះផ្សាយដោយមូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ (UNICEF) នៅទីក្រុងញូយ៉កនៅខែកុម្ភៈ ឆ្នាំ២០១៩ មានដូចខាងក្រោម៖

- **អ្នកអាជីពសង្គមកិច្ច(បុគ្គលិកសង្គមអាជីព)**សំដៅដល់អ្នកដែលបានបញ្ចប់ការសិក្សា ដោយជោគជ័យលើជំនាញសង្គមកិច្ចវិទ្យាពីគ្រឹះស្ថានអប់រំណាមួយ ហើយប្រើប្រាស់ចំណេះដឹងនិងជំនាញរបស់ខ្លួន ដើម្បីផ្តល់សេវាសង្គមជូនអតិថិជន(អាចជាបុគ្គល គ្រួសារ ក្រុម សហគមន៍ ឬមួយសង្គមជារួម)។ បុគ្គលិកសង្គមអាជីពជួយប្រជាពលរដ្ឋបង្កើនសមត្ថភាពរបស់គាត់សម្រាប់ដោះស្រាយ និងទប់ទល់ជាមួយបញ្ហាជួយឱ្យប្រជាពលរដ្ឋទទួលបានប្រភពធនធានចាំបាច់ សម្របសម្រួលអន្តរកម្មរវាងបុគ្គលនិងបុគ្គល និងរវាងប្រជាពលរដ្ឋជាមួយបរិស្ថាន ធ្វើឱ្យស្ថាប័នពាក់ព័ន្ធឆ្លើយតបចំពោះប្រជាពលរដ្ឋ ហើយរួមចំណែកក្នុងការបង្កើតអនុវត្តនិងវាយតម្លៃគោលនយោបាយសង្គម។ អ្នកអាជីពសង្គមកិច្ចអាចធ្វើការជាមួយអតិថិជនផ្ទាល់ ដើម្បីដោះស្រាយបញ្ហាបុគ្គល បញ្ហាគ្រួសារ និងបញ្ហាសហគមន៍។ ម៉្យាងទៀតអ្នកអាជីពសង្គមកិច្ចអាចធ្វើការកម្រិតជាប្រព័ន្ធដោយផ្តោតទៅលើការអភិវឌ្ឍក្របខ័ណ្ឌច្បាប់និងគោលនយោបាយ ឬមួយជាអ្នករដ្ឋបាលឬជាអ្នកកសាងផែនការក្នុងប្រព័ន្ធសេវាសង្គមទាំងមូល។
- **អ្នកអាជីពសង្គមកិច្ចរង(បុគ្គលិកសង្គមប៉ារ៉ាអាជីព)** នឹងធ្វើការនៅក្បែរឬគាំទ្រការងារជំនាញក្នុងវិស័យតែមួយ។ ប៉ារ៉ាអាជីពត្រូវបានបណ្តុះបណ្តាលឱ្យអនុវត្តមុខងារជាក់លាក់ ប៉ុន្តែមិនតម្រូវមានការបញ្ជាក់ឬមានការអនុញ្ញាតត្រឹមត្រូវដើម្បីអនុវត្តជាអ្នកមានវិជ្ជាជីវៈពេញលេញ ដែលនៅក្នុងមុខវិជ្ជាខ្លះត្រូវការមហាវិទ្យាល័យឬមហាវិទ្យាល័យសាកលវិទ្យាល័យឬការបណ្តុះបណ្តាលជំនាញ។
- **អ្នកសង្គមកិច្ចមិនអាជីព(បុគ្គលិកសង្គមប៉ារ៉ាវិជ្ជាជីវៈ)** គឺត្រួតពិនិត្យអ្នកអាជីពសង្គមកិច្ចរង បុគ្គលិក ឬអ្នកស្ម័គ្រចិត្តដែលធ្វើការនៅតាមសហគមន៍បម្រើសេចក្តីត្រូវការរបស់ជនរងគ្រោះនិងងាយរងគ្រោះរួមទាំងកុមារនិងគ្រួសារ ជាពិសេសនៅពេលដែលប្រព័ន្ធសុខមាលភាពសង្គមកំពុងអភិវឌ្ឍ។
- **អ្នកសង្គមកិច្ចសម្ព័ន្ធ(បុគ្គលិកសម្ព័ន្ធសង្គមកិច្ច)** គឺជាអ្នកដែលផ្តល់សេវាសង្គមប៉ុន្តែត្រូវបានផ្សារភ្ជាប់ជាមួយនឹងវិស័យផ្សេងទៀតដូចជាការអប់រំ សុខភាព ឬយុត្តិធម៌។ ឧទាហរណ៍រួមមានគិលានុបដ្ឋាក មេធាវី វេជ្ជបណ្ឌិត និងគ្រូបង្រៀននិងអ្នកផ្សេងទៀត។ អ្នកសង្គមកិច្ចសម្ព័ន្ធ អនុវត្តមុខងារជាច្រើនដែលធ្វើឱ្យប្រសើរឡើងការគាំទ្រ ឬសម្របសម្រួលមុខងារដែលអនុវត្តដោយកម្លាំងសេវាសង្គមផ្សេងទៀត។

សូមមើលនៅខាងក្រោមសម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីស្តង់ដារនិយមន័យ និងចំណាត់ថ្នាក់បុគ្គលិកសង្គមនៃកម្លាំងសេវាសង្គមមិនមានភាពខុសគ្នាខ្លាំងទេនៅក្នុងឯកសារចេញផ្សាយផ្លូវការដូចជា៖ការពិនិត្យឡើងវិញលើការអនុវត្តការងារសង្គមកិច្ចឆ្នាំ២០១៤ គោលការណ៍ណែនាំស្តីពីសមត្ថភាពមូលដ្ឋានសម្រាប់កម្លាំងសេវាសង្គមនៅកម្ពុជាឆ្នាំ២០១៩ សេចក្តីណែនាំស្តីពីការពង្រឹងកម្លាំងសេវាសង្គមដើម្បីការពារកុមារឆ្នាំ២០១៩ សេចក្តីថ្លែងការណ៍អាស៊ានស្តីពីការលើកកម្ពស់ការងារសង្គមកិច្ចឆ្នាំ២០១៩។

### ១.៥.១.ការត្រួតពិនិត្យឡើងវិញលើការអនុវត្តការងារសង្គមកិច្ចនៅកម្ពុជា

លទ្ធផលនៃការពិនិត្យឡើងវិញលើការអនុវត្តការងារសង្គមកិច្ចដែលផ្សព្វផ្សាយនៅថ្ងៃទី១១ខែមិថុនាឆ្នាំ ២០១៤ ក្រសួងស.អ.យ បង្ហាញថានៅតែមានតម្រូវការចាំបាច់ជាច្រើនក្នុងការពង្រឹងវិស័យការងារសង្គមតាមរយៈការបង្កើន ចំនួននិងគុណភាពរបស់អ្នកអនុវត្តការងារសង្គមកិច្ច។ លើសពីនេះទៀតផ្តល់នូវសារៈសំខាន់នៃវិស័យការងារសង្គម មានតម្រូវការបន្ទាន់ដើម្បីធានាថាការងារសង្គមត្រូវបានទទួលស្គាល់ថាជាវិជ្ជាជីវៈមួយហើយប្រភេទនៃការងារសង្គមកិច្ច ត្រូវបានទទួលស្គាល់រួមមាន បុគ្គលិកសង្គមកិច្ចវិជ្ជាជីវៈ និងអ្នកផ្តល់សេវាសង្គមកិច្ចប៉ារ៉ាវិជ្ជាជីវៈ។ លើសពីនេះទៅទៀត មានតំរូវការចាំបាច់ដើម្បីធានាថាវិស័យការងារសង្គមរីកលូតលាស់លើសពីវិស័យសុខុមាលភាពសង្គមនិងទូទាំងប្រព័ន្ធ មន្ត្រីរាជការផងដែររួមមាន សុខភាព ការអប់រំ យុត្តិធម៌ និងមហាផ្ទៃ។ ការរកឃើញនេះក៏បានផ្តល់អនុសាសន៍ផងដែរ ដើម្បីបង្កើតចំណាត់ថ្នាក់ការងារនៅក្នុងប្រព័ន្ធរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលទទួលស្គាល់មន្ត្រីជាពីរប្រភេទផ្សេងគ្នា ដែលមានមុខងារនៅក្នុងប្រព័ន្ធសុខុមាលភាពសង្គមសាធារណៈ និងសុខុមាលភាពកុមារៈ**១.អ្នកផ្តល់សេវាសង្គមកិច្ចប៉ារ៉ាវិជ្ជាជីវៈ និង២.បុគ្គលិកសង្គមកិច្ចវិជ្ជាជីវៈ**។ ការបែងចែកប្រភេទបែបនេះមិនត្រឹមតែនឹងត្រូវប្រើប្រាស់នៅក្នុង ក្រសួងស.អ.យ.ប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវប្រើប្រាស់នៅក្នុងប្រព័ន្ធមន្ត្រីរាជការរបស់រាជរដ្ឋាភិបាលកម្ពុជាទាំងមូល។ ការបែងចែកប្រភេទការងារទាំងនេះនឹងទទួលស្គាល់ប្រភេទតួនាទី និងការទទួលខុសត្រូវដែលប្រតិបត្តិការពីកម្រិតថ្នាក់ជាតិរហូតដល់កម្រិតថ្នាក់ក្រោមជាតិ និងសេចក្តីត្រូវការឱ្យមានបុគ្គលិកសង្គមកិច្ចវិជ្ជាជីវៈ និងបុគ្គលិកសង្គមកិច្ចប៉ារ៉ាវិជ្ជាជីវៈក្នុងការបំពេញមុខងារទាំងនេះ។[22]

### ១.៥.២.គោលការណ៍ណែនាំស្តីពីសមត្ថភាពមូលដ្ឋានសម្រាប់កម្លាំងសេវាសង្គម

គោលការណ៍ណែនាំស្តីពីសមត្ថភាពមូលដ្ឋានសម្រាប់កម្លាំងសេវាសង្គមនៅកម្ពុជា ត្រូវបានរៀបចំឡើងដើម្បីជាឧបករណ៍វាស់វែងកម្រិតសមត្ថភាពមូលដ្ឋានសម្រាប់កម្លាំងសេវាសង្គមលើផ្នែកគុណតម្លៃនិងក្រមសីលធម៌ ចំណេះដឹង និងជំនាញ ដែលជាតម្រូវការចាំបាច់ក្នុងការអនុវត្ត ការងារសង្គមកិច្ចគ្រប់កម្រិត។ អ្នកអនុវត្តការងារសង្គមគ្រប់ៗរូប នៅកម្ពុជាត្រូវប្រតិបត្តិតាមគោលការណ៍ណែនាំទាំងនេះ ដែលជាឧបករណ៍សម្រាប់វាស់វែងនៃការអនុវត្តល្អៗ និងជាកិច្ចគាំពារសម្រាប់អ្នកប្រើប្រាស់ និងអ្នកផ្តល់សេវា។ គោលការណ៍ណែនាំនេះ មានវិសាលភាពអនុវត្តចំពោះអង្គភាព ឬស្ថាប័ន ដែលផ្តល់សេវាសង្គម និងអ្នកផ្តល់សេវាសង្គមគ្រប់រូប ដែលធ្វើការផ្ទាល់ជាមួយអតិថិជន(បុគ្គល គ្រួសារ និងក្រុម)នៅក្នុងប្រទេសកម្ពុជា ទាំងអ្នកមាន និងអ្នកមិនទាន់មានសញ្ញាបត្រសង្គមកិច្ចវិទ្យា។ គោលការណ៍ណែនាំស្តីពីសមត្ថភាពមូលដ្ឋានសម្រាប់កម្លាំងសេវាសង្គមនៅកម្ពុជា គឺជាឯកសារយ៉ាងសំខាន់ដើម្បីគាំទ្រកម្លាំងសេវាសង្គមសម្រាប់អនុវត្តមុខងារផ្តល់សេវាសង្គមកិច្ចជូនអ្នកទទួលផលគ្រប់រូប។

គោលការណ៍ណែនាំស្តីពីសមត្ថភាពមូលដ្ឋានសម្រាប់កម្លាំងសេវាសង្គមត្រូវបានបែងចែកជា៣ផ្នែកធំៗរួមមាន៖ (១)គុណតម្លៃនិងក្រមសីលធម៌(២)ចំណេះដឹង(៣)ជំនាញ ហើយបានឱ្យនិយមន័យ **កម្លាំងសេវាសង្គម** សំដៅដល់អ្នកទាំងឡាយណាដែលធ្វើការដើម្បីធានាបាននូវការអភិវឌ្ឍសុខុមាលភាពរបស់ជនរងគ្រោះ និងជនងាយរងគ្រោះ ទាំងមន្ត្រីរដ្ឋាភិបាល ទាំងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ទោះជាអ្នកទាំងនោះមានអាជីព ឬគ្មានអាជីព ហើយធ្វើការដោយយកកម្រៃ ឬមិនយកកម្រៃក៏ដោយ។ កម្លាំងសេវាសង្គមផ្តោតការយកចិត្តទុកដាក់លើកម្មវិធីបង្ការ ឆ្លើយតប និងកម្មវិធីលើកកម្ពស់កិច្ចគាំទ្រដល់ជនរងគ្រោះ និងជនងាយរងគ្រោះនៅក្នុងសហគមន៍តាមរយៈការលុបបំបាត់ភាពក្រីក្រ ការកាត់បន្ថយការរើសអើង ការសម្របសម្រួលឱ្យទទួលបានសេវា ការលើកកម្ពស់យុត្តិធម៌សង្គម ព្រមទាំងការបង្ការ និងឆ្លើយតបចំពោះអំពើហិង្សា ការរំលោភបំពាន ការកេងប្រវ័ញ្ច ការមិនអើពើ និងការបំបែកពីគ្រួសារ។ ព្រម

[22] ការត្រួតពិនិត្យឡើងវិញលើការអនុវត្តការងារសង្គមកិច្ចផ្តោតលើសុខុមាលភាពកុមារ និងសុខុមាលភាពសង្គមសាធារណៈ ឆ្នាំ២០១៤ ។

ទាំងធ្វើការកំណត់កម្លាំងសេវាសង្គមរួមមាន៖ "ភ្នាក់ងារសង្គមកិច្ច អ្នកផ្តល់សេវាសង្គមឬកម្លាំងសេវាសង្គម និង អ្នកសង្គមកិច្ចវិទ្យា" ។

- **ភ្នាក់ងារសង្គមកិច្ច៖** សំដៅមន្ត្រីរបស់ក្រសួង មន្ទីរ ការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ច រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬបុគ្គលផ្សេងទៀត ដែលទទួលបានការបណ្តុះបណ្តាលជំនាញ ហើយត្រូវទទួលបានការតែងតាំង ឬទទួលស្គាល់ពីរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច។

- **អ្នកផ្តល់សេវាសង្គម ឬកម្លាំងសេវាសង្គម៖** សំដៅដល់អ្នកផ្តល់សេវាពាក់ព័ន្ធនឹងសុខុមាលភាពសង្គម និងសេដ្ឋកិច្ចដល់បុគ្គលម្នាក់ ឬគ្រួសារមួយ ឬក្រុមមួយ។ ការងារសង្គម គឺជាអាជីពវិជ្ជាជីវៈមួយពាក់ព័ន្ធនឹងការផ្តល់សេវា សង្គម។ ឧទាហរណ៍ អ្នកចិត្តសាស្ត្រ អ្នកផ្តល់ប្រឹក្សាផ្លូវចិត្ត បុគ្គលិកផ្នែកផ្ទេរថវិកា អ្នកស្ម័គ្រចិត្តតាមសហគមន៍ ។ល។

- **អ្នកសង្គមកិច្ចវិទ្យា៖** សំដៅដល់អ្នកដែលបានបញ្ចប់ការសិក្សាដោយជោគជ័យលើជំនាញសង្គមកិច្ចវិទ្យាពីគ្រឹះស្ថានអប់រំណាមួយ ហើយប្រើប្រាស់ចំណេះដឹងនិងជំនាញរបស់ខ្លួនដើម្បីផ្តល់សេវាសង្គមជូនអតិថិជន (អាចជាបុគ្គល គ្រួសារ ក្រុម សហគមន៍ ឬមួយសង្គមជារួម)។ អ្នកសង្គមវិទ្យា ជួយប្រជាពលរដ្ឋបង្កើនសមត្ថភាពរបស់គាត់សម្រាប់ដោះស្រាយ និងទប់ទល់ជាមួយបញ្ហា ជួយឱ្យប្រជាពលរដ្ឋទទួលបានប្រភពធនធានចាំបាច់ សម្របសម្រួលអន្តរកម្មរវាងបុគ្គលនិងបុគ្គល និងរវាងប្រជាពលរដ្ឋជាមួយបរិស្ថាន ធ្វើឱ្យស្ថាប័នពាក់ព័ន្ធឆ្លើយតបចំពោះប្រជាពលរដ្ឋ ហើយរួមចំណែកក្នុងការបង្កើត អនុវត្ត និងវាយតម្លៃគោលនយោបាយសង្គម។ អ្នកសង្គមកិច្ចវិទ្យា អាចធ្វើការជាមួយអតិថិជនផ្ទាល់ ដើម្បីដោះស្រាយបញ្ហាបុគ្គល បញ្ហាគ្រួសារ និងបញ្ហាសហគមន៍។ ម៉្យាងទៀតអ្នកសង្គមកិច្ចវិទ្យាអាចធ្វើការកម្រិតជាប្រព័ន្ធដោយផ្តោតទៅលើការអភិវឌ្ឍក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ ឬមួយជាអ្នករដ្ឋបាល ឬជាអ្នកកសាងផែនការក្នុងប្រព័ន្ធសេវាសង្គមទាំងមូល។

### ១.៥.៣.គោលការណ៍ណែនាំដើម្បីពង្រឹងកម្លាំងសេវាសង្គម

សេចក្តីណែនាំស្តីពីការពង្រឹងកម្លាំងសេវាសង្គមដើម្បីការពារកុមារចេញផ្សាយដោយផ្នែកការពារកុមារនៃមូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ (UNICEF) នៅទីក្រុងញូយ៉កនៅខែកុម្ភៈ ឆ្នាំ២០១៩ បង្ហាញថាកម្លាំងសេវាសង្គមរួមបញ្ចូលទាំងអ្នកជំនាញ និងអ្នជំនាញប៉ារ៉ាវិជ្ជាជីវៈដែលកំពុងបម្រើការក្នុងប្រព័ន្ធសេវាសង្គម។ ដូចគ្នានឹងវិជ្ជាជីវៈវេជ្ជសាស្ត្រដែររួមមានវេជ្ជបណ្ឌិត គិលានុបដ្ឋាក អ្នកព្យាបាលដោយចលនា និងអ្នកបច្ចេកទេស កម្លាំងសេវាសង្គមរួមមានមន្ត្រីដែលមានងារផ្សេងៗ តួនាទី និងមុខងារ ប៉ុន្តែមានគោលដៅរួមមួយគឺថែទាំ គាំទ្រ លើកស្ទួយ និងផ្តល់អំណាចដល់ជនងាយរងគ្រោះ។ សម្ព័ន្ធភាពកម្លាំងសេវាសង្គមសកល Global Social Service Workforce Alliance **(GSWA)**.[23] បានឱ្យនិយមន័យថាកម្លាំងសេវាសង្គមដូចជា៖ មន្ត្រីរដ្ឋាភិបាល បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល អ្នកផ្តល់សេវាសង្គមប៉ារ៉ាវិជ្ជាជីវៈ និងបុគ្គលិកសង្គមវិជ្ជាជីវៈមានប្រាក់ខែ និងមិនមានប្រាក់ខែ ដែលធ្វើការដើម្បីជានាការអភិវឌ្ឍសុខភាពនិងសុខុមាលភាពរបស់កុមារនិងគ្រួសារ។ កម្លាំងសេវាសង្គមផ្តោតសំខាន់លើកម្មវិធីការពារ ឆ្លើយតប និងលើកកម្ពស់ការគាំទ្រគ្រួសារ នងកុមារនៅក្នុងសហគមន៍ដើម្បីកាត់បន្ថយភាពក្រី កាត់បន្ថយការរើសអើង សម្របសម្រួលទៅរក សេវាគាំទ្រ លើកកម្ពស់យុត្តិធម៌សង្គម និងការពារនិងឆ្លើយតបចំពោះអំពើហិង្សា ការរំលោភបំពាន ការកេងប្រវ័ញ្ចការធ្វេសប្រហែស និងការបែកបាក់គ្រួសារ។

---

[23] The Global Social Service Workforce Alliance (GSSWA) is a network of over 1,800 members in 125 countries formed as a result of the Social Service Workforce Strengthening Summit held in 2010

- **បុគ្គលិកប៉ារ៉ាអាជីព** នឹងធ្វើការនៅក្បែរឬគាំទ្រការងារជំនាញក្នុងវិស័យតែមួយ។ ប៉ារ៉ាអាជីពត្រូវបានបណ្តុះបណ្តាលឱ្យអនុវត្តមុខងារជាក់លាក់ ប៉ុន្តែមិនតម្រូវមានការបញ្ជាក់ឬមានការអនុញ្ញាតត្រឹមត្រូវដើម្បីអនុវត្តជាអ្នកមានវិជ្ជាជីវៈពេញលេញ ដែលនៅក្នុងមុខវិជ្ជាខ្លះត្រូវការមហាវិទ្យាល័យឬមហាវិទ្យាល័យសាកលវិទ្យាល័យឬការបណ្តុះបណ្តាលជំនាញ។
- **បុគ្គលិកសង្គមប៉ារ៉ាវិជ្ជាជីវៈ**គឺគ្រូតពិត្យអ្នកប៉ារ៉ាអាជីព បុគ្គលិក ឬអ្នកស្ម័គ្រចិត្តដែលធ្វើការនៅតាមសហគមន៍បម្រើសេចក្តីត្រូវការរបស់ជនរងគ្រោះនិងងាយរងគ្រោះរួមទាំងកុមារនិងគ្រួសារ ជាពិសេសនៅពេលដែលប្រព័ន្ធសុខមាលភាពសង្គមកំពុងអភិវឌ្ឍ។
- **បុគ្គលិកសម្ព័ន្ធសង្គមកិច្ច** គឺជាអ្នកដែលផ្តល់សេវាសង្គមប៉ុន្តែត្រូវបានផ្សារភ្ជាប់ជាមួយនឹងវិស័យផ្សេងទៀតដូចជាការអប់រំ សុខភាព ឬយុត្តិធម៌។ ឧទាហរណ៍រួមមានគិលានុបដ្ឋាយិកា មេធាវីវេជ្ជបណ្ឌិត និងគ្រូបង្រៀននិងអ្នកផ្សេងទៀត។ បុគ្គលិកសម្ព័ន្ធសង្គមកិច្ចអនុវត្តមុខងារជាច្រើនដែលធ្វើឱ្យប្រសើរឡើង ការគាំទ្រ ឬសម្របសម្រួលមុខងារដែលអនុវត្តដោយកម្លាំងសេវាសង្គមផ្សេងទៀត។
- **បុគ្គលិកសង្គម** គឺជាផ្នែកមួយនៃកម្លាំងសេវាសង្គមកាន់តែទូលំទូលាយដែលអាស្រ័យលើបរិបទប្រទេសមានតួអង្គផ្សេងៗគ្នាជាច្រើនដែលមានតួនាទី មុខងារ សមត្ថភាព និងជំនាញផ្សេងៗគ្នាក្នុងកិច្ចការពារកុមារ។ ក្នុងប៉ុន្មានទសវត្សថ្មីៗនេះការងារសង្គមបានលេចចេញជាអាជីពឈានមុខគេក្នុងការផ្តល់សេវាសង្គមដោយផ្ទាល់និងត្រូវបានអភិវឌ្ឍនៅក្នុងប្រទេសជាង១០០។

សេចក្តីណែនាំស្តីពីការពង្រឹងកម្លាំងសេវាសង្គមដើម្បីការពារកុមារចេញផ្សាយដោយមូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ (UNICEF) នៅខែកុម្ភៈ ឆ្នាំ២០១៩ បានកំណត់ពីតួនាទីនិងមុខងាររបស់កម្លាំងសេវាសង្គម៖ នៅក្នុងបរិបទជាតិ កម្លាំងសេវាសង្គម មានតួនាទី និងមុខងារផ្តល់សេវាផ្សព្វផ្សាយ សេវាបង្ការនិងឆ្លើយតប និងស្តារនីតិសម្បទានៅកម្រិតម៉ាក្រូ កម្រិតកណ្តាល និងកម្រិតមីក្រូ មានដូចតារាងទី៣ខាងក្រោម។

តារាងទី៣៖ តួនាទីនិងមុខងាររបស់កម្លាំងសេវាសង្គមសម្រាប់កិច្ចការកុមារនិងគ្រួសារ (GSSWA and UNICEF)

| **កម្រិតមាក្រូ៖**<br>**សេវាផ្សព្វផ្សាយ**<br>សហគមន៍ សាលារៀន រដ្ឋាភិបាល និងសង្គមស៊ីវិល | **កម្រិតកណ្តាល៖**<br>**សេវាបង្កានិងទប់ស្កាត់**<br>កុមារ និងគ្រួសារស្ថិតនៅក្នុងភាពគ្រោះថ្នាក់ | **កម្រិតមីក្រូ៖**<br>**សេវាបង្ការនិងឆ្លើយតប**<br>កុមារនិងក្រុមគ្រួសារដែលបានឆ្លងកាត់អំពើហិង្សា ការរំលោភបំពាន ការកេងប្រវ័ញ្ច |
|---|---|---|
| - ការផ្សព្វផ្សាយ<br>- កសាង/ប្រមូលផ្តុំភាពជាដៃគូសហគមន៍<br>- សហការជាមួយកុមារនិងគ្រួសារ<br>- ធ្វើការនៅក្នុងបណ្តាញអន្តរក្រសួងស្តីពីគោលនយោបាយ<br>- តស៊ូមតិដើម្បីពង្រីកសេវាកម្ម | - បង្កើតយន្តការឆ្លើយតបបឋមដើម្បីកំណត់អត្តសញ្ញាណកុមាររងគ្រោះនិងងាយរងគ្រោះ<br>- ជានាឱ្យទទួលបានសេវាកម្មមូលដ្ឋាន<br>- ការអប់រំមាតាបិតា<br>- ចុះសួរសុខទុកដល់ផ្ទះ<br>- អភិវឌ្ឍជម្រើសថែទាំតាមលក្ខណៈគ្រួសារ<br>- គាំទ្រកម្មវិធីបង្វែរ | - សេវាគ្រប់គ្រងករណី<br>- សេវាបង្រួបបង្រួមសម្រាប់កុមារ<br>- គាំទ្រកុមារក្នុងប្រព័ន្ធយុត្តិធម៌<br>- សេវាការពារនិងគាំទ្រជនរងគ្រោះ<br>- ធ្វើការវាយតម្លៃស៊ីជម្រៅលើសុខភាពផ្លូវចិត្តនិងចិត្តសង្គម<br>- ផ្តល់ព័ត៌មានអំពីរបួសស្នាម សេវាប្រឹក្សាយោបល់ស្តារនីតិសម្បទា |

### ១.៥.៤.សេចក្តីថ្លែងការណ៍អាស៊ានស្តីពីការលើកកម្ពស់ការងារសង្គមកិច្ច

សិក្ខាសាលាថ្នាក់តំបន់ស្តីពីការពង្រឹងកម្លាំងសេវាសង្គមនៅកិច្ចប្រជុំរបស់អាស៊ាន នៅទីក្រុងហាណូយ ប្រទេសវៀតណាមពីថ្ងៃទី២៨-២៩ ខែតុលា ឆ្នាំ២០១៩[24] បានផ្តួចផ្តើមគំនិតដើម្បីគាំទ្រដល់ការពង្រឹងវិជ្ជាជីវៈការងារសង្គមកិច្ច និងកម្លាំងសេវាសង្គមនៅទូទាំងតំបន់អាស៊ាន ដោយធ្វើការពង្រឹងសមត្ថភាពរៀបចំផែនការ អភិវឌ្ឍនិងគាំទ្រដល់កម្លាំងសេវាសង្គម និងបង្កើតសេចក្តីប្រកាសស្តីពីការអភិវឌ្ឍការងារសង្គម។ ការផ្តួចផ្តើមនេះបង្កើតនូវគំនិតផ្តួចផ្តើមអាស៊ានជាច្រើនដើម្បីពង្រឹងសុខុមាលភាពសង្គម ការងារសង្គម និងគាំទ្រដល់ការអនុវត្តផែនការសកម្មភាពអាស៊ានស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី និងកុមារក៏ដូចជាការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៥និង១៦និងបំពេញបន្ថែមការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលអាស៊ានសម្រាប់សុខុមាលភាពនិងការងារសង្គម។ សេចក្តីប្រកាសអាស៊ានបានឱ្យនិយមន័យ"កម្លាំងសេវាសង្គម"សំដៅដល់មន្ត្រីរដ្ឋាភិបាល បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល បុគ្គលិកសង្គម និងបុគ្គលិកសង្គមប៉ារ៉ាវិជ្ជាជីវៈ ដែលធ្វើការជាមួយកុមារ យុវជន មនុស្សចាស់ ក្រុមគ្រួសារនិងសហគមន៍ដើម្បីធានាបាននូវការអភិវឌ្ឍសុខភាពនិងសុខុមាលភាព" រួមមាន៖ **បុគ្គលិកសង្គម** (Social Worker) **អ្នកជំនាញផ្សេងទៀត**(Other professionals) **បុគ្គលិកសង្គមប៉ារ៉ាវិជ្ជាជីវៈ**(Para-professional workers) **អ្នកស្ម័គ្រចិត្ត** (Volunteers) និង **បុគ្គលិកសម្ព័ន្ធសង្គមកិច្ច**(Allied workers)។

- **បុគ្គលិកសង្គម** គឺជាអ្នកជំនាញដែលមានសញ្ញាបត្រសិក្សាដែលជំរុញការផ្លាស់ប្តូរនិងការអភិវឌ្ឍសង្គម ភាពស្អិតរមួតក្នុងសង្គម ការផ្តល់អំណាចដល់ប្រជាជន។ ក្នុងករណីដែលគ្មានបទប្បញ្ញត្តិជាផ្លូវការនៃវិជ្ជាជីវៈនេះនៅក្នុងប្រទេសមួយចំនួន កម្លាំងសេវាសង្គមជាច្រើនផ្សេងទៀតត្រូវបានគេហៅថាជា" បុគ្គលិកសង្គម" ទោះយ៉ាងណាមានសារៈសំខាន់ណាស់ក្នុងការរក្សាសិទ្ធិវិជ្ជាជីវៈនេះសម្រាប់បុគ្គលិកសង្គមដែលមានសមត្ថភាព។
- **អ្នកជំនាញផ្សេងទៀត៖** កម្លាំងសេវាសង្គមក៏រួមបញ្ចូលក្រុមជំនាញផ្សេងទៀតផងដែរដូចជាអ្នកថែទាំកុមារនិងយុវជននិងចិត្តវិទូ។
- **បុគ្គលិកសង្គមប៉ារ៉ាវិជ្ជាជីវៈ** គឺជាអ្នកត្រួតពិនិត្យបុគ្គលិកជំនាញឬអ្នកស្ម័គ្រចិត្តដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់សេវាសង្គមដល់ជនងាយរងគ្រោះរួមទាំងកុមារនិងគ្រួសារនៅក្នុងសហគមន៍។ ពួកគេធ្វើការរួមគ្នាជាមួយបុគ្គលិកសង្គមនិងអ្នកជំនាញផ្សេងទៀត ប៉ុន្តែពួកគេក៏ត្រូវបានបណ្តុះបណ្តាលនិងបញ្ជាក់ដើម្បីអនុវត្តមុខងារ ហើយចាំបាច់ណាស់ក្នុងការទទួលស្គាល់សមត្ថភាព និងការចូលរួមរបស់ពួកគេ។
- **អ្នកស្ម័គ្រចិត្ត៖** ពួកគេផ្តល់សេវាដោយស្ម័គ្រចិត្តមិនយកថ្លៃសេវាកម្មដែលពួកគេផ្តល់ជូន។ អ្នកជំនាញឬអ្នកជំនាញប៉ារ៉ាវិជ្ជាជីវៈណាមួយអាចធ្វើជាអ្នកស្ម័គ្រចិត្តប្រសិនបើពួកគេមិនយកថ្លៃសេវាសម្រាប់សេវាកម្មដែលពួកគេផ្តល់ជូន។ ជារឿយៗអ្នកស្ម័គ្រចិត្តត្រូវបានគេយកចិត្តទុកដាក់ ប៉ុន្តែពួកគេគួរតែត្រូវបានរាប់បញ្ចូលជានិច្ចនៅពេលនិយាយអំពីកម្លាំងសេវាកម្មសង្គម។ លើសពីនេះទៅទៀតអ្នកស្ម័គ្រចិត្តគួរតែត្រូវបានត្រួតពិនិត្យដោយមិនគិតថាតើពួកគេជាអ្នកជំនាញឬអ្នកជំនាញប៉ារ៉ាវិជ្ជាជីវៈទេ។
- **បុគ្គលិកសម្ព័ន្ធសង្គមកិច្ច៖** គឺជាអ្នកជំនាញនិងអ្នកជំនាញប៉ារ៉ាវិជ្ជាជីវៈដែលពាក់ព័ន្ធនឹងវិស័យ អប់រំ សុខាភិបាល និងយុត្តិធម៌ ដែលមានតួនាទីសំខាន់ទាក់ទងនឹងការថែទាំ គាំទ្រ ការការពារ ផ្តល់សិទ្ធអំណាច និងការការពារ និងលើកកម្ពស់សិទ្ធិរបស់ប្រជាជន។ ពួកគេធ្វើការជាមួយកម្លាំងសេវាសង្គមប៉ុន្តែពួកគេត្រូវបានបង្កើតឡើងនៅក្នុងវិស័យមួយផ្សេងទៀត។

---

[24] ASEAN Secretariat and UNICEF, Regional Workshop on Social Service Workforce Strengthening: Kick off workshop on the ASEAN Declaration on Promotion of Social Work, ASEAN 2019

សិក្ខាសាលាថ្នាក់តំបន់ស្តីពីការពង្រឹងកម្លាំងសេវាសង្គមនៅកិច្ចប្រជុំរបស់អាស៊ាន នៅទីក្រុងហាណូយ ប្រទេសវៀតណាមពីថ្ងៃទី២៨-២៩ ខែតុលា ឆ្នាំ២០១៩[25] ចេញប្រកាសស្តីពីការលើកកម្ពស់ការងារសង្គមកិច្ច ដោយបានធ្វើការកំណត់ពីតួនាទីនិងមុខងារកម្លាំងសេវាសង្គមមានដូចជាចូលរួមចំណែកលើកកម្ពស់យុត្តិធម៌សង្គម កាត់បន្ថយការរើសអើង ការប្រឈមនិងការផ្លាស់ប្តូរអាកប្បកិរិយាដែលបង្កអន្តរាយនិងបទដ្ឋានសង្គម ការពារនិងឆ្លើយតបចំពោះអំពើហិង្សា ការរំលោភបំពាន ការធ្វេសប្រហែស និងការកេងប្រវ័ញ្ច និងការបែកបាក់គ្រួសារ មានចែងនៅតារាងទី៤។

តារាងទី៤៖ តួនាទីនិងមុខងាររបស់កម្លាំងសេវាសង្គមអាស៊ាន (ASEAN)

| ការផ្សព្វផ្សាយ | ការការពារ | ការឆ្លើយតប |
|---|---|---|
| - ការតស៊ូមតិ<br>- ការកៀរគរសហគមន៍<br>- បង្កើតនិងលើកកម្ពស់ស្តង់ដារ និងការអនុវត្ត<br>- ស្រាវជ្រាវ តាមដាន និងវាយតម្លៃ<br>- រដ្ឋបាលសេវាកម្មសង្គម<br>- ការអប់រំអ្នកផ្តល់សេវាសង្គម | - ការកំណត់អត្តសញ្ញាណដំបូងនៃភាពងាយរងគ្រោះ<br>- ធ្វើការជាមួយកុមារ គ្រួសារនិងសហគមន៍<br>- ការផ្តល់និងការទទួលបានសេវាបង្ការដូចជាការអភិវឌ្ឍកុមារតូចនិងការអប់រំ<br>- ច្រកទ្វារចូលសុវត្ថិភាព | - ការចូលរួមរបស់កុមារ<br>- ការគ្រប់គ្រងករណី<br>- ការគាំទ្រផ្នែកចិត្តសាស្ត្រនិង/ឬការប្រឹក្សា<br>- គាំទ្រដល់ការផ្តល់សេវាកម្ម<br>- ការការពារនិងការគាំទ្រជនរងគ្រោះ<br>- ការបង្រួបបង្រួមនិងការស្តារនីតិសម្បទា |

## ១.៦. ទំនាក់ទំនងរវាងផែនការយុទ្ធសាស្ត្រ ជាមួយនឹងឯកសារពាក់ព័ន្ធ

ផែនការយុទ្ធសាស្ត្រដើម្បីបណ្តុះបណ្តាលកម្លាំងសេវាសង្គមឆ្នាំ២០២១-២០២៥ដែលមានសង្គតិភាពជាមួយនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្សវិស័យសង្គមកិច្ចឆ្នាំ២០១៩-២០២៣ របស់វិទ្យាស្ថានជាតិសង្គមកិច្ច ផែនការសកម្មភាពដើម្បីទប់ស្កាត់និងឆ្លើយតបចំពោះអំពើហឹង្សាលើកុមារឆ្នាំ២០១៧-២០២១ ផែនការយុទ្ធសាស្ត្រវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ២០១៩-២០២៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ២០៣០ ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ គោលនយោបាយជាតិប្រជាជន ២០១៦-២០៣០ និងក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា ២០១៤ និងឯកសារពាក់ព័ន្ធមួយចំនួនទៀត។

ផែនការយុទ្ធសាស្ត្រដើម្បីបណ្តុះបណ្តាលកម្លាំងសេវាសង្គមគឺជាផែនទីតម្រង់ផ្លូវឱ្យវិទ្យាស្ថានជាតិសង្គមកិច្ច គ្រឹះស្ថានអប់រំ ក្រសួង ស.អ.យ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេស ដៃគូអភិវឌ្ឍន៍និងអង្គភាពពាក់ព័ន្ធចូលរួមអនុវត្តផែនការយុទ្ធសាស្ត្រដើម្បីបណ្តុះបណ្តាលកម្លាំងសេវាសង្គម ឱ្យសម្រេចបាននូវគោលដៅយុទ្ធសាស្ត្រ និងចំណុចដៅនៃសូចនាករដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រ ២០២១-២០២៥។

## ១.៧. ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានចេញសេចក្តីសម្រេចលេខ ៣១៨ អ.ស.យ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៩ ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសចម្រុះសម្រាប់រៀបចំយុទ្ធសាស្ត្រដើម្បីបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញសង្គមកិច្ចដល់កម្លាំងសេវាសង្គមដឹកនាំដោយវិទ្យាស្ថានជាតិសង្គមកិច្ច។ វិទ្យាស្ថានជាតិសង្គមកិច្ចដោយ

[25] ASEAN Secretariat and UNICEF, Regional Workshop on Social Service Workforce Strengthening: Kick off workshop on the ASEAN Declaration on Promotion of Social Work, ASEAN 2019

មានគាំទ្រពីមូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ(UNICEF)ប្រចាំកម្ពុជា បានជ្រើសរើសទីប្រឹក្សាបច្ចេកទេស ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រដើម្បីបណ្តុះបណ្តាលកម្លាំងសេវាសង្គមឆ្នាំ២០២១-២០២៥ រយៈពេលពីថ្ងៃទី២២ ខែមិថុនា ដល់ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ ចំនួន៩០ថ្ងៃ។ ជំហានសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពចងក្រងផែនការយុទ្ធសាស្ត្រដើម្បីបណ្តុះបណ្តាលកម្លាំងសេវាសង្គម និងពិនិត្យឡើងវិញនូវយុទ្ធសាស្ត្របណ្តុះបណ្តាល ផែនការសម្រាប់ពង្រឹងសមត្ថភាពកម្លាំងសេវាសង្គមកិច្ចការពារកុមារដែលត្រូវបានអនុវត្តដោយក្រសួង ស.អ.យ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស ដៃគូអភិវឌ្ឍដទៃទៀត និងឯកសារពាក់ព័ន្ធ។
- កំណត់យុទ្ធសាស្ត្រ និងរៀបចំមាតិកានៃសេចក្តីព្រាងផែនការយុទ្ធសាស្ត្រដើម្បីបណ្តុះបណ្តាលកម្លាំងសេវាសង្គមឆ្នាំ២០២១-២០២៥។
- រៀបចំចងក្រងសេចក្តីព្រាងសូន្យផែនការយុទ្ធសាស្ត្រដើម្បីបណ្តុះបណ្តាលកម្លាំងសេវាសង្គមដាក់ជូនក្រុមការងារបច្ចេកទេសចម្រុះវិទ្យាស្ថានជាតិសង្គមកិច្ចនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០។ សេចក្តីព្រាងទី១ ជូនសមាជិកក្រុមការងារបច្ចេកទេសផ្តល់ធាតុចូលបន្ថែម និងប្រមូលធាតុចូលពីកិច្ចប្រជុំក្រុមការងារបច្ចេកទេស និងសិក្ខាសាលាជាបន្តបន្ទាប់ ដើម្បីពិនិត្យកែសម្រួលសេចក្តីព្រាងទី១ឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ។
- រៀបចំកែសម្រួលសេចក្តីព្រាងចុងក្រោយនៃផែនការយុទ្ធសាស្ត្រដើម្បីអប់រំបណ្តុះបណ្តាលកម្លាំងសេវាសង្គមឆ្នាំ២០២១-២០២៥ សម្រាប់ស្នើសុំការអនុម័តពីឯកឧត្តមរដ្ឋមន្ត្រីក្រសួង ស.អ.យ។

### ១.៨ ទម្រង់ផែនការយុទ្ធសាស្ត្រ

ផែនការយុទ្ធសាស្ត្រដើម្បីអប់រំបណ្តុះបណ្តាលកម្លាំងសេវាសង្គម២០២១-២០២៥ ចែកជា៨ផ្នែក៖ផ្នែកទី១៖ រៀបរាប់ពីសាវតានិងបរិបទ ការអប់រំកម្លាំងសេវាសង្គមកម្រិតឧត្តម ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា ការវិភាគប្រភេទកម្លាំងសេវាសង្គមនិងមុខងារ ទំនាក់ទំនងរវាងផែនការយុទ្ធសាស្ត្រជាមួយនឹងឯកសារពាក់ព័ន្ធ ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រនិងទម្រង់ផែនការយុទ្ធសាស្ត្រ ផ្នែកទី២៖ការវិភាគមុខងារនិងសមត្ថភាពកម្លាំងសេវាសង្គមកិច្ចការពារកុមាររួមមានក្រសួង មន្ទីរ ស.អ.យ ក.ជ.ក រាជធានី ខេត្ត គ.ក.ស.ក ក.ក.ន.ក យន្តការកិច្ចការពារកុមារថ្នាក់ក្រោមជាតិ ផ្នែកទី៣៖រៀបរាប់ពីវឌ្ឍនភាពនិងបញ្ហាប្រឈម ផ្នែកទី៤៖ រៀបរាប់ពីទស្សនៈវិស័យ បេសកម្ម គោលដៅយុទ្ធសាស្ត្រ លទ្ធផលរំពឹងទុក ផ្នែកទី៥៖រៀបរាប់ពីការរៀបចំស្ថាប័នសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រ ផ្នែកទី៦៖រៀបរាប់ពីយុទ្ធសាស្ត្រកៀរគរហិរញ្ញប្បទានសម្រាប់ផែនការយុទ្ធសាស្ត្រ ផ្នែកទី៧៖រៀបរាប់ពីការត្រួតពិនិត្យតាមដាន និងវាយតម្លៃ និងផ្នែកទី៨៖សេចក្តីសន្និដ្ឋាន និងឧបសម្ព័ន្ធ។

## ២. ផែនទីស្ថាប័នផ្តល់សេវាសង្គម និងយន្តការកិច្ចការពារកុមារ

រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពសង្គមសាធារណៈ តាមរយៈក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមានការចូលរួមពីក្រសួង ស្ថាប័នជាច្រើនទៀតដូចជា ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ(ក.ក.ជ) ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក) និងស្ថាប័នដទៃទៀតដែលមានភារកិច្ចតាមអាណត្តិការងាររបស់ខ្លួនដូចមានចែងនៅក្នុងព្រះរាជក្រឹត្យស្តីពីការបង្កើត និងអនុក្រឹត្យស្តីពីការការរៀបចំ និងការប្រព្រឹត្តនៃក្រសួង ស្ថាប័ននោះ និងគណៈកម្មាធិការកិច្ចការពារមួយចំនួនទៀត។

## ២.១.ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ក្រៅពីក្រសួង ស្ថាប័នដែលរៀបរាប់ខាងលើ សម្រាប់**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** យោងតាមមាត្រា៣ នៃអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ មិនា ឆ្នាំ២០១១ ស្តីពីការពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង ស.អ.យ. និងលខិតបទដ្ឋានគិតិយុត្តគាំទ្រពាក់ព័ន្ធក្រសួងមានមុខងារផ្តល់សេវាសាធារណៈចំនួន ២២ ដូចជា៖១.កម្មវិធីជំនួយសង្គ្រោះបន្ទាន់ជនរងគ្រោះដោយដាច់ស្បៀងទីទ័លក្រ គ្រោះធម្មជាតិនិងគ្រោះមហន្តរាយដោយយថាហេតុនៅតាមសហគមន៍ ២.ផ្តល់សេវាថែទាំ គាំទ្រដល់ជនផ្ទុកមេរោគអេដស៍ ជំងឺអេដស៍និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ និងជំងឺកាចសាហាវផ្សេងៗនៅតាមសហគមន៍ ៣.កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនដល់ស្រ្តីមានផ្ទៃពោះនិងកុមារអាយុក្រោម ២ឆ្នាំ ៤.ដោះស្រាយបញ្ហា ទប់ស្កាត់ និងការពារជនអនាថា ៥.ទទួលថែទាំ និងព្យាបាលជនវិបល្លាសស្មារតី ៦.សេវាស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ ៧.មាតុភូមិនិវត្ត ស្តារនីតិសម្បទា និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ច និងទម្រង់ផ្សេងៗទៀតនៃការរំលោភបំពាន ៨.សេវាថែទាំជំនួសចំពោះកុមារ ៩.ការផ្តល់អាជ្ញាប័ណ្ណដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេស ១០.ការទុកដាក់កុមារជាមួយគ្រួសារអចិន្រ្តៃយ៍នៅប្រទេសទទួល ១១.ផ្តល់សេវាស្តារនីតិសម្បទាជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន ១២.ផ្តល់សេវាស្តារនីតិសម្បទាអនីតិជនទំនាស់នឹងច្បាប់ ១៣.របបគោលនយោបាយឧបត្ថម្ភចំពោះជនពិការក្រីក្រនៅតាមសហគមន៍ ១៤.សេវាបណ្តុះបណ្តាលវិជ្ជាជីវៈជូនជនពិការ ១៥.សេវាចុះបញ្ជិកាលើការអនុវត្តច្បាប់ពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ១៦.អន្តរាគមន៍សេវាយុត្តិធម៌សម្រាប់ជនពិការ ១៧.ផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទា ១៨.សេវាស្តារលទ្ធភាពពលកម្ម និងរបបគោលនយោបាយផ្នែកពិនិត្យ ព្យាបាល និងថែទាំសុខភាពចំពោះជនពិការក្រីក្រតាមសហគមន៍ ១៩.ផ្តល់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុក ២០.បើកផ្តល់របបសន្តិសុខសង្គម ជូនអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន ២១.ផ្តល់សេវាជួយដល់អតីតយុទ្ធជននៅតាមសហគមន៍ ២២.ការអប់រំ និងបណ្តុះបណ្តាលកម្រិតឧត្តមសិក្សា។

## ២.២.មន្ទីរ សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត

នៅថ្នាក់រាជធានីខេត្ត ក្រសួងមាន**មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**ជាសេនាធិការដើម្បីអនុវត្តនិងសម្រួលការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ យោងតាមប្រកាសលេខ ០៦៦ ស.អ.យ ចុះថ្ងៃទី ១២ ខែមករា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងលិខិតបទដ្ឋានគតិយុត្តគាំទ្រ មន្ទីរអនុវត្តផ្តល់សេវាសាធារណៈផ្ទាល់ ឬសម្របសម្រួលជាស្ថាប័ន អង្គភាព និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេសផ្តល់សេវាដល់អថិជនដូចក្រសួងដែរ លើកលែងតែសេវាមួយចំនួនមិនបានអនុវត្តទេនៅកម្រិតមន្ទីរ ស.អ.យ រាជធានីខេត្តមានដូចជា៖សេវាសាធារណៈទី៩.ការផ្តល់អាជ្ញាប័ណ្ណដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេស ១០.ការទុកដាក់កុមារជាមួយគ្រួសារអចិន្ត្រៃយ៍នៅប្រទេសទទួល ១២.ផ្តល់សេវាស្តារនីតិសម្បទាអនីតិជនទំនាស់នឹងច្បាប់ ១៥.សេវាចុះបញ្ជិកាលើការអនុវត្តច្បាប់ពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ ១៩.ផ្តល់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុក ២០.បើកផ្តល់របបសន្តិសុខសង្គមជូនអតីតយុទ្ធជននិងគ្រួសារអតីតយុទ្ធជន ២២.ការអប់រំនិងបណ្តុះបណ្តាលកម្រិតឧត្តមសិក្សា។

## ២.៣.ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម ក្រុង ស្រុក ខណ្ឌ

យោងតាមអនុក្រឹត្យលេខ ១៨២ អនក្រ.បក ១៨៣ អនក្រ.បក និង១៨៤អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ មាត្រា៧១ និងមាត្រា៥៦ ការិយាល័យ និងអង្គភាពជំនាញពាក់ព័ន្ធរបស់ក្រសួង ស្ថាប័ន ដែលមាននៅថ្នាក់ក្រុង ស្រុក និងខណ្ឌត្រូវធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលក្រុង ស្រុក និងខណ្ឌ។ មាត្រា២៦ និងមាត្រា២២

**ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម**ត្រូវបំពេញតួនាទីជាសេនាការឱ្យរដ្ឋបាលក្រុង ស្រុក និងខណ្ឌលើការងារសង្គមកិច្ច និងសុខុមាលភាពសង្គម និងមានភារកិច្ចចាត់ចែងលើមុខងារមួយចំនួនដូចជា៖ **ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ការងារសុខាភិបាល ការងារកិច្ចការនារី ការងារធម្មការនិងសាសនា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ ការងារវប្បធម៌និងវិចិត្រសិល្បៈ និងការងារគ្រោះមហន្តរាយ។ ការិយាល័យនេះជាសេនាធិការឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌមានភារកិច្ចអនុវត្ត និងសហការជាមួយអង្គភាព និងអង្គការមិនរដ្ឋាភិបាលក្នុងស្រុកនិងបរទេសលើការងារសង្គមកិច្ច និងសុខុមាលភាពសង្គមនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន មើលតារាងទី៥។

តារាងទី៥៖មុខងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា[26]

| មុខងារ | មុខងាររង ឬសកម្មភាព |
|---|---|
| ១ ការងារកុមារកំព្រានិងកុមារងាយរងគ្រោះ | ការគ្រប់គ្រងករណីកុមារកំព្រា និងងាយរងគ្រោះ<br>- គ្រប់គ្រង និងកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងរំលោភបំពានផ្លូវភេទលើកុមារ<br>- គ្រប់គ្រង ស្វែងរក និងប៉ាន់ប្រមាណគ្រួសារងាយរងគ្រោះ<br>- គ្រប់គ្រង តាមដាន និងបិទករណីកុមាររងគ្រោះដែលបានសមាហរណកម្មទៅសហគមន៍<br>- ផ្សព្វផ្សាយគោលនយោបាយ និងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងរំលោភបំពានផ្លូវភេទលើកុមារ |
| ២ ការងារជនរងគ្រោះនិងងាយរងគ្រោះ | ការគ្រប់គ្រង និងការកំណត់អត្តសញ្ញាណជនរងគ្រោះនិងងាយរងគ្រោះ<br>- ប្រមូល និងគ្រប់គ្រងទិន្នន័យជនរងគ្រោះដោយគ្រោះមហន្តរាយ ជនក្រីក្រ និងគ្រួសារនៅសហគមន៍<br>- ប្រមូល និងគ្រប់គ្រងទិន្នន័យជនអនាថា<br>- គ្រប់គ្រង កំណត់អត្តសញ្ញាណ និងតាមដានជនផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍<br>- គ្រប់គ្រង កំណត់អត្តសញ្ញាណ និងតាមដានស្ត្រីមានផ្ទៃពោះក្រីក្រ និងកុមារក្រោម២ឆ្នាំស្ថិតនៅគ្រួសារក្រីក្រ |
| ៣ ការងារជនពិការ | ការគ្រប់គ្រងជនពិការ និងការផ្តល់ព័ត៌មានសេវាស្តារលទ្ធភាពពលកម្ម<br>- គ្រប់គ្រង និងចងក្រងទិន្នន័យជនពិការក្រីក្រ ជនពិការភាពទូទៅ ស្ត្រីពិការ កុមារពិការ និងកីឡាករជនពិការ<br>- គ្រប់គ្រង និងផ្តល់ព័ត៌មានអំពីសេវាកម្មសម្រាប់ជនមានពិការភាព<br>- គ្រប់គ្រង និងផ្តល់ព័ត៌មានការស្នើសុំផ្តល់សេវាស្តារលទ្ធភាពកម្មដល់ជនពិការ |

[26] សៀវភៅ "ការគ្រប់គ្រងរដ្ឋបាល ក្រុង ស្រុក ខណ្ឌ" ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២០ អនុម័តដោយសម្តេចក្រហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

| មុខងារ | មុខងាររង ឬសកម្មភាព |
|---|---|
| ៤ ការងារបេឡាជាតិ អតីតយុទ្ធជន និងបេឡាជាតិសន្តិសុខសង្គម | ការគ្រប់គ្រង និងកំណត់អត្តសញ្ញាណលើមុខសញ្ញាបេឡាជាតិអតីតយុទ្ធជន និងបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល<br>- គ្រប់គ្រងទិន្នន័យនិវត្តជន ( និវត្តជនចាស់ ថ្មី ផ្លាស់ប្តូរទីលំនៅ ទទួលមរណភាព ឬនិវត្តជនត្រូវបានលុបឈ្មោះ )<br>- គ្រប់គ្រងស្ថិត តាមដាន ត្រួតពិនិត្យស្ថានភាពអតីតយុទ្ធជនគ្រប់ប្រភេទ និងគ្រួសារ<br>- គ្រប់គ្រង និងស្នើសុំផ្ទេរលំនៅដ្ឋានរបស់អតីតយុទ្ធជននិងគ្រួសារ<br>- គ្រប់គ្រង និងស្នើសុំលុបឈ្មោះអតីតយុទ្ធជនដែលទទួលមរណភាព<br>- គ្រប់គ្រងទិន្នន័យជនបាត់បង់សម្បទាវិជ្ជាជីវៈ<br>- គ្រប់គ្រងអ្នកនៅក្នុងបន្ទុករបស់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ឬអ្នកនៅក្នុងបន្ទុករបស់សពនិវត្តជន និងសពជនបាត់បង់សម្បទាវិជ្ជាជីវៈ មានប្រពន្ធ កូន<br>- គ្រប់គ្រង និងស្នើសុំលុបឈ្មោះអតីតយុទ្ធជន និងគ្រួសារដែលផុតសុពលភាពទទួលរបបសន្តិសុខសង្គម<br>- គ្រប់គ្រង និងស្នើសុំលុបឈ្មោះអតីតយុទ្ធជន និងគ្រួសារដែលមិនបានបើកប្រាក់របបសន្តិសុខសង្គមរបស់ខ្លួនដោយគ្មានមូលហេតុ<br>- គ្រប់គ្រង និងស្នើសុំបញ្ចូល ឬលុបអ្នកក្នុងបន្ទុកអតីតយុទ្ធជន និងគ្រួសារដើម្បីបានទទួលរបបឧបត្ថម្ភប្រចាំខែ<br>- គ្រប់គ្រង និងទទួលសំណើអតីតយុទ្ធជន និងគ្រួសារដែលបានបោះបង់របបសន្តិសុខសង្គម<br>- សហការជាមួយសមាគមអតីតយុទ្ធជនកម្ពុជាក្នុងការបញ្ចូល ឬលុបអតីតយុទ្ធជនពីសមាជិកសមាគមអតីតយុទ្ធជនកម្ពុជា<br>- គ្រប់គ្រងព័ត៌មានអតីតយុទ្ធជនសម្រាប់ទទួលសេវាសុខភាព ឬសេវានានាពីរដ្ឋ<br>- សហការជាមួយធនាគារដៃគូក្នុងការគ្រប់គ្រង បើកផ្តល់របបសន្តិសុខសង្គម |
| ៥ ការងារអតីតយុទ្ធជន និងគ្រួសារ | ការគ្រប់គ្រង និងកំណត់អត្តសញ្ញាណអតីតយុទ្ធជន និងគ្រួសារ<br>- ប្រមូលទិន្នន័យពីស្ថានភាព និងតម្រូវការរបស់អតីតយុទ្ធជន និងគ្រួសារជនពលីមរណៈ<br>- ផ្តល់សេវាឆ្លើយតបនឹងតម្រូវការជាក់ស្តែងរបស់អតីតយុទ្ធជន និងគ្រួសារជនពលីមរណៈ<br>- គ្រប់គ្រងទិន្នន័យអតីតយុទ្ធជន និងគ្រួសារដែលទទួលផ្ទះ |
| ៦ ការងារមណ្ឌលស្តារនីតិសម្បទា | ការគ្រប់គ្រង និងសហការជាមួយមណ្ឌលស្តារនីតិសម្បទាខេត្ត<br>- គ្រប់គ្រងទិន្នន័យអនីតិជនទំនាស់នឹងច្បាប់<br>- គ្រប់គ្រង តាមដានអនីតិជនដែលបានស្តារនីតិសម្បទាដោយសារញៀនគ្រឿងញៀនក្រោយសមាហរណកម្មទៅសហគមន៍ |
| ៧ ការងារសមាគមមនុស្ស | ការគ្រប់គ្រងទិន្នន័យមនុស្សវ័យចាស់ក្នុងសហគមន៍ |

| មុខងារ | មុខងាររង ឬសកម្មភាព |
|---|---|
| វ័យចាស់ | - គ្រប់គ្រង និងស្រង់ទិន្នន័យ សមាជិក សមាជិកាសមាគមមនុស្សវ័យចាស់<br>- ផ្សព្វផ្សាយលក្ខន្តិកៈសមាគមមនុស្សវ័យចាស់<br>- តាមដានត្រួតពិនិត្យ និងវាយតម្លៃការប្រើប្រាស់ថវិកាវិភាគទានរបស់សមាគមមនុស្សវ័យចាស់ |
| ៨ ការត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល | ការត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែបរដ្ឋាភិបាល[27]<br>- ធ្វើអធិការកិច្ចលើការអនុវត្តបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួសចំពោះកុមារនៅក្នុងមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល។<br>- ការសម្របសម្រួលដោះស្រាយករណីរំលោភបំពានលើសិទ្ធិកុមារដែលកើតមាននៅក្នុងមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល<br>- គ្រប់គ្រង និងវិភាគទិន្នន័យកុមាររងគ្រោះនិងងាយរងគ្រោះ និងកុមារដែលកំពុងស្ថិតនៅក្នុងការថែទាំជំនួសក្នុងសហគមន៍<br>- ការរៀបចំបញ្ជីបច្ចុប្បន្នភាព នៃអង្គការមិនមែនរដ្ឋាភិបាលដែលត្រូវបានអនុញ្ញាតផ្តល់ការថែទាំជំនួសចំពោះកុមារ<br>- ការជម្រុញលើកទឹកចិត្តឱ្យអង្គការមិនមែនរដ្ឋាភិបាលផ្តល់សេវាថែទាំកុមាររងគ្រោះនិងងាយរងគ្រោះ<br>- ការពិនិត្យនិងសម្រេចលើសំណុំឯកសារដែលសុំ ឬបញ្ចូលកុមាររងគ្រោះនិងងាយរងគ្រោះសម្រាប់មណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល<br>- ការតាមដានការបញ្ជូនករណីកុមារ និងការផ្តល់សេវាសុខុមាលភាពកុមារនៅក្នុងមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល។ |

## ២.៤. យន្តការសម្របសម្រួលកិច្ចការពារកុមារ

### ២.៤.១.ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ(ក.ជ.ក) នៅឆ្នាំ១៩៩៥[28] ហើយនៅចុងឆ្នាំ២០០៩បានកែសម្រួលរចនាសម្ព័ន្ធ[29] និងសមាសភាពជាបន្តបន្ទាប់[30]។ ក.ជ.ក មានភារកិច្ច សម្របសម្រួល និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលសម្រាប់ការងារពិគ្រោះយោបល់ សម្របសម្រួលសកម្មភាពទាំងឡាយដែលពាក់ព័ន្ធនឹងបញ្ហាកុមារ ពិនិត្យតាមដាននិងវាយតម្លៃលើការអនុវត្តអនុសញ្ញា ស្តីពីសិទ្ធិកុមារ ចូលរួមពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹង កុមារ និងផ្តល់អនុសាសន៍ស្របនឹងអនុសញ្ញានិងបទដ្ឋានអន្តរជាតិផ្សេងៗស្តីពីកុមារ និងដឹកនាំអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។[31]

---

[27] មាត្រា ៦ នៃអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៧ បានប្រគល់មុខងារ "ការត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល" ទៅឱ្យរដ្ឋបាលរាជធានី ក្រុង ស្រុក។ រដ្ឋបាលរាជធានីធ្វើប្រតិភូកម្មមុខងារឱ្យរដ្ឋបាលខណ្ឌ។

[28] អនុក្រឹត្យលេខ៨៣ អនក្រ.បក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន ក.ជ.ក.ក

[29] ព្រះរាជក្រឹត្យលេខនស/រកត/១២០៩/១២០១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

[30] អនុក្រឹត្យលេខ ៣៨២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៤ ស្តីពីការតែងសមាសភាព ក.ជ.ក និងអនុក្រឹត្យលេខ ៤១៦ អនក្រ.បក ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៩ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។

[31] មាត្រា៨ នៃព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារឆ្នាំ២០០៩

### ២.៤.២.អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

អគ្គលេខាធិការដ្ឋាន ក.ជ.ក[32] ជាសេនាធិ ក.ជ.ក មាន៖ ១.ផ្នែករដ្ឋបាលផែនការ និងហិរញ្ញវត្ថុ ២.ផ្នែកការពារកុមារនិងពិនិត្យតាម ដាន និង៣.ផ្នែកអប់រំផ្សព្វផ្សាយ និងអភិវឌ្ឍធនធានមនុស្ស មានភារកិច្ចរៀបចំ និងអនុវត្តផែនការ សម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារនានា ពិនិត្យតាមដានស្ថានភាពកុមារ ជំរុញការផ្សព្វផ្សាយខ្លឹមសារអនុសញ្ញាស្តីពីសិទ្ធិកុមារ សិក្សាស្រាវជ្រាវច្បាប់ជាតិ អន្តរជាតិ និងលិខិតបទដ្ឋានគតិយុត្ត សហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ តំណាងកុមារ អង្គការមិនមែន រដ្ឋាភិបាលក្នុងស្រុក និងបរទេសព្រមទាំងដៃគូអភិវឌ្ឍ។

### ២.៤.៣.ក្រុមការងារដើម្បីកុមារនៅតាមក្រសួង ស្ថាប័ន

ក្រុមការងារដើម្បីកុមារនៅតាមក្រសួង ស្ថាប័ន[33]ដឹកនាំដោយរដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការជាប្រធានអគ្គនាយក១រូបជាអនុប្រធាន និងសមាជិកជាប្រធាន ឬអនុប្រធាននាយកដ្ឋានពាក់ព័ន្ធដើរតួនាទីជាយន្តការសម្របសម្រួល និងផ្តល់យោបល់ជូនក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារលើការងារពិគ្រោះយោបល់ និងពិនិត្យតាមដានវាយតម្លៃលើការអនុវត្តសិទ្ធិកុមារ ផ្សព្វផ្សាយច្បាប់ អនុសញ្ញាស្តីពីសិទ្ធិកុមារ គោលនយោបាយ និងលិខិតដ្ឋានគតិយុត្តនានារបស់រាជរដ្ឋាភិបាល និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។ រៀបចំផែនការ កម្មវិធីនិងសកម្មភាពផ្សេងៗដើម្បីឧត្តមប្រយោជន៍របស់កុមារ និងបញ្ជ្រាបការងារកុមារទៅក្នុងកម្មវិធីរបស់ក្រសួងស្ថាប័ន និងធ្វើទំនាក់ទំនងជាមួយអង្គការ មិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេសដែលមានគម្រោងការងារពាក់ព័ន្ធនឹងកុមារនៅក្នុងក្រសួងស្ថាប័ន ស្វែងរកជំនួយឧបត្ថម្ភ និងផ្លាស់ប្តូរព័ត៌មាន បទពិសោធន៍ ទស្សនៈរីកចម្រើនដែលទាក់ទងនឹងគោលដៅរួមក្នុងការកែសម្ពស្ថានភាពកុមារ។ រៀបចំទិន្នន័យស្តីពីស្ថានភាពកុមារ និងចាត់ចែងអនុវត្តរាល់គោលការណ៍ និងផែនការសកម្មភាពរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។

### ២.៤.៤.ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមាររាជធានី ខេត្ត

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមាររាជធានីខេត្ត[34] ដែលមានអភិបាលរាជធានី ខេត្តជាប្រធានកិត្តិយស អភិបាលរងរាជធានីខេត្តជាប្រធាន អនុប្រធាន សមាជិក មើលតារាងទី៦។ ប្រការ ៩ នៃសេចក្តីសម្រេចបញ្ជាក់ថា ក.ជ.ក រាជធានីខេត្តមានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិជាកញ្ចប់ដោយឡែក ក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់មន្ទីរ ស.អ.យ រាជធានីខេត្ត និងមានសិទ្ធិទទួលនិងគ្រប់គ្រងមូលនិធិមនុស្សធម៌ ដែលបានមកពីប្រភពស្របច្បាប់ផ្សេងៗ សម្រាប់បំពេញការងាររបស់ខ្លួន។

តារាងទី៦៖សមាសភាពក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ រាជធានី ខេត្ត

| ល.រ | សមាសភាព | តួនាទី |
|---|---|---|
| ១ | អភិបាលរាជធានី ខេត្ត | ប្រធានកិត្តិយស |
| ២ | អភិបាលរង រាជធានី ខេត្ត | ប្រធាន |
| ៣ | ប្រធានមន្ទីរ សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធានទី១ |
| ៤ | ប្រធានមន្ទីរ កិច្ចការនារី | អនុប្រធាន |
| ៥ | ប្រធានមន្ទីរ សុខាភិបាល | អនុប្រធាន |

[32] អនុក្រឹត្យលេខ០២ ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន ក.ជ.ក

[33] សេចក្តីសម្រេចលេខ១២៧ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការក្រុមការងារដើម្បីកុមារនៅតាមក្រសួងស្ថាប័ន

[34] សេចក្តីសម្រេចលេខ ២១៦ ក.ជ.ក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ ២០១០ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ រាជធានី ខេត្ត

| ល.រ | សមាសភាព | តួនាទី |
|---|---|---|
| ៦ | ប្រធានមន្ទីរ អប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៧ | ប្រធានមន្ទីរ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៨ | ស្នងការ នៃស្នងការដ្ឋាននគរបាល រាជធានី ខេត្ត | អនុប្រធាន |
| ៩ | អនុប្រធានមន្ទីរ សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិកអចិន្ត្រៃយ៍ |
| ១០ | មេបញ្ជាការតំបន់ប្រតិបត្តិការសឹករង រាជធានី ខេត្ត | សមាជិក |
| ១១ | មេបញ្ជាការកងរាជអាវុធហត្ថ រាជធានី ខេត្ត | សមាជិក |
| ១២ | នាយករដ្ឋបាលសាលា រាជធានី ខេត្ត | សមាជិក |
| ១៣ | អនុប្រធានមន្ទីរ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៤ | អនុប្រធានមន្ទីរ ពាណិជ្ជកម្ម | សមាជិក |
| ១៥ | អនុប្រធានមន្ទីរ ផែនការ | សមាជិក |
| ១៦ | អនុប្រធានមន្ទីរ អភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៧ | អនុប្រធានមន្ទីរ វប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១៨ | អនុប្រធានមន្ទីរ សាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៩ | អនុប្រធានមន្ទីរ បរិស្ថាន | សមាជិក |
| ២០ | អនុប្រធានមន្ទីរ ប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ២១ | អនុប្រធានមន្ទីរ ឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ២២ | អនុប្រធានមន្ទីរ ទេសចរណ៍ | សមាជិក |
| ២៣ | អនុប្រធានមន្ទីរ ព័ត៌មាន | សមាជិក |
| ២៤ | អនុប្រធានមន្ទីរ ធម្មការ និងសាសនា | សមាជិក |
| ២៥ | អនុប្រធានមន្ទីរ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ២៦ | តំណាងសាខាកាកបាទក្រហម រាជធានី ខេត្ត | សមាជិក |

ក.ជ.ក រាជធានី ខេត្ត ជាយន្តការសម្របសម្រួល និងផ្តល់យោបល់ជូន ក.ជ.ក លើការងារសម្របសម្រួលពិនិត្យតាមដានវាយតម្លៃ ផ្សព្វផ្សាយច្បាប់ អនុសញ្ញាស្តីពីសិទ្ធិកុមារ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានារបស់រាជរដ្ឋាភិបាល និង ក.ជ.ក បំផុសចលនាគាំទ្រ ការអនុវត្តសិទ្ធិកុមារឱ្យមានប្រសិទ្ធភាព។ រៀបចំផែនការ កម្មវិធីដើម្បីឧត្តមប្រយោជន៍របស់កុមារ និងធ្វើទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេសដែលមានគម្រោងការងារពាក់ព័ន្ធនឹងកុមារ ដើម្បីស្វែងរកជំនួយឧបត្ថម្ភ និងផ្លាស់ប្តូរព័ត៌មាន បទពិសោធន៍ ទស្សនៈរីកចម្រើនដែលទាក់ទងនឹងគោលដៅរួមក្នុងការកែលម្អស្ថានភាពកុមារ។ រៀបចំទិន្នន័យស្តីពីស្ថានភាពកុមារ ធ្វើរបាយការណ៍ផ្ទៀងផ្ទាត់នឹងគោលដៅសូចនាករកិច្ចការពារកុមារ និងចាត់ចែងអនុវត្តរាល់គោលការណ៍ ផែនការសកម្មភាពរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។[35]

[35] ប្រការ ៣ នៃសេចក្តីសម្រេចលេខ លេខ ២១៦ ក.ជ.ក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ ២០១០ ស្តីពីការបង្កើត ក.ជ.ក រាជធានី ខេត្ត

### ២.៤.៥.គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររាជធានី ខេត្ត

ក្រុមប្រឹក្សារាជធានី ខេត្ត បានបង្កើត គ.ក.ស.ក ដែលមានសិទ្ធិនិងមានភារកិច្ច[36] ផ្តល់យោបល់ និងលើកអនុសាសន៍ជូនក្រុមប្រឹក្សារាជធានីខេត្ត គណៈអភិបាលរាជធានីខេត្ត អភិបាលរាជធានីខេត្ត និងគណៈកម្មាធិការដទៃទៀតរបស់ក្រុមប្រឹក្សារាជធានីខេត្ត លើបញ្ហាពាក់ព័ន្ធនឹងសមភាពយេនឌ័រ បញ្ហាស្ត្រី យុវវ័យ និងកុមារដែលស្ថិតនៅក្នុងអំណាចមុខងារនិងភារកិច្ចរបស់ក្រុមប្រឹក្សារាជធានីខេត្ត។

តារាងទី៧៖សមាសភាពគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមាររាជធានី ខេត្ត

| ល.រ | សមាសភាព | តួនាទី |
|---|---|---|
| ១ | សមាជិកក្រុមប្រឹក្សាជាស្ត្រីជ្រើសរើសដោយក្រុមប្រឹក្សា | ប្រធាន |
| ២ | សមាជិកក្រុមប្រឹក្សាជ្រើសរើសដោយក្រុមប្រឹក្សា | អនុប្រធាន |
| ៣ | អភិបាលរងជាស្ត្រី០១រូប | អនុប្រធាន |
| ៤ | ប្រធាន ឬអនុប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធាន |
| ៥ | ប្រធាន ឬអនុប្រធានមន្ទីរកិច្ចការនារី | អនុប្រធានអចិន្ត្រៃយ៍ |
| ៦ | នាយករងរដ្ឋបាល០១រូប | សមាជិក |
| ៧ | ប្រធាន ឬអនុប្រធានមន្ទីរផែនការ | សមាជិក |
| ៨ | ប្រធាន ឬអនុប្រធានមន្ទីរសុខាភិបាល | សមាជិក |
| ៩ | ប្រធាន ឬអនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១០ | ប្រធាន ឬអនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា | សមាជិក |
| ១១ | ប្រធាន ឬអនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១២ | ប្រធាន ឬអនុប្រធានមន្ទីរកសិកម្ម | សមាជិក |
| ១៣ | ស្នងការ ឬតំណាងស្នងការដ្ឋាននគរបាល | សមាជិក |
| ១៤ | នាយក ឬនាយករងទីចាត់ការអន្តរវិស័យ | សមាជិក |
| ១៥ | ប្រធាន ឬអនុប្រធានសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ | សមាជិក |
| ១៦ | តំណាងពីស្ថាប័ន ឬអង្គភាពផ្សេងៗទៀតតាមការចាំបាច់ | សមាជិក |

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ មានមុខងារចម្បងដូចជា៖ ចូលរួមក្នុង ការកសាងចក្ខុវិស័យជាយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា និងដើម្បីធ្វើឱ្យសម្រេចបាននូវសមភាពយេនឌ័រ និងការផ្តល់សេវាផ្សេងៗដែលពាក់ព័ន្ធនឹងសមភាពយេនឌ័រ បញ្ហាស្ត្រី យុវវ័យ និងកុមារ។ ប្រមូល និងវិភាគព័ត៌មាននិងទិន្នន័យដែលទាក់ទងនឹងយេនឌ័រ និងតម្រូវការស្ត្រី យុវវ័យ និងកុមារ ដើម្បីដាក់បញ្ចូលព័ត៌មានទាំងនេះ ទៅក្នុងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំរបស់ក្រុមប្រឹក្សារាជធានីខេត្ត។ ស្វែងរកការគាំទ្រពីក្រុមប្រឹក្សា គណៈអភិបាល និងគណៈកម្មាធិការផ្សេងទៀតនៃក្រុមប្រឹក្សារាជធានីខេត្ត ដើម្បីលើកផែនការសកម្មភាពសម្រាប់ដោះស្រាយបញ្ហាសមភាពយេនឌ័រ បញ្ហាស្ត្រី យុវវ័យ និងកុមារនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានីខេត្ត។ សហការ និងផ្តល់ការគាំទ្រដល់ គ.ក.ស.ក ប្រភេទផ្សេងទៀតក្នុងការដោះស្រាយបញ្ហា ឬសំណូមពរឬសំណើនានា ដែលគណៈកម្មាធិការរបស់ក្រុមប្រឹក្សាប្រភេទផ្សេងនោះមិនអាចដោះស្រាយបានក្នុងការអនុវត្តមុខងាររបស់ខ្លួន។ លើកសំណើ និងផ្តល់យោបល់ជូនក្រុមប្រឹក្សាខេត្ត ឬគណៈអភិបាលខេត្តអំពីវិធានការ

[36] មាត្រា ១២៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ២០០៨

សមស្របនានា ដើម្បីជំរុញឱ្យមានការចូលរួមពីសមត្ថកិច្ចពាក់ព័ន្ធ និងប្រជាពលរដ្ឋក្នុងការដោះស្រាយ និងទប់ស្កាត់នូវបញ្ហាដែលកើតមានឡើងពាក់ព័ន្ធនឹងស្ត្រី យុវវ័យនិងកុមារ។ ជំរុញការលើកកម្ពស់ការយល់ដឹងអំពីច្បាប់ និងគោលនយោបាយទាក់ទងនឹងសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារដល់សហគមន៍នានានៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត។ ជំរុញឱ្យមានការប្រមូលព័ត៌មានរបស់សហគមន៍អំពីបញ្ហាដែលបានកើតមានជាប្រចាំពាក់ព័ន្ធនឹងសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារនិងមានវិធានការដើម្បីឆ្លើយតប។ ពិនិត្យមើលលើការអនុវត្តគោលនយោបាយសមភាពយេនឌ័រ និងស្ថានភាពរបស់ស្ត្រី យុវវ័យ និងកុមារ ជាពិសេសដើម្បីកំណត់រកគម្លាតផ្សេងៗនៅក្នុងការទទួលបានសេវានានា និងដើម្បីលើកអនុសាសន៍ក្នុងការដោះស្រាយបញ្ហាទាំងនេះ។ រាយការណ៍ជូនក្រុមប្រឹក្សាលើបញ្ហាដែលទាក់ទងនឹងសមភាពយេនឌ័រ ការបង្កើនសមត្ថភាពដល់ស្ត្រី និងបញ្ហារបស់យុវវ័យ និងកុមារ។ គាំទ្រគ្រប់កិច្ចខិតខំប្រឹងប្រែងដើម្បីកៀរគរមូលនិធិសម្រាប់ការងារសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារ។

### ២.៤.៦.គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្រុង ស្រុក ខណ្ឌ

ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ បានបង្កើត គ.ក.ស.ក ដែលមានសិទ្ធិ និងមានភារកិច្ចផ្តល់យោបល់ និងលើកអនុសាសន៍ជូនក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ គណៈអភិបាលស្រុក ក្រុង ខណ្ឌ អភិបាលក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការដទៃទៀតរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ លើបញ្ហាពាក់ព័ន្ធនឹងសមភាពយេនឌ័រ បញ្ហាស្ត្រី យុវវ័យ និងកុមារដែលស្ថិតនៅក្នុងអំណាច មុខងារ និងភារកិច្ចរបស់ក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ។ ចំពោះមុខងារចម្បងៗមិនខុសពី គ.ក.ស.ក រាជធានី ខេត្តឡើយ គឺគ្រាន់តែមានវិសាលភាពក្នុងដែនសមត្ថកិច្ចក្រុង ស្រុក ខណ្ឌ តែប៉ុណ្ណោះ។

តារាងទី៨៖សមាសភាពគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្រុង ស្រុក ខណ្ឌ

| ល.រ | សមាសភាព | តួនាទី |
|---|---|---|
| ១ | សមាជិកក្រុមប្រឹក្សាជាស្ត្រីជ្រើសរើសដោយក្រុមប្រឹក្សា | ប្រធាន |
| ២ | សមាជិកក្រុមប្រឹក្សាជ្រើសរើសដោយក្រុមប្រឹក្សា | អនុប្រធាន |
| ៣ | អភិបាលរងជាស្ត្រី០១រូប | អនុប្រធាន |
| ៤ | ប្រធាន ឬអនុប្រធានការិយាល័យ ស.អ.យ | អនុប្រធាន |
| ៥ | ប្រធាន ឬអនុប្រធានការិយាល័យកិច្ចការនារី | អនុប្រធានអចិន្ត្រៃយ៍ |
| ៦ | នាយករងរដ្ឋបាល០១រូប | សមាជិក |
| ៧ | ប្រធាន ឬអនុប្រធានការិយាល័យផែនការ | សមាជិក |
| ៨ | ប្រធាន ឬអនុប្រធានការិយាល័យសុខាភិបាល | សមាជិក |
| ៩ | ប្រធាន ឬអនុប្រធានការិយាល័យអភិវឌ្ឍន៍ជនបទ(បើមាន) | សមាជិក |
| ១០ | ប្រធាន ឬអនុប្រធានការិយាល័យអប់រំ យុវជន និងកីឡា | សមាជិក |
| ១១ | ប្រធាន ឬអនុប្រធានការិយាល័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ(បើមាន) | សមាជិក |
| ១២ | ប្រធាន ឬអនុការិយាល័យកសិកម្ម | សមាជិក |
| ១៣ | អធិការ ឬតំណាងអធិការដ្ឋាននគរបាល | សមាជិក |
| ១៤ | ប្រធាន ឬអនុប្រធានការិយាល័យពាក់ព័ន្ធនៃសាលាក្រុង | សមាជិក |
| ១៤ | អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារសង្កាត់ចំណុះ | សមាជិក |
| ១៥ | តំណាងពីស្ថាប័ន ឬអង្គភាពផ្សេងៗទៀតតាមការចាំបាច់ | សមាជិក |

**២.៤.៧.គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់**

នៅឆ្នាំ២០០៧គណៈកម្មាធិការសម្រាប់ការអភិវឌ្ឍបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គ.ជ.អ.ប បានចេញសេចក្តីណែនាំលេខ០៨២ ស.ណ.ន/គ.ជ.វ.វ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារនៅគ្រប់ឃុំ សង្កាត់ (គ.ក.ន.ក)។ ឆ្លងកាត់ការអនុវត្តអស់រយៈពេល១៣ឆ្នាំកន្លងមកទើបក្រសួងមហាផ្ទៃបានចេញប្រកាស ៣៨៤០ ប្រក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់ (គ.ក.ន.ក) ដើម្បីជំនួសសេចក្តីណែនាំលេខ០៨២ ស.ណ.ន/គ.ជ.វ.វ។ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ "គ.ក.ន.ក" មានសមាសភាពដូចខាងក្រោម ៖

តារាងទី៩៖ សមាសភាពគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់

| ល.រ | សមាសភាព | តួនាទី |
|---|---|---|
| ១ | មេឃុំ ចៅសង្កាត់ | ប្រធាន |
| ២ | ជំទប់ទី២ ឬចៅសង្កាត់រងទី២ | អនុប្រធាន |
| ៣ | **អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់** | អនុប្រធានអចិន្ត្រៃយ៍ |
| ៤ | ស្មៀនឃុំ សង្កាត់ | សមាជិក |
| ៥ | នាយប៉ុស្តិ៍នគរបាលឃុំ សង្កាត់១រូប | សមាជិក |
| ៦ | នាយក ឬនាយិកាសាលាបឋមសិក្សានៅក្នុងឃុំ សង្កាត់ ០១រូប | សមាជិក |
| ៧ | នាយក ឬនាយិកាសាលាមេត្តេយ្យសិក្សានៅក្នុងឃុំ សង្កាត់ ០១រូប | សមាជិក |
| ៨ | ប្រធានមណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាព | សមាជិក |
| ៩ | មេភូមិ ឬអនុប្រធានប្រធានភូមិទាំងអស់នៅក្នុងឃុំ សង្កាត់ | សមាជិក |
| ១០ | តំណាងក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជន ឃុំ សង្កាត់០១ រូប | សមាជិក |
| ១១ | តំណាងសមាគមមនុស្សចាស់ ០១ រូប | សមាជិក |
| ១២ | តំណាងជនមានពិការភាព ០១រូប | សមាជិក |
| ១៣ | **ជំនួយការសេវាសង្គមឃុំ សង្កាត់** | ជាលេខាធិការ |

គ.ក.ន.ក មានតួនាទីផ្តល់យោបល់ និងជួយរដ្ឋបាលឃុំ សង្កាត់ក្នុងការសម្របសម្រួល និងការអនុវត្តសកម្មភាពសេវាសង្គមទាំងអស់នៅក្នុងឃុំ សង្កាត់ ដើម្បីធានាថា ស្ត្រី កុមារ យុវជន មនុស្សចាស់ ជនក្រីក្រ ជនមានពិការភាព ជនជាតិដើមភាគតិច និងជនងាយរងគ្រោះផ្សេងទៀត ទទួលបានព័ត៌មាន ចំណេះដឹង និងសេវានានាប្រកបដោយសមធម៌សង្គម និងបរិយាប័ន្ន ព្រមទាំងមានជីវភាពរស់នៅប្រកបដោយសុវត្ថិភាព សុខដុមរមនា និងសេចក្តីថ្លៃថ្នូរ។ គ.ក.ន.ក មានភារកិច្ចដូចខាងក្រោម[37]៖

- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំសម្រាប់អនុវត្តសកម្មភាពសេវាសង្គមនានា ដោយផ្អែកតាមកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ហើយដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ពិនិត្យ និងអនុម័ត ដើម្បីដាក់បញ្ចូលទៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់។

[37] ប្រការ ៧ នៃប្រកាស ៣៨៤០ ប្រក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់

- សហការ និងសម្របសម្រួលការអនុវត្តសកម្មភាពសេវាសង្គមនានានៅក្នុងឃុំ សង្កាត់ ទៅតាមផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំសម្រាប់អនុវត្តសកម្មភាពសេវាសង្គម។
- តាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តសកម្មភាពសេវាសង្គមនានានៅក្នុងឃុំ សង្កាត់របស់ខ្លួន។
- ប្រមូល និងវិភាគទិន្នន័យតាមរយៈដំណើរការរៀបចំ និងធ្វើបច្ចុប្បន្នភាពផែនទីសេវាសង្គម និងឬតាមរយៈការប្រើប្រាស់ឧបករណ៍វិភាគសេវាសង្គមផ្សេងៗទៀត ដើម្បីកំណត់បញ្ហា តម្រូវការ និងដំណោះស្រាយផ្នែកសេវាសង្គម សម្រាប់ដាក់បញ្ចូលទៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។
- ពិនិត្យ និងផ្តល់យោបល់ទៅលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ រួមទាំងសេចក្តីព្រាងវិសោធនកម្មផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ដើម្បីធានាថា បញ្ហា តម្រូវការ ដំណោះស្រាយ និងគម្រោងឬសកម្មភាពផ្នែកសេវាសង្គម ត្រូវបានដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។
- ពិនិត្យ និងផ្តល់យោបល់ទៅលើសេចក្តីព្រាងគម្រោងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់ និងសេចក្តីព្រាងកែសម្រួលគម្រោងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់ ដើម្បីធានាថា សកម្មភាពឬគម្រោងអាទិភាពនានាផ្នែកសេវាសង្គម ត្រូវបានវិភាជថវិកាសម្រាប់អនុវត្តប្រកបដោយសមធម៌សង្គម និងបរិយាប័ន្ន។
- ផ្តល់ប្រឹក្សាយោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់អំពីកិច្ចការសេវាសង្គមនានានៅក្នុងឃុំ សង្កាត់ប្រកបដោយសមធម៌សង្គម និងបរិយាប័ន្ន។
- គាំទ្រ និងលើកទឹកចិត្តដល់ស្ត្រី កុមារ យុវជន មនុស្សចាស់ ជនក្រីក្រ ជនមានពិការភាព ជនជាតិដើមភាគតិច និងជនងាយរងគ្រោះផ្សេងៗទៀត ឱ្យចូលរួមនៅក្នុងដំណើរការធ្វើសេចក្តីសម្រេច និងដំណើរការអនុវត្តសេចក្តីសម្រេចរបស់រដ្ឋបាលឃុំ សង្កាត់ ដើម្បីអភិវឌ្ឍមូលដ្ឋានប្រកបដោយសមធម៌សង្គម និងបរិយាប័ន្ន។
- ចលនា និងជំរុញលើកទឹកចិត្តដល់ប្រជាពលរដ្ឋ ជាពិសេសស្ត្រី កុមារ យុវជន មនុស្សចាស់ ជនក្រីក្រ ជនមានពិការភាព ជនជាតិដើមភាគតិច និងជនងាយរងគ្រោះផ្សេងៗទៀត ឱ្យទៅទទួលយកសេវាសង្គមនានា ព្រមទាំងចូលរួមបង្ការ ទប់ស្កាត់ និងដោះស្រាយបញ្ហាសង្គមនានាដែលកើតមានឡើងនៅក្នុងឃុំ សង្កាត់។
- ចលនាអង្គភាពរដ្ឋ អង្គការសង្គមស៊ីវិល និងផ្នែកឯកជន ឱ្យចូលរួមចំណែកយ៉ាងសកម្មក្នុងការរៀបចំស្ថាប័នរបស់ខ្លួន ទាំងផ្នែករឹងនិងផ្នែកទន់ដើម្បីបង្កលក្ខណៈងាយស្រួលដល់ស្ត្រី កុមារ យុវជន មនុស្សចាស់ ជនក្រីក្រ ជនមានពិការភាព ជនជាតិដើមភាគតិច និងជនងាយរងគ្រោះផ្សេងៗទៀត ក្នុងការទទួលបាននូវព័ត៌មាន ចំណេះដឹង និងសេវានានាប្រកបដោយបរិយាប័ន្ន សមធម៌សង្គម និងសេចក្តីថ្លៃថ្នូរ។
- អប់រំផ្សព្វផ្សាយបង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋ ជាពិសេសស្ត្រី កុមារ យុវជន មនុស្សចាស់ ជនក្រីក្រ ជនមានពិការភាព ជនជាតិដើមភាគតិច និងជនងាយរងគ្រោះផ្សេងៗទៀត អំពីច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងកិច្ចការសេវាសង្គម និងកិច្ចការអភិវឌ្ឍន៍មូលដ្ឋាន។
- សហការជាមួយអង្គភាព ឬអ្នកផ្តល់សេវាសង្គម ភ្នាក់ងារសង្គមកិច្ច អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍នានាក្នុងការអនុវត្តសកម្មភាពសេវាសង្គមនានានៅក្នុងឃុំ សង្កាត់របស់ខ្លួន។
- កៀរគរធនធាននានាពីស្ថាប័នរដ្ឋ អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ ផ្នែកឯកជន និងសប្បុរសជននានា ដើម្បីគាំទ្រដល់ការអនុវត្តសកម្មភាពសេវាសង្គមនានា។
- សហការជាមួយអង្គភាព ឬភ្នាក់ងារមានសមត្ថកិច្ចនានាក្នុងការទប់ស្កាត់ និងការធ្វើអន្តរាគមន៍ចំពោះករណីអំពើហិង្សា ការរំលោភបំពាន ការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចពលកម្មស្ត្រី

និងកុមារ ការចរាចរគ្រឿងញៀន ការប្រើប្រាស់គ្រឿងញៀន និងសកម្មភាពអសកម្មផ្នែកសេវាសង្គមផ្សេងៗទៀត នៅក្នុងឃុំ សង្កាត់។

- តាមដាន និងរាយការណ៍ជូនកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់អំពីស្ថានភាព បញ្ហាប្រឈម និងតម្រូវការរបស់ស្ត្រី កុមារ យុវជន មនុស្សចាស់ ជនក្រីក្រ ជនមានពិការភាព ជនជាតិដើមភាគតិច និងជនងាយរងគ្រោះផ្សេងៗទៀត ដើម្បីធានាដល់ការទទួលបាននូវការឆ្លើយតប និងកិច្ចអន្តរាគមន៍ទាន់ពេលវេលា។
- រៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃការអនុវត្តសកម្មភាពសេវាសង្គមទៅតាមការកំណត់ ហើយដាក់ជូនមេឃុំ ចៅសង្កាត់ ដើម្បីដាក់បញ្ចូលទៅក្នុងរបាយការណ៍ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលឃុំ សង្កាត់។

បន្ថែមពីភារកិច្ចខាងលើនេះ គ.ក.ន.ក មានសកម្មភាពសេវាសង្គមសំខាន់ៗរួមមាន[38]៖

**ក) ការងារសុខភាពមាតា ទារក អាហារូបត្ថម្ភ**

- ស្រង់ស្ថិតិស្ត្រីមានផ្ទៃពោះ ទារក និងកុមារស្គមស្គាំង កុមារក្រិសក្រិន ព្រមទាំងតាមដានស្ថានភាពសុខភាពស្ត្រីមានផ្ទៃពោះ ទារក និងកុមារទាំងនោះ
- ចលនា និងជំរុញលើកទឹកចិត្តស្ត្រីមានផ្ទៃពោះឱ្យទៅពិនិត្យផ្ទៃពោះជាទៀងទាត់មុនពេលសម្រាល ធ្វើការសម្រាលកូន និងពិនិត្យសុខភាពក្រោយពេលសម្រាលនៅមូលដ្ឋានសុខាភិបាលសាធារណៈ
- ចលនា និងជំរុញលើកទឹកចិត្តឪពុកម្តាយ ឬអ្នកអាណាព្យាបាល យកកូនទៅទទួលថ្នាំបង្ការ(រួមទាំងជីវជាតិបន្ថែម) ឱ្យបានគ្រប់ចំនួន និងតាមពេលវេលាកំណត់
- ផ្តល់ការគាំទ្រថវិកា និងមធ្យោបាយធ្វើដំណើរដល់ស្ត្រីក្រីក្រមានផ្ទៃពោះក្នុងការពិនិត្យផ្ទៃពោះមុនពេលសម្រាល ការសម្រាលកូននិងការពិនិត្យសុខភាពក្រោយពេលសម្រាលនៅមូលដ្ឋានសុខាភិបាលសាធារណៈ
- ផ្តល់ការគាំទ្រដល់កុមារស្គមស្គាំង ឬកុមារខ្វះអាហារូបត្ថម្ភ តាមរយៈការរៀបចំកម្មវិធីអាហារូបត្ថម្ភនានា
- គាំទ្រ និងដោះស្រាយបញ្ហានានាក្នុងការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម២ឆ្នាំ
- ចូលរួមផ្សព្វផ្សាយសារលិខិតរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជានៅក្នុងទិវាជាតិសុខភាពមាតា ទារក និងកុមារ ថ្ងៃទី២១ ខែកុម្ភៈ និងទិវាជាតិអាហារូបត្ថម្ភថ្ងៃទី០៦ ខែវិច្ឆិកា
- ចូលរួមអប់រំផ្សព្វផ្សាយអំពីសារៈសំខាន់នៃការថែទាំសុខភាពមាតានិងទារក ការពិនិត្យផ្ទៃពោះមុនពេលសម្រាល ការពិនិត្យសុខភាពក្រោយពេលសម្រាល ការសម្រាលកូននៅមូលដ្ឋានសុខាភិបាលសាធារណៈ ការចាក់ថ្នាំបង្ការដល់កុមារឱ្យបានគ្រប់ចំនួន ការថែទាំសុខភាពបន្តពូជ និងកម្មវិធីសុខភាពផ្សេងៗទៀត ព្រមទាំងមូលរួមផ្សព្វផ្សាយអំពីព័ត៌មានពាក់ព័ន្ធនឹងបញ្ហាជំងឺឆ្លង បញ្ហាជំងឺមិនឆ្លង និងបញ្ហាសុខភាពសារណៈផ្សេងៗទៀត

**ខ) ការងារអត្តសញ្ញាណកម្ម**

- ចលនា និងជំរុញលើកទឹកចិត្តឪពុកម្តាយទារកទៅចុះសៀវភៅអត្រានុកូលដ្ឋានកំណើត និងសំបុត្រកំណើតឱ្យកូនរបស់ខ្លួននៅក្នុងអំឡុងពេល៣០ថ្ងៃ បន្ទាប់ពីកើត
- ចលនា និងជំរុញលើកទឹកចិត្ត យុវជន យុវនារី ទៅធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរនៅពេលឈានចូលអាយុ១៥ឆ្នាំ
- ចលនា និងជំរុញលើកទឹកចិត្ត បុរស ស្ត្រី យុវជន យុវនារី ដែលបានសម្រេចរៀបអាពាហ៍ពិពាហ៍ទៅចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ និងសំបុត្រអាពាហ៍ពិពាហ៍

[38] ប្រការ ៨ នៃប្រកាស ៣៨៤០ ប្រក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់

- ចលនា និងជំរុញលើកទឹកចិត្តគ្រួសារ ឬសាច់ញាតិរបស់មរណជនទៅចុះសៀវភៅអត្រានុកូលដ្ឋាន មរណភាព និងសំបុត្រមរណភាព ក្នុងរយៈពេលយ៉ាងយូរ១៥ថ្ងៃក្រោយថ្ងៃទទួលមរណភាព
- អប់រំផ្សព្វផ្សាយបង្កើនការយល់ដឹងអំពីកាតព្វកិច្ច និងសារៈសំខាន់នៃការចុះអត្រានុកូលដ្ឋាន និងការធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

គ)ការងារសិក្សាអប់រំ

- ចលនា និងជំរុញលើកទឹកចិត្តឪពុកម្តាយ ឬអ្នកអាណាព្យាបាលឱ្យបញ្ជូនកូនដែលមានអាយុ៣-៥ឆ្នាំចូលរៀនថ្នាក់មតេយ្យសិក្សា និងកូនដែលមានអាយុចាប់ពី៦ឆ្នាំ ឬយ៉ាងទាបបំផុតអាយុ៧០ខែឡើងទៅចូលរៀនថ្នាក់ទី១
- ចូលរួមអប់រំផ្សព្វផ្សាយបង្កើនការយល់ដឹងរបស់ឪពុកម្តាយ និងអ្នកអាណាព្យាបាលអំពីសារៈសំខាន់នៃការសិក្សាអប់រំរបស់ក្មេងស្រី ព្រមទាំងជំរុញលើកទឹកចិត្តដល់ក្មេងស្រីឱ្យបន្តការសិក្សានៅឧត្តមសិក្សា
- សម្របសម្រួលការរៀបចំបង្កើត និងដំណើរការមត្តេយ្យសិក្សាសហគមន៍
- តាមដានបញ្ហាអវត្តមានរបស់សិស្ស និងបញ្ហាផ្នែកអប់រំផ្សេងៗទៀត ព្រមទាំងសម្របសម្រួលដោះស្រាយបញ្ហាទាំងនេះតាមរយៈការជួបពិភាក្សាជាមួយឪពុកម្តាយ ឬអ្នកអាណាព្យាបាលសិស្ស និងលោកគ្រូអ្នកគ្រូ
- ចូលរួមរៀបចំទិវាជាតិអំណាន ថ្ងៃទី១១ ខែមិនា
- ចូលរួមផ្សព្វផ្សាយ និងលើកកម្ពស់ការអប់រំពហុភាសានៅតាមតំបន់ជនជាតិដើមភាគតិច
- ចូលរួមសម្របសម្រួលការអនុវត្តកម្មវិធីនានាពាក់ព័ន្ធនឹងការអភិវឌ្ឍ និងការគាំពារដល់កុមារដូចជាកម្មវិធីទារកដ្ឋាន ការអប់រំឪពុកម្តាយ ឬអ្នកអាណាព្យាបាលអំពីរបៀបចិញ្ចឹមកូនតាមបែបវិជ្ជមានជាដើម។

ឃ)ការទប់ស្កាត់អំពើហិង្សាទាក់ទងយេនឌ័រ ជាពិសេសអំពើហិង្សាលើស្ត្រីនិងកុមារ

- កំណត់ និងស្រង់ទិន្នន័យជនងាយរងគ្រោះដោយសារអំពើហិង្សា(ផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ និងផ្លូវសេដ្ឋកិច្ច) និងការបំពានខាងផ្លូវភេទ ការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្មស្ត្រី និងកុមារនៅក្នុងឃុំ សង្កាត់
- ចូលរួមបង្ការ ទប់ស្កាត់ និងធ្វើអន្តរាគមន៍ចំពោះករណីអំពើហិង្សា និងការរំលោភបំពាននានាជាពិសេសទៅលើស្ត្រី និងកុមារ
- សម្របសម្រួលបញ្ជូនជនរងគ្រោះដោយអំពើហិង្សា ឬដោយការរំលោភបំពាននានាទៅទទួលសេវាសង្គ្រោះបន្ទាន់ ឬសេវាសមស្របនានា
- ចូលរួមអនុវត្តវិធានការដោះស្រាយ ឬវិធានការសមស្របនានាដើម្បីជួយដល់ជនរងគ្រោះដោយអំពើហិង្សា ឬដោយការរំលោភបំពាន រហូតដល់ជនរងគ្រោះទាំងនេះអាចរស់នៅបានប្រកបដោយសុវត្ថិភាព និងសុខដុមរមនា
- តាមដាន កត់ត្រា និងរាយការណ៍អំពីករណីអំពើហិង្សា និងការរំលោភបំពាននានា។

ង)ការងារកិច្ចការពារកុមារ

- កំណត់ និងស្រង់ទិន្នន័យកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងឃុំ សង្កាត់
- ចូលរួមបង្ការ ទប់ស្កាត់ និងធ្វើអន្តរាគមន៍ចំពោះករណីអំពើហិង្សា ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការរំលោភបំពាននានាលើកុមារ
- សម្របសម្រួលបញ្ជូនកុមាររងគ្រោះដោយអំពើហិង្សានិងការរំលោភបំពាននានាទៅទទួលសេវាសមស្រប និងសេវាឯកទេស (ចិត្តសង្គម សុខភាព ផ្លូវច្បាប់)

- ចូលរួមផ្សព្វផ្សាយសារលិខិតរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជានៅក្នុងទិវាកុមារអន្តរជាតិថ្ងៃទី០១ មិថុនា
- ចូលរួមអនុវត្តវិធានការសមស្របនានា ដោយផ្អែកលើគោលការណ៍ឧត្តមប្រយោជន៍កុមារដើម្បីអភិវឌ្ឍ និងជួយដល់កុមាររងគ្រោះរហូតដល់កុមាររងគ្រោះទាំងនេះអាចរស់នៅប្រកបដោយសុវត្ថិភាព ព្រមទាំងទទួលបានការអប់រំមូលដ្ឋាន៩ឆ្នាំយ៉ាងតិចនិងកម្មវិធីអភិវឌ្ឍន៍សមត្ថភាពជំនាញនានាសម្រាប់ការបំពេញការងារ។

**ច)ការងារទឹកស្អាត និងអនាម័យ**

- ចលនា និងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យប្រើប្រាស់ ឬបរិភោគទឹកដែលមានសុវត្ថិភាព
- ចលនា និងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋប្រើប្រាស់បង្គន់អនាម័យ លាងដៃនឹងសាប៊ូ និងប្រតិបត្តិជាប្រចាំនូវអនាម័យសំខាន់ៗផ្សេងៗទៀត
- ផ្តល់ការគាំទ្រដល់គ្រួសារដែលពុំមានលទ្ធភាពក្នុងការប្រើប្រាស់ទឹកដែលមានសុវត្ថិភាពនិងឬបង្គន់អនាម័យ
- ចូលរួមរៀបចំទិវាអនាម័យសំខាន់ៗដូចជាទិវាទឹកពិភពលោកថ្ងៃទី២២ ខែមីនា ទិវាពិភពលោកលាងដៃស្អាត ថ្ងៃទី១៥ ខែតុលា និងទិវាជាតិលើកកម្ពស់អនាម័យជនបទ ថ្ងៃទី១៣ ខែវិច្ឆិកាជាដើម

**ឆ)ការងារពិការភាព**

- ចលនា និងជំរុញលើកទឹកចិត្តដល់ជនមានពិការភាព និងគ្រួសារឱ្យចូលរួមក្នុងដំណើរការកំណត់អត្តសញ្ញាណកម្មជនមានពិការភាព
- ស្រង់ស្ថិតិគ្រួសារដែលមានសមាជិកជាជនមានពិការភាព
- កំណត់បញ្ហា តម្រូវការ និងដោះស្រាយចាំបាច់នានារបស់ជនមានពិការភាព
- ចូលរួមអនុវត្តវិធានការសមស្របនានាដើម្បីឱ្យជនមានពិការភាពទទួលបាននូវព័ត៌មាន ចំណេះដឹងនិងសេវានានាប្រកបដោយសមធម៌សង្គម បរិយាប័ន្ន និងមានជីវភាពរស់នៅប្រកបដោយសុវត្ថិភាពនិងសេចក្តីថ្លៃថ្នូរ
- ចូលរួមរៀបចំទិវាជនមានពិការភាពកម្ពុជា ថ្ងៃទី០៣ ខែធ្នូ។

**ជ)ការងារជនក្រីក្រ និងមនុស្សចាស់**

- ស្រង់ស្ថិតិគ្រួសារក្រីក្រ ឬចូលរួមកិច្ចដំណើរការធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ព្រមទាំងស្ថិតិមនុស្សចាស់មនុស្សចាស់ក្រីក្រ
- កំណត់បញ្ហា តម្រូវការ និងដំណោះស្រាយនានារបស់ជនក្រីក្រ ជនចាស់ជរា និងមនុស្សចាស់ចូលរួមអនុវត្តវិធានការសមស្របនានាដើម្បីជួយដល់ជនក្រីក្រ ជនចាស់ជរា និងមនុស្សចាស់ក្នុងការទទួលបាននូវជីវភាពរបស់នៅប្រកបដោយសុវត្ថិភាព និងសេចក្តីថ្លៃថ្នូរ
- ចូលរួមសម្របសម្រួលនិងគាំទ្រការរៀបចំបង្កើតនិងដំណើរការរបស់សមាគមមនុស្សចាស់នៅតាមសហគមន៍
- ចូលរួមរៀបចំទិវាមនុស្សចាស់កម្ពុជា ថ្ងៃទី០១ ខែតុលា

**ឈ)ការបង្ការទប់ស្កាត់ប្រើប្រាស់គ្រឿងញៀន(រួមទាំងគ្រឿងស្រវឹង)**

- ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋជាពិសេសយុវជនអំពីផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀននិងគ្រឿងស្រវឹង
- ចូលរួមកំណត់មុខសញ្ញាអ្នកចរាចរ និងឬអ្នកប្រើប្រាស់គ្រឿងញៀន
- ចូលរួមអនុវត្តវិធានការសមស្របនានា ដើម្បីបង្កា និងទប់ស្កាត់ការចរាចរ និងការប្រើប្រាស់គ្រឿងញៀន ព្រមទាំងការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន។

**៣)ការលើកកម្ពស់សមភាពយេនឌ័រ**

- ចលនា និងជំរុញលើកទឹកចិត្តស្ត្រីឱ្យចូលរួមនៅក្នុងដំណើរការធ្វើសេចក្តីសម្រេច និងអនុវត្តសេចក្តីសម្រេចរបស់រដ្ឋបាលឃុំ សង្កាត់
- ចលនា និងជំរុញលើកទឹកចិត្តស្ត្រីឱ្យចូលរួមសកម្មភាពនយោបាយ និងអភិវឌ្ឍន៍សេដ្ឋកិច្ចដើម្បីលើកកម្ពស់ឋានៈស្ត្រីនៅក្នុងគ្រួសារ និងសង្គមជាតិ
- ចូលរួមអនុវត្តវិធានការសមស្របនានាដើម្បីផ្តល់ភាពអង់អាចដល់ស្ត្រី និងលើកកម្ពស់សមធម៌សង្គម និងបរិយាប័ន្ន
- ចូលរួមផ្សព្វផ្សាយអំពីការផ្លាស់ប្តូរឥរិយាបថ និងផ្នត់គំនិតអវិជ្ជមានដែលរារាំងដល់ស្ត្រី និងក្មេងស្រីក្នុងការចូលរួមការងារសង្គម និងសហគមន៍
- ចូលរួមផ្សព្វផ្សាយសារលិខិតរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជានៅក្នុងទិវានារីអន្តរជាតិថ្ងៃទី០៨ ខែមីនា។

**ង)ការងារសេវាសង្គមផ្សេងៗទៀត។**

- សម្របសម្រួល និងអនុវត្តសកម្មភាពសេវាសង្គមផ្សេងៗទៀតដែលបានប្រគល់ឱ្យរដ្ឋបាលឃុំ សង្កាត់។

ទន្ទឹមនឹងអនុវត្តមុខងារចម្បងខាងលើ គ.ក.ន.ក ចូលរួមអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាពដែលចាប់ផ្តើមអនុវត្តតាំងពីឆ្នាំ២០១០ កន្លងមកគឺជាយន្តការមួយដើម្បីកាត់បន្ថយបទល្មើសនៅថ្នាក់មូលដ្ឋាននៅទូទាំងប្រទេសរួមមានអំពើចោរកម្មជាអាទិ៍លួចឆក់ ប្លន់ អំពើហិង្សាក្នុងគ្រួសារ ការជួញដូរមនុស្ស គ្រឿងញៀន ល្បែងស៊ីសង សកម្មភាពទំនើង និងការប្រើប្រាស់អាវុធខុសច្បាស់ជាដើម ។ល។ គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព៖

- គ្មានសកម្មភាពលួច ឆក់ ប្លន់គ្រប់ប្រភេទ
- គ្មានការដាំដុះ ការផលិត ការចរាចរ ការជួញដូរការចែកចាយ និងការប្រើប្រាស់គ្រោះងញៀនខុសច្បាប់
- គ្មានអំពើអាណាចារ្យ ការជួញដូរស្ត្រីនិងកុមារ និងអំពើហិង្សាក្នុងគ្រួសារ
- គ្មានក្មេងទំនើង
- គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ
- គ្មានគ្រោះថ្នាក់ចរាចរណ៍
- គ្មានគ្រោះថ្នាក់ដោយសារយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ
- មានវិធានការការទប់ស្កាត់ គ្រប់គ្រង និងឆ្លើយតបចំពោះគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព
- គ្មានការត្រួតពិនិត្យខុសច្បាប់។

គ.ក.ន.ក ចូលរួមអនុវត្តសេចក្តីសម្រេចលេខ១៩៥៦ សសរ ចុះថ្ងៃទីចុះថ្ងៃទី២ ឧសភា ឆ្នាំ២០១៨ ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីការអនុវត្តសកម្មភាពសេវាសង្គមឃុំសង្កាត់។ សៀវភៅណែនាំនេះបានបញ្ជាក់ពីបញ្ហាសេវាសង្គមមួយចំនួននៅឃុំ សង្កាត់មានដូចជាសុខភាពមាតា ទារក និងអាហារូបត្ថម្ភ អនាម័យ និងទឹកស្អាត កិច្ចការពារកុមារ ការអប់រំកុមារតូច និងភាពងាយរងគ្រោះជាដើម។ បញ្ហាទាំងនោះសុទ្ធសឹងជាអាទិភាពតម្រូវឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រុមប្រឹក្សា ឃុំ សង្កាត់ និង គ.ក.ន.ក បង្កើនការយកចិត្តទុកដាក់ក្នុងការផ្តល់សេវាសង្គមឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព និងសមធម៌។

### ២.៤.៩.គណៈកម្មាធិការពាក់ព័ន្ធដឹកនាំ និងសម្របសម្រួលដោយក្រសួងស្ថាប័ន

រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតគណៈកម្មាធិការមួយចំនួន រួមមាន៖ ក.គណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ "គ.ជ.ព"[39] ដែលដឹកនាំនិងសម្របសម្រួលដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងបានបង្កើតអគ្គលេខាធិការដ្ឋាននៃគ.ជ.ព[40] ធ្វើជាសេនាធិការ ខ.គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស"គ.ជ.ប.ជ"[41] ដែលដឹកនាំសម្របសម្រួលដោយក្រសួងមហាផ្ទៃនិងបានបង្កើតអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប.ជ[42] ធ្វើជាសេនាធិការ គ.គណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍន៍កុមារតូច "គ.ជ.គ.ក"[43] ដែលដឹកនាំនិងសម្របសម្រួលដោយក្រសួងអប់រំ យុវជន និងកីឡា និងបានបង្កើតអគ្គលេខាធិការដ្ឋាននៃ គ.ជ.គ.ក[44]ធ្វើជាសេនាធិការ ឃ.គណៈកម្មការដឹកនាំអនុវត្តផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ[45] ដែលដឹកនិងសម្របសម្រួលដោយក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា និងបានបង្កើតក្រុមការងារបច្ចេកទេសចំនួនបី រួមមាន៖១.ក្រុមការងារលើកកម្ពស់ការយល់ដឹង និងទប់ស្កាត់អំពើហិង្សាលើកុមារ ២.ក្រុមការងារផ្តល់សេវានិងអនុវត្តច្បាប់ និង៣.ក្រុមការងារសិក្សាលើបទដ្ឋានគតិយុត្ត ពិនិត្យតាមដាន និងធ្វើរបាយការណ៍ ង.គណៈកម្មការការពារកុមារថ្នាក់ជាតិ[46] ដឹកនាំដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងច.គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើ ទុក្ខបុកម្នេញ ឬទណ្ឌកម្ម "គ.ជ.ប.ទ."[47] ដឹកនាំនិងសម្របសម្រួលដោយក្រសួងមហាផ្ទៃ និងបានបង្កើតលេខាធិការដ្ឋានធ្វើជាសេនាធិការ[48] ។

## ២.៥.អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស

អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស បាន និងកំពុងអនុវត្តផ្តល់សេវាសុខុមាលភាពសង្គម និងកិច្ចការពារកុមារតាមរយៈកម្មវិធីមួយចំនួន ជាពិសេសកម្មវិធីភាពជាដៃគូសម្រាប់ការពារកុមារ(3PC)[49] ដែលមានអង្គការមិនមែនរដ្ឋាភិបាលអនុវត្តផ្ទាល់ចំនួន១១ ដៃគូផ្តល់បច្ចេកទេសចំនួន៦ និងដៃគូជាបណ្តាញចំនួន៤០។ គម្រោងថែទាំកុមារក្នុងគ្រួសារជាអាទិភាពចម្បង(FCF) និង REACT[50] គឺជាបណ្តាញនៃស្ថាប័នជាច្រើន ដោយមានការគាំទ្រមូលនិធិពីសហភាពអឺរ៉ុប ទីភ្នាក់ងារជំនួយអាមេរិក USAID មូលនិធិ GHR អង្គការ Save the Children ហុងកុង និងអង្គការយូនីសេហ្វ មានសមាជិកជាង ៦០អង្គភាព។ ក្រៅពីអង្គការមិនមែនរដ្ឋាភិបាលក៏មានដៃគូអភិវឌ្ឍនានា រួមទាំងមូលនិធីអង្គការសហប្រជាជាតិដើម្បីកុមារ (UNICEF) កំពុងតែគាំទ្រដល់សកម្មភាពផ្តល់កិច្ចការពារកុមារផងដែរ។

---

[39] ព្រះរាជក្រឹត្យលេខ នស/រកត/១១១៦/១០៤៤ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការបង្កើត គ.ជ.ព

[40] អនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃ គ.ជ.ព

[41] ព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៨០៨ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការបង្កើត គ.ជ.ប.ជ

[42] អនុក្រឹត្យលេខ ២៧៣ អនក្រ.បក ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប.ជ

[43] ព្រះរាជក្រឹត្យលេខ នស/រកត/០៤១២/៣១៧ ចុះថ្ងៃទី៤ មេសា ឆ្នាំ២០១៣ ស្តីពីការបង្កើត គ.ជ.គ.ក

[44] អនុក្រឹត្យលេខ ១៩០ អនក្រ.បក ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្យទៅរបស់អគ្គលេខាធិការនៃ គ.ជ.គ.ក

[45] សេចក្តីសម្រេចលេខ ១៨៧ ស.អ.យ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ ស្តីពីការបង្កើតគណៈកម្មការដឹកនាំអនុវត្តផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ២០១៧-២០២១

[46] សេចក្តីសម្រេចលេខ ១០៥ ក.ជ.ក ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការបង្កើតគណៈកម្មការការពារកុមារថ្នាក់ជាតិ

[47] ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៧/៦១៩ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៧ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម "គ.ជ.ប.ទ"

[48] អនុក្រឹត្យលេខ២២៨ អនក្រ.បក ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន នៃ គ.ជ.ប.ទ.

[49] https://web.facebook.com/3pccambodia & 3pc-cambodia.org

[50] www.fcf-react.org

តារាងទី១០៖ ផែនទីកម្លាំងសេវាសង្គមកិច្ចការពារកុមារ

| ល.រ | ស្ថាប័ន/អង្គភាព | ចំនួនកម្លាំងសេវាសង្គម[51] | |
|---|---|---|---|
| | | ចំនួនរួម | ការពារកុមារ[52] |
| ក | ភាពជាអ្នកដឹកនាំនិងការត្រួតពិនិត្យ | | |
| ១ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | មន្ត្រីសរុបចំនួន ១២០២នាក់[53] (កម្លាំងសេវាសង្គម ៥០០នាក់ រួមទាំងមន្ត្រីកិច្ចការពារកុមារ) | ១១៨នាក់[54] |
| ខ | កម្រិតអនុវត្ត | | |
| ២ | មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត | មន្ត្រីសរុបចំនួន ១០៥៧នាក់[55] (កម្លាំងសេវាសង្គម ៤៧១នាក់ រួមទាំងមន្ត្រីកិច្ចការពារកុមារ) | ១២៥នាក់ |
| ៣ | ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម ក្រុង ស្រុក ខណ្ឌ | មន្ត្រីទទួលបន្ទុកការងារសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ២ x ២០៣=៤០៦នាក់ | |
| ៤ | គ.ក.ន.ក ឃុំ សង្កាត់ | សមាជិក៖១៣x១៦៤៦=២១៣៩៨នាក់<br>មន្ត្រីទទួលបន្ទុក៖២x១៦៤៦=៣២៩នាក់ | |
| ៥ | អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស | បុគ្គលិកកិច្ចការពារកុមារ ១០ x ១១៧ =១១៧០នាក់ | |
| គ | យន្តការសម្របសម្រួល | | |
| ៦ | អគ្គលេខាធិការដ្ឋាន ក.ជ.ក | មន្ត្រីទទួលបន្ទុកកិច្ចការពារកុមារ ១០ x ៣=២១នាក់ | |
| ៧ | ក្រុមការងារដើម្បីកុមារនៅតាមក្រសួង-ស្ថាប័នចំនួន៩ | មន្ត្រីទទួលបន្ទុកកិច្ចការពារកុមារ ៣ x ៩=២៧ នាក់ | |
| ៨ | គណៈកម្មាធិការដឹកនាំដោយក្រសួង ស្ថាប័ន៖[56] គ.ជ.ព, គ.ជ.ប.ជ, គ.ជ.គ.ក និង គ.ជ.ប.ទ | មន្ត្រីទទួលបន្ទុកកិច្ចការពារកុមារ ១០ x ៤=៤០នាក់ | |
| ៩ | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមាររាជធានី ខេត្ត | សមាជិក ក.ជ.ក ៖ ២៦ x ២៥=៦៥០នាក់<br>ក្រុមការងារបច្ចេកទេស៖៥ x ២៥=១២៥នាក់ | |
| ១០ | គ.ក.ស.ក រាជធានី ខេត្ត | សមាជិក គ.ក.ស.ក ៖១៦ x ២៥=៤០០នាក់<br>ក្រុមការងារបច្ចេកទេស៖៥x២៥=១២៥នាក់ | |
| ១១ | គ.ក.ស.ក ក្រុង ស្រុក ខណ្ឌ | សមាជិក គ.ក.ស.ក ៖១៥ x ២០៣=៣០៤៥នាក់<br>ក្រុមការងារបច្ចេកទេស៖៣ x ២០៣=៦០៩នាក់ | |

[51] In Cambodia, the ratio of social worker to the population is currently 1/12,000. The need for the social service workforce has been recognized in different policies, including the Juvenile Justice Law (2016) and the National Social Protection Policy Framework (2016-2025).

[52] GSWA-the state of the social service workforce 2018, the ratio 59.6 (3490) with responsibility for child protection per 100.000 children

[53] របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំខែតុលា ឆ្នាំ២០២០ របស់ក្រសួង ស.អ.យ (មន្ត្រីកិច្ចសន្យាចំនួន២៦០នាក់)។

[54] របាយការណ៍របស់នាយកដ្ឋានសុខុមាលភាពកុមារឆ្នាំ២០២០ (បុរីទារក និងកុមារជាតិចំនួន ៨៤នាក់) បុគ្គលិកកិច្ចសន្យាចំនួន ៣៣នាក់

[55] របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំខែតុលា ឆ្នាំ២០២០ របស់ក្រសួង ស.អ.យ (មន្ត្រីកិច្ចសន្យាចំនួន ១៨៧នាក់)

[56] លើកលែងតែគណៈកម្មការដឹកនាំអនុវត្តផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ និងគណៈកម្មការការពារកុមារថ្នាក់ជាតិ ដែលប្រើប្រាស់មន្ត្រីរបស់នាយកដ្ឋានសុខុមាលភាពកុមារ នៃក្រសួង ស.អ.យ និងអគ្គលេខាធិការដ្ឋាន ក.ជ.ក

# ៣. វឌ្ឍនភាព និងបញ្ហាប្រឈម

## ៣.១. វឌ្ឍនភាព

គ្រឹះស្ថានអប់រំរួមមានសកលវិទ្យាល័យភូមិន្ទភ្នំពេញ វិទ្យាស្ថានជាតិសង្គមកិច្ច និងវិទ្យាស្ថានសន្តប៉ូលបានអប់រំ និងបណ្តុះបណ្តាលនិស្សិតកម្រិតឧត្តមសិក្សា និងក្រោយឧត្តមសិក្សា ផ្នែកសិល្បៈការងារសង្គមចំនួន ៤០៨នាក់ ទន្ទឹមនឹងនេះក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការមិនមែនរដ្ឋាភិបាល បានបណ្តុះបណ្តាលសេវាសង្គមកិច្ចមូលដ្ឋាន សេវាសង្គមកិច្ចជំនាញ និងការគ្រប់គ្រងសេវាសង្គមកិច្ចចំនួន ១៦០១នាក់។ នាយកដ្ឋាន/អង្គភាពចំណុះរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការមិនមែនរដ្ឋាភិបាលបានធ្វើការបណ្តុះបណ្តាលមន្រ្តី ឬបុគ្គលិកលើជំនាញកិច្ចការពារកុមារ និងការងារសង្គមកិច្ច។

ចាប់តាំងពីដំណើរការវិស័យសង្គមកិច្ចកន្លងមក កម្ពុជាមិនទាន់មានបទដ្ឋានសង្គមកិច្ចនៅឡើយទេ ទើបនៅឆ្នាំ២០១៧ ក្រោមកិច្ចសហការជាមួយគម្រោងថៃទាំកុមារជាអាទិភាពចម្បងនៃអង្គការសង្គ្រោះកុមារ និងដោយមានការយល់ដឹងអំពីសារៈសំខាន់នៃបទដ្ឋានវិជ្ជាជីវៈសង្គមកិច្ចសម្រាប់ជាសូចនាករវាស់វែង គុណតម្លៃ ចំណេះដឹង និងជំនាញ កម្លាំងសេវាសង្គមទាំងនៅក្នុង និងក្រៅក្របខ័ណ្ឌរដ្ឋាភិបាល ទើបក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានផ្តួចផ្តើមសិក្សាស្រាវជ្រាវ និងចងក្រងបទដ្ឋានវិជ្ជាជីវៈសង្គមកិច្ចនេះឡើង។ បទដ្ឋានវិជ្ជាជីវៈសង្គមកិច្ចមានពីរគឺៈ១.បទដ្ឋានវិជ្ជាជីវៈសង្គមកិច្ចសម្រាប់អ្នកអនុវត្តទូទៅ[57] និង ២.បទដ្ឋានវិជ្ជាជីវៈសង្គមកិច្ចកម្រិតឯកទេស ដែលនៅក្នុងនោះមានបទដ្ឋានវិជ្ជាជីវៈសង្គមកិច្ចសម្រាប់អ្នកដឹកនាំនិងគ្រប់គ្រងវិស័យសង្គមកិច្ច និងបទដ្ឋានវិជ្ជាជីវៈសង្គមកិច្ចសម្រាប់អ្នកសង្គមកិច្ចបែបគ្លីនិក។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានចេញប្រកាសលេខ ៤៤៣ ស.អ.យ.ប្រ.ក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីសមត្ថភាពមូលដ្ឋានសម្រាប់កម្លាំងសេវាសង្គមនៅកម្ពុជាដើម្បីជាឧបករណ៍វាស់វែងកម្រិតសមត្ថភាពមូលដ្ឋានសម្រាប់កម្លាំងសេវាសង្គម លើផ្នែកគុណតម្លៃ[58]និងក្រមសីលធម៌ ចំណេះដឹង[59] និងជំនាញ[60] ដែលជាតម្រូវការចាំបាច់ក្នុងការអនុវត្តការងារសង្គមកិច្ចនៅគ្រប់កម្រិត។ អ្នកដែលមានអាជីពអនុវត្តការងារសង្គមគ្រប់រូបនៅកម្ពុជា ត្រូវប្រតិបត្តិតាមគោលការណ៍ណែនាំនេះ ដែលជាឧបករណ៍សម្រាប់អនុវត្តល្អៗ និងជាកិច្ចគាំពារសម្រាប់អ្នកប្រើប្រាស់ និងអ្នកផ្តល់សេវា។ គោលការណ៍ណែនាំនេះមានវិសាល

---

[57] បានកំណត់នូវវិធានសម្រាប់អនុវត្តវិជ្ជាជីវៈសង្គមកិច្ច និងប្រើជាឯកសារៈ ១.សម្រាប់ការអភិវឌ្ឍបទដ្ឋានបណ្តុះបណ្តាលវិស័យសង្គមកិច្ចវិទ្យា ២.មគ្គុទេសក៍មួយដ៏មានប្រយោជន៍សម្រាប់ស្ថាប័នរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជនដែលពាក់ព័ន្ធក្នុងការបណ្តុះបណ្តាល និងកសាងសមត្ថភាព ស្របតាមតម្រូវការនៃស្ថាប័នរបស់ខ្លួន ៣.ប្រើប្រាស់ជាវិធានគោលសម្រាប់ផ្តល់អាជ្ញាប័នដល់អ្នកផ្តល់សេវាសង្គមកិច្ច។

[58] **គុណតម្លៃ៖** សំដៅដល់គោលការណ៍ និងគោលគំនិត ដែលអ្នកអនុវត្តការងារសង្គមទាំងអស់ប្រាថ្នាចង់បាន។ រួមបញ្ចូលនឹងចំណេះដឹងនិងជំនាញ គុណតម្លៃនៃការងារសង្គម គឺជាលក្ខណៈវិនិច្ឆ័យវិជ្ជាជីវៈសម្រាប់វាស់ស្ទង់សមត្ថភាព ក្នុងការអនុវត្ត។

[59] **ចំណេះដឹង៖**សំដៅដល់អ្នកអនុវត្តការងារសង្គមមានចំណេះដឹងស្តីពីស្ថានភាពនិងបញ្ហាសង្គមគោលនយោបាយសង្គមនិងកម្មវិធីនានា បាតុភូតសង្គម អាជីពសង្គមកិច្ចវិទ្យា និងចំណេះដឹងអំពីទ្រឹស្តីពាក់ព័ន្ធនានា សម្រាប់អនុវត្តការងារ ក្នុងគោលបំណងសម្រួលដំណើរការនៃការផ្លាស់ប្តូរ។

[60] **ជំនាញ៖** សំដៅដល់សមត្ថភាពធ្វើអ្វីមួយបានយ៉ាងល្អ។

ភាពអនុវត្តចំពោះអង្គភាព ឬស្ថាប័ន ដែលផ្តល់សេវាសង្គម[61] និងអ្នកផ្តល់សេវាសង្គមគ្រប់រូបទាំងអ្នកមាន និងអ្នកមិនទាន់មានសញ្ញាបត្រសង្គមកិច្ចវិទ្យាដែលធ្វើការផ្ទាល់ជាមួយអតិថិជន[62](បុគ្គល គ្រួសារ និងក្រុម)នៅកម្ពុជា។

## ៣.២.បញ្ហាប្រឈម

### ៣.២.១.ការរៀបចំកម្មវិធីនិងកញ្ចប់មេរៀនបណ្តុះបណ្តាលកម្លាំងសេវាសង្គម

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មាននាយកដ្ឋាន និងអង្គភាពជំនាញរៀបចំកម្មវិធីនិងកញ្ចប់មេរៀនយោងតាមតម្រូវការអនុវត្តមុខងារស្របតាមគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តដើម្បីគាំទ្រដល់ការផ្តល់សេវាសាធារណៈដែលទទួលខុសត្រូវសម្រាប់បណ្តុះបណ្តាលមន្ត្រីជំនាញ។ ដោយឡែកអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ ក៏រៀបចំកម្មវិធីនិងកញ្ចប់បណ្តុះបណ្តាលដល់បុគ្គលិករបស់ពួកគេដើម្បីអនុវត្តមុខងារផ្តល់សេវាដូចដែលមានចែងនៅក្នុងគម្រោងនិងកម្មវិធីរបស់ពួកគេ។ ការរៀបចំកម្មវិធីនិងកញ្ចប់មេរៀនមិនមានស្តង់ដារវិជ្ជាជីវៈមូលដ្ឋានណាមួយដើម្បីកំណត់ឱ្យស្របតាមគោលការណ៍ណែនាំស្តីពីសមត្ថភាពមូលដ្ឋានសម្រាប់កម្លាំងសេវាសង្គមនៅកម្ពុជា(កម្រិតចំណេះដឹង ជំនាញ និងគុណតម្លៃ) និងក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា (វិញ្ញាបនបត្រវិជ្ជាជីវៈសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ១ ២ និង៣)។

### ៣.២.២.ការបណ្តុះបណ្តាលកម្លាំងសេវាសង្គមកិច្ចការពារកុមារ

ការបណ្តុះបណ្តាលកម្លាំងសេវាសង្គមកន្លងមកគឺធ្វើឡើងសម្រាប់មន្ត្រីឬបុគ្គលិកជំនាញដែលទទួលខុសត្រូវក្នុងការអនុវត្តមុខងារមិនកំណត់ពីប្រភេទនៃកម្លាំងសេវាសង្គមទេចំណែកឯកម្មវិធីបណ្តុះបណ្តាលមិនទាន់មានលក្ខណៈស្តង់ដារទៅតាមប្រភេទកម្លាំងសេវាសង្គមមាន៖១.បុគ្គលិកសង្គមអាជីព ២.បុគ្គលិកសង្គមប៉ារ៉ាអាជីព ៣.បុគ្គលិកសង្គមប៉ារ៉ា និង៤.បុគ្គលិកសម្ព័ន្ធសង្គមកិច្ច ដូចដែលបានកំណត់នៅក្នុងគោលការណ៍ណែនាំស្តីពីសមត្ថភាពមូលដ្ឋានសម្រាប់កម្លាំងសេវាសង្គមនៅកម្ពុជា និងសេចក្តីណែនាំស្តីពីការពង្រឹងកម្លាំងសេវាសង្គមដើម្បីការពារកុមារ។

### ៣.២.៣.ការពង្រឹងសមត្ថភាពគ្រូបង្គោល គ្រូជំនាញ និងគ្រឹះស្ថានអប់រំបណ្តុះបណ្តាល

វិទ្យាស្ថានជាតិសង្គមកិច្ច គ្រឹះស្ថានអប់រំ មានគ្រូក្នុងក្របខណ្ឌ និងជំនាញច្បាស់លាស់នៅកម្រិតឧត្តមសិក្សាចំណែកគ្រូបង្គោលពុំទាន់មានការចងក្រងជាក្រុមទៅតាមជំនាញឡើយ។ បច្ចុប្បន្នគ្រូបង្គោលបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈសង្គមកិច្ចភាគច្រើនជាមន្ត្រីឯកទេសកំពុងបម្រើការនៅតាមនាយកដ្ឋាន និងអង្គភាពចំណុះក្រសួង ឬជាអ្នកឯកទេសរបស់អង្គការមិនមែនរដ្ឋាភិបាលនានា។ បច្ចុប្បន្នក្រសួងមិនទាន់មានកម្មវិធីបណ្តុះបណ្តាលគរុកោសល្យ និងជំនាញសង្គមកិច្ចបន្ថែមសម្រាប់គ្រូបង្គោលដើម្បីឱ្យមានចំណេះដឹងទៅតាមឯកទេស និងចងក្រងជាក្រុមនៅឡើយ។ បន្ថែមពីនេះមិនបានកំណត់គ្រឹះស្ថានអប់រំ ឬអង្គភាពណាមួយជាក់លាក់សម្រាប់ការអប់រំបណ្តុះបណ្តាលនេះ។

---

[61] **សេវាសង្គម៖** គឺជាប្រព័ន្ធរៀបរយមួយនៃសេវាកម្ម និងកម្មវិធីរបស់រាជរដ្ឋាភិបាល ដើម្បីធ្វើការទប់ស្កាត់ កាត់បន្ថយ ឬដោះស្រាយហានិភ័យផ្នែកសង្គម និងបញ្ហាសង្គម ដោយធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពរបស់បុគ្គល គ្រួសារ និងក្រុម។ អត្ថប្រយោជន៍ដែលផ្តល់ឱ្យត្រូវផ្អែកលើទស្សនៈវិស័យ ឬជម្រើសមួយស្តីពីសិទ្ធិ ឧទាហរណ៍ ផ្អែកលើមូលដ្ឋាននៃលក្ខណៈវិនិច្ឆ័យ ឬលក្ខខណ្ឌតម្រូវជាក់លាក់មួយចំនួន។

[62] **អតិថិជន៖** សំដៅដល់អ្នកដែលទទួលផល ឬប្រយោជន៍ ឬទទួលសេវាកម្មពីអ្នកផ្តល់សេវាមនុស្សធម៌ ដោយការផ្តល់សេវានេះមិនដើម្បីប្តូរជាប្រាក់ឡើយ។

## ៤. ទស្សនៈវិស័យ បេសកកម្ម និងគោលដៅយុទ្ធសាស្ត្រ

### ៤.១. ទស្សនៈវិស័យ

អ្នកផ្តល់សេវាសង្គមកិច្ចគ្រប់រូបមានចំណេះដឹង ជំនាញ និងអាកប្បកិរិយាចាំបាច់ ព្រមទាំងគុណវុឌ្ឍិ និងក្រមសីលធម៌វិជ្ជាជីវៈដើម្បីផ្តល់សេវាសង្គមប្រកបដោយគុណភាព។

### ៤.២. បេសកកម្ម

បណ្តុះបណ្តាលកម្លាំងសេវាសង្គមឱ្យមានគុណវុឌ្ឍិពិតប្រាកដលើចំណេះដឹង ជំនាញ និងអាកប្បកិរិយាប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈដើម្បីក្លាយជា "១.អ្នកអាជីពសង្គមកិច្ច(បុគ្គលិកសង្គមអាជីព) ២.អ្នកអាជីពសង្គមកិច្ចរង (បុគ្គលិកសង្គមប៉ារ៉ាអាជីព) ៣.អ្នកសង្គមកិច្ចមិនអាជីព(បុគ្គលិកសង្គមប៉ារ៉ាវិជ្ជាជីវៈ) និង៤.អ្នកសង្គមកិច្ចសម្ព័ន្ធ (បុគ្គលិកសម្ព័ន្ធសង្គមកិច្ច)"ឱ្យមានសមត្ថភាពក្នុងការផ្តល់សេវាសង្គមកិច្ចជូនអតិថិជនដែលជាជនរងគ្រោះនិងងាយរងគ្រោះជាពិសេសកុមារ។

### ៤.៣. គោលបំណងគោលនយោបាយ

ផែនការយុទ្ធសាស្ត្រដើម្បីអប់រំបណ្តុះបណ្តាលកម្លាំងសេវាសង្គម ផ្តោតលើកិច្ចការពារកុមារ ឆ្នាំ២០២១-២០២៥ មានគោលបំណងអនុវត្តគោលនយោបាយរបស់វិស័យសង្គមកិច្ច ដែលចូលរួមធ្វើឱ្យសម្រេចនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ត្រង់ចតុកោណទី១"ការអភិវឌ្ឍធនធានមនុស្ស"ដោយផ្តោតសំខាន់លើមុំ៖១.ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ២.ការបណ្តុះបណ្តាលជំនាញបច្ចេកទេស ៣.ការលើកកម្ពស់សេវាសុខភាពសាធារណៈនិងអាហារូបត្ថម្ភ និង៤.ការពង្រឹងសមភាពយេនឌ័រនិងការគាំពារសង្គម៖

- **មុំទី១.**ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា គឺអភិវឌ្ឍ "ប្រព័ន្ធអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាប័ន្ន" ដោយផ្តោតសំខាន់លើវិទ្យាសាស្ត្រ និងបច្ចេកទេស ការតម្រង់ទិសសម្រាប់ទីផ្សារការងារ និង ការយកចិត្តទុកដាក់លើការអប់រំកាយ សម្រាប់ទ្រទ្រង់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ។
- **មុំទី២.**ការបណ្តុះបណ្តាលជំនាញបច្ចេកទេស គឺសំដៅជានាថា "យុវជនម្នាក់ៗមានជំនាញមួយយ៉ាងតិចប្រចាំជីវិតប្រចាំជីវិត" ពិសេសដើម្បីជំរុញការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ឱ្យឈានឡើងមួយកម្រិតទៀត។ ការបណ្តុះបណ្តាល ជំនាញបច្ចេកទេសធ្វើឡើងក្នុងរូបភាពពីរ ដែលមានការផ្សារភ្ជាប់គ្នា គឺធនធានមនុស្សនៅក្នុងប្រព័ន្ធអប់រំ និងធនធាន មនុស្សនៅក្រៅប្រព័ន្ធអប់រំ ឬក្នុងទីផ្សារការងារ។
- **មុំទី៣.**ការលើកកម្ពស់សេវាសុខភាពសាធារណៈ និងអាហារូបត្ថម្ភគឺសំដៅលើកកម្ពស់សុខភាពប្រជាជន និងអាហារូបត្ថម្ភដើម្បីគាំទ្រដល់ការអភិវឌ្ឍធនធានមនុស្ស កំណើនសេដ្ឋកិច្ចនិងវឌ្ឍនភាពសង្គមប្រកបដោយចីរភាព
- **មុំទី៤.**ការពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គម គឺការពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គមដើម្បីលើកស្ទួយស្ថានភាពសង្គម-សេដ្ឋកិច្ច និងពង្រឹងតួនាទីស្ត្រីដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិ។

### ៤.៤. គោលបំណងរួមនៃយុទ្ធសាស្ត្រ

ផែនការយុទ្ធសាស្ត្រដើម្បីបណ្តុះបណ្តាលកម្លាំងសេវាសង្គម ឆ្នាំ២០២១-២០២៥ ផ្តោតលើវិជ្ជាជីវៈរបស់មន្ត្រីរាជការដែលអនុវត្តមុខងារផ្តល់សេវាទាក់ទងនឹងកិច្ចការពារកុមារ ទោះបីអាចត្រូវបានប្រើប្រាស់ដោយអង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធដទៃទៀតផងដែរ។ ផ្អែកលើព័ត៌មានដែលបានផ្តល់ជូនខាងលើផែនការយុទ្ធសាស្ត្រនេះផ្តោតលើកម្មវិធីបណ្តុះបណ្តាលចំនួនបួនកម្រិត៖

- សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ៣
- សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ២

- សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ១
- វិញ្ញាបនបត្រវិជ្ជាជីវៈ

សម្រាប់បរិបទនៃប្រទេសកម្ពុជា វិញ្ញាបនបត្រប្រភេទខាងក្រោមតម្រូវឱ្យមានសម្រាប់ប្រភេទផ្សេងៗនៃកម្លាំងសេវាសង្គម។ បុគ្គលិកសម្ព័ន្ធសង្គមកិច្ចនិងកម្លាំងសេវាសង្គមទាក់ទងនឹងកិច្ចការពារកុមាររបស់អង្គការមិនមែនរដ្ឋាភិបាលអាចមានកម្រិតណាមួយអាស្រ័យលើលក្ខណៈនៃការងាររបស់ពួកគេ។ ខណៈពេលដែលកម្លាំងសេវាសង្គមត្រូវបានលើកឡើងនៅក្នុងតារាងខាងក្រោម អាទិភាពគួរតែសម្រាប់អ្នកដែលជាអ្នកដឹកនាំក្រសួង ស.អ.យ នាយកដ្ឋាន/អង្គភាពចំណុះក្រសួង និងមន្ទីរ ស.អ.យ ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម ក្រុង ស្រុក ខណ្ឌ និង គ.ក.ន.ក។

កម្មវិធីបណ្តុះបណ្តាលឈានដល់កម្រិតវិញ្ញាបនបត្រខុសគ្នានឹងមានទាំងការសិក្សាក៏ដូចជាបទពិសោធន៍ជាក់ស្តែង ហើយក៏អាចរួមបញ្ចូលទាំងការគ្រប់គ្រងការសិក្សា រួមទាំងតាមរយៈការសិក្សាតាមអ៊ីនធឺណិត និងទម្រង់បែបបទនៃការរៀនទល់មុខគ្នា។ យន្តការអាចមានសម្រាប់ការវាយតម្លៃអំពីសមត្ថភាពដែលនិស្សិតអាចទទួលបានរួចហើយតាមរយៈបទពិសោធន៍នៅកន្លែងធ្វើការ និងពេលវេលាទាំងនេះអាចត្រូវបានកាត់បន្ថយតាមរយៈការវាយតម្លៃជាផ្លូវការសម្រាប់ការទទួលស្គាល់ការរៀនមុន(RPL) និងការទទួលស្គាល់សមត្ថភាពបច្ចុប្បន្ន(RCC)។

វិទ្យាស្ថានជាតិសង្គមកិច្ចនឹងទទួលខុសត្រូវក្នុងការរៀបចំកម្មវិធីបណ្តុះបណ្តាលរួមទាំងចំនុចក្រេឌីត និងម៉ោងព្រមទាំងកាត់បន្ថយតាមរយៈការវាយតម្លៃជាផ្លូវការសម្រាប់ការទទួលស្គាល់ការរៀនមុន(RPL)និង ការទទួលស្គាល់សមត្ថភាពបច្ចុប្បន្ន(RCC) ហើយនឹងទទួលខុសត្រូវក្នុងការធានានូវដំណើរការផ្លូវការទាំងអស់ដើម្បីធានាបាននូវទម្រង់បែបបទនៃប្រព័ន្ធវិញ្ញាបនបត្រទាំងនេះ។

ខាងក្រោមនេះត្រូវបានស្នើសុំជាអាទិភាពសម្រាប់កម្លាំងសេវាសង្គមរបស់រដ្ឋាភិបាលដែលទទួលខុសត្រូវចំពោះកិច្ចការពារកុមារ។ ទោះជាយ៉ាងណាក៏ដោយ បុគ្គលផ្សេងទៀតដែលចាប់អារម្មណ៍នឹងកម្មវិធីនេះក៏នឹងអាចចូលរួមក្នុងកម្មវិធីទាំងនេះនិងទទួលបានវិញ្ញាបនបត្រតាមរយៈស្ថាប័នពាក់ព័ន្ធ។

លើសពីនេះទៀត យុទ្ធសាស្ត្រផ្តល់វិញ្ញាបនបត្រត្រូវបានតម្រង់ទិសឆ្ពោះទៅកអ្នកដែលអនុវត្ត ឬត្រួតពិនិត្យ ឬតួនាទីបញ្ជូន។ សម្រាប់អ្នកដែលមានតួនាទីគ្រប់គ្រងទូទៅនិងសម្របសម្រួល ពួកគេគួរតែត្រូវបានផ្តល់ការបណ្តុះបណ្តាលជាក់លាក់ទៅនឹងបរិបទនិងតម្រូវការរបស់ពួកគេដោយជ្រើសរើសម៉ូឌុលពាក់ព័ន្ធនៅពេលដែលពួកគេត្រូវបានអភិវឌ្ឍដោយមិនចាំបាច់ត្រូវបានបញ្ជាក់។

តារាងទី១១៖ ប្រភេទនិងកម្រិតវិញ្ញាបនបត្រដែលត្រូវការសម្រាប់កម្លាំងសេវាសង្គមនៅកម្ពុជា

| សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ | ប្រភេទកម្លាំងសេវាសង្គម | ស្ថាប័ន/អង្គភាព (នាក់) | ក្រេឌីត | សេចក្តីពន្យល់ពីក្រេឌីតម៉ោង |
|---|---|---|---|---|
| សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ៣ | អ្នកអាជីពសង្គមកិច្ចវង (បុគ្គលិកសង្គមប៉ាអាជីព) | កម្លាំងសេវាសង្គមចំនួន ៥០០នាក់ (រួមទាំងមន្ត្រីទទួលបន្ទុកកិច្ចការពារកុមារចំនួន១១៨នាក់) ក្នុងចំណោមមន្ត្រីសរុបថ្នាក់ក្រសួង១២០២នាក់ | ៣០ ក្រេឌីត | ១៥ ម៉ោងសម្រាប់ ១ក្រេឌីត ត្រូវបានគេវាស់ជាបរិមាណនៃការបង្រៀន និង៣០ ម៉ោង សម្រាប់ ១ក្រេឌីត ត្រូវបានវាស់ជាចំនួននៃការពិសោធន៍/សិក្ខាសាលាការបង្រៀន និង ៤៥ម៉ោង សម្រាប់១ក្រេឌីត |
| សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ២ | អ្នកអាជីពសង្គមកិច្ចវង (បុគ្គលិកសង្គមប៉ាអាជីព) | កម្លាំងសេវាសង្គមចំនួន ៤៧១នាក់ (រួមទាំងមន្ត្រីទទួលបន្ទុកកិច្ចការពារកុមារចំនួន ១២៥នាក់) ក្នុងចំណោម | ៣០ ក្រេឌីត | |

| សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ | ប្រភេទកម្លាំងសេវាសង្គម | ស្ថាប័ន/អង្គភាព<br>(នាក់) | ក្រេឌីត | សេចក្តីពន្យល់ពីក្រេឌីតម៉ោង |
|---|---|---|---|---|
| | | មន្ត្រីសរុបថ្នាក់មន្ទីរ ស.អ.យ ចំនួន **១០៥៧នាក់** | | ត្រូវបានគេវាស់ជាបរិមាណនៃការងារទីវាលនិងកម្មសិក្សា |
| សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ១ | អ្នកអាជីពសង្គមកិច្ចរង (បុគ្គលិកសង្គមប៉ារ៉ាអាជីព) | មន្ត្រីទទួលបន្ទុកការងារ ស.អ.យ នៃការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម ក្រុង ស្រុក ខណ្ឌចំនួន **៤០៦នាក់** | ៣០ ក្រេឌីត | |
| | | បុគ្គលិកកិច្ចការពារកុមារ នៃអង្គការមិនមែនរដ្ឋាភិបាលចំនួន**១១៧០នាក់** | | |
| វិញ្ញាបនបត្រវិជ្ជាជីវៈ | អ្នកសង្គមកិច្ចមិនអាជីព (បុគ្គលិកសង្គមប៉ារ៉ាវិជ្ជាជីវៈ) | **គ.ក.ន.ក** ឃុំ សង្កាត់ មន្ត្រីទទួលបន្ទុកកិច្ចការពារកុមារ ចំនួន **៣,៧៩២នាក់** | ៣០ ក្រេឌីត | យន្តការដែលមានរួចសម្រាប់វាយតម្លៃសមត្ថភាពដែលនិស្សិតអាចទទួលបានរួចហើយតាមរយៈបទពិសោធន៍នៅកន្លែងធ្វើការ និងពេលវេលាទាំងនេះអាចត្រូវបានកាត់បន្ថយតាមរយៈការវាយតម្លៃជាផ្លូវការសម្រាប់ការទទួលស្គាល់ការរៀនមុន (RPL)និងការទទួលស្គាល់សមត្ថភាពបច្ចុប្បន្ន (RCC) |
| | | **គ.ក.ស.ក** ក្រុង ស្រុក ខណ្ឌ មន្ត្រីទទួលបន្ទុកកិច្ចការពារកុមារ ចំនួន **៦០៩នាក់** | | |
| | | **គ.ក.ស.ក** រាជធានី ខេត្ត មន្ត្រីទទួលបន្ទុកកិច្ចការពារកុមារ ចំនួន **១២៥នាក់** | | |
| វិញ្ញាបនបត្រ | អ្នកសង្គមកិច្ចសម្ព័ន្ធ (បុគ្គលិកសម្ព័ន្ធសង្គមកិច្ច) | ការបង្ការទប់ស្កាត់ ប្រព័ន្ធអន្តរាគមន៍ និងប្រព័ន្ធឆ្លើយតបនិងផ្តល់សេវា មន្ត្រីសម្ព័ន្ធសង្គមកិច្ចទទួលបន្ទុកកិច្ចការពារកុមារ[63]ចំនួន **២៥០នាក់** | រយៈពេល ១៥ថ្ងៃ | ជ្រើសរើសម៉ូឌុលពាក់ព័ន្ធសម្រាប់បណ្តុះបណ្តាលបុគ្គលិកសម្ព័ន្ធសង្គមកិច្ច |
| | | គណៈកម្មាធិការដឹកនាំដោយក្រសួងស្ថាប័ន៖[64]គ.ជ.ព,គ.ជ.ប.ជ, គ.ជ.គ.ក និង គ.ជ.ប.ទ មន្ត្រីទទួលបន្ទុកកិច្ចការពារកុមារចំនួន **៤០នាក់** | | |

[63]គោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ ២០១៩-២០២៩ មានសវស្តម្ភចំនួន៣គឺ៖ (១).ការបង្ការទប់ស្កាត់ក្នុងកិច្ចការពារកុមារ រួមមាន៖ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងព័ត៌មាន ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងសភាពាណិជ្ជកម្មកម្ពុជា ក្រសួងធម្មការនិងសាសនា ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងមហាផ្ទៃ និងក្រសួងកិច្ចការនារី(២).ប្រព័ន្ធអន្តរាគមន៍រួមមាន៖ក្រសួងយុត្តិធម៌ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ អគ្គស្នងការនគរបាលជាតិ បណ្ឌិត្យសភានគរបាលកម្ពុជា កងរាជអាវុធហត្ថលើផ្ទៃប្រទេស នាយកដ្ឋានអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នៃក្រសួងមហាផ្ទៃ(៣).ប្រព័ន្ធឆ្លើយតបនិងផ្តល់សេវា រួមមាន៖ក្រសួងអប់រំ ក្រសួងសុខាភិបាល ក្រសួងមហាផ្ទៃ សួងយុត្តិធម៌និងគណៈមេធាវីកម្ពុជា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងកាកបាទក្រហមកម្ពុជា

[64]លើកលែងតែគណៈកម្មការដឹកនាំអនុវត្តផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ និងគណៈកម្មការការពារកុមារថ្នាក់ជាតិ ដែលប្រើប្រាស់មន្ត្រីរបស់នាយកដ្ឋានសុខុមាលភាពកុមារ នៃក្រសួង ស.អ.យ និងអគ្គលេខាធិការដ្ឋាន ក.ជ.ក

| សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ | ប្រភេទកម្លាំងសេវាសង្គម | ស្ថាប័ន/អង្គភាព (នាក់) | ក្រេឌីត | សេចក្តីពន្យល់ពីក្រេឌីតម៉ោង |
|---|---|---|---|---|
| | | ក្រុមការងារដើម្បីកុមារនៅតាមក្រសួង-ស្ថាប័នមន្ត្រីទទួលបន្ទុកកិច្ចការពារកុមារចំនួន **២៧នាក់** | | |

## ៤.៥. គោលដៅយុទ្ធសាស្ត្រ

ដើម្បីដោះស្រាយបញ្ហាខាងលើ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលមានវិទ្យាស្ថានជាតិសង្គមកិច្ច សហការជាមួយ UNICEF អង្គការមិនមែនរដ្ឋាភិបាល គ្រឹះស្ថានអប់រំ និងអ្នកពាក់ព័ន្ធ បានរៀបចំផែនការយុទ្ធសាស្ត្រដើម្បីបណ្តុះបណ្តាលកម្លាំងសេវាសង្គម ផ្តោតលើកិច្ចការពារកុមារឆ្នាំ២០២១-២០២៥ មានគោលដៅយុទ្ធសាស្ត្រចំនួន៣៖ (១)អភិវឌ្ឍកម្មវិធីនិងកញ្ចប់មេរៀនសម្រាប់បណ្តុះបណ្តាលកម្លាំងសេវាសង្គម (២)បណ្តុះបណ្តាលកម្លាំងសេវាសង្គមនិងបង្កើនប្រសិទ្ធភាព (៣)ពង្រឹងសមត្ថភាពគ្រឹះស្ថានអប់រំនិងបណ្តុះបណ្តាលកម្លាំងសេវាសង្គម ដែលរៀបរាប់លម្អិតដូចខាងក្រោម៖

| គោលដៅយុទ្ធសាស្ត្រទី១៖ | **អភិវឌ្ឍកម្មវិធី និងកញ្ចប់មេរៀនសម្រាប់បណ្តុះបណ្តាលកម្លាំងសេវាសង្គម** |
|---|---|
| គោលបំណង៖ | គ្រឹះស្ថានអប់រំ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេសគួររៀបចំកម្មវិធីបណ្តុះបណ្តាលនិងកញ្ចប់មេរៀនបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពកម្លាំងសេវាសង្គមដោយផ្តោតលើប្រភេទកម្លាំងសេវាសង្គមដែលមានមុខងារទាក់ទងនឹងការផ្តល់សេវាកិច្ចការពារកុមារ និងសុខុមាលភាពសង្គម។ |
| **លទ្ធផលរំពឹងទុក៖** | កម្មវិធី និងកញ្ចប់មេរៀនបណ្តុះបណ្តាលត្រូវបានអភិវឌ្ឍទៅតាមតម្រូវការរបស់ប្រភេទកម្លាំងសេវាសង្គម និងកម្រិតគុណវុឌ្ឍិ ដោយផ្តោតលើកិច្ចការពារកុមារ។ |

ចង្កោមសកម្មភាព និងសកម្មភាពអនុវត្ត៖

| ល.រ | ចង្កោមសកម្មភាព | | សកម្មភាពអនុវត្ត |
|---|---|---|---|
| ១.១ | ការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលសម្រាប់កម្រិតវិញ្ញាបនបត្រវិជ្ជាជីវៈ និងសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១ ២ និង៣ | ១.១.១ | ពិនិត្យមុខងារចំណុចទី១.៥ ទី២ និងភាពខ្វះចន្លោះសមត្ថភាពរបស់មន្ត្រីពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ |
| | | ១.១.២ | ពិនិត្យមើលកម្មវិធីបណ្តុះបណ្តាលដែលបានរៀបចំដោយក្រសួង ស.អ.យ NISA RUPP SPI និងអង្គការមិនមែនរដ្ឋាភិបាលកន្លងមករួមទាំងកម្មវិធីបណ្តុះបណ្តាល BSST PSST MSST |
| | | ១.១.៣ | ពិនិត្យ និងវិភាគលើកម្មវិធីបណ្តុះបណ្តាលដែលបានកំណត់ដោយ IFSW,IASSW និងគ្រឹះស្ថានអប់រំ ASEAN និងអន្តរជាតិ |
| | | ១.១.៤ | ពិនិត្យសូចនាករនៅក្នុងគោលការណ៍ណែនាំស្តីពីសមត្ថភាពមូលដ្ឋានសម្រាប់កម្លាំងសេវាសង្គម ក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា និងមុខងាររបស់អង្គភាពឬស្ថាប័នដើម្បីជាមូលដ្ឋានសម្រាប់បង្កើតកម្មវិធីបណ្តុះបណ្តាល |
| | | ១.១.៥ | រៀបចំបង្កើតកម្មវិធីបណ្តុះបណ្តាលសម្រាប់ វិញ្ញាបនបត្រវិជ្ជាជីវៈ សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១ ២ និង៣ |
| ១.២ | | ១.២.១ | រៀបចំកញ្ចប់មេរៀន៖ កម្រិតវិញ្ញាបនបត្រវិជ្ជាជីវៈ សម្រាប់បណ្តុះបណ្តាល បុគ្គលិកសង្គមប៉ារ៉ាវិជ្ជាជីវៈ |

| ល.រ | ចង្កោមសកម្មភាព | | សកម្មភាពអនុវត្ត |
|---|---|---|---|
| | ការអភិវឌ្ឍកញ្ចប់មេរៀនសម្រាប់កម្លាំងសេវាសង្គមដោយផ្តោតលើកិច្ចការពារកុមារផ្អែកលើកម្មវិធីបណ្តុះបណ្តាល | ១.២.២ | រៀបចំកញ្ចប់មេរៀន៖ កម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ កម្រិតទី១ សម្រាប់បណ្តុះបណ្តាល បុគ្គលិកសង្គមប៉ារ៉ាអាជីព |
| | | ១.២.៣ | រៀបចំកញ្ចប់មេរៀន៖ កម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ កម្រិតទី២ សម្រាប់បណ្តុះបណ្តាលបុគ្គលិកសង្គមប៉ារ៉ាអាជីព |
| | | ១.២.៤ | រៀបចំកញ្ចប់មេរៀន៖ កម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ កម្រិតទី៣ សម្រាប់បណ្តុះបណ្តាលបុគ្គលិកសង្គមប៉ារ៉ាអាជីព |
| | | ១.២.៥ | ជ្រើសរើសមេរៀន៖ កម្រិតវិញ្ញាបនបត្រ សម្រាប់បណ្តុះបណ្តាលបុគ្គលិកសម្ព័ន្ធសង្គមកិច្ច |

| គោលដៅយុទ្ធសាស្ត្រទី២៖ | បណ្តុះបណ្តាលកម្លាំងសេវាសង្គម និងបង្កើនប្រសិទ្ធភាព |
|---|---|
| **គោលបំណង៖** | គ្រឹះស្ថានអប់រំ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេស រៀបចំផែនការដើម្បីបណ្តុះបណ្តាលកម្លាំងសេវាសង្គម៖១.បុគ្គលិកសង្គមអាជីព ២.បុគ្គលិកសង្គមប៉ារ៉ាអាជីព ៣.បុគ្គលិកសង្គមប៉ារ៉ាវិជ្ជាជីវៈ និង៤.បុគ្គលិកសម្ព័ន្ធសង្គមកិច្ចជាពិសេសផ្តោតលើក្រុមគោលដៅនៅក្នុងតារាងទី១១។ |
| **លទ្ធផលរំពឹងទុក៖** | កម្លាំងសេវាសង្គមគ្រប់រូបមានចំណេះដឹងជំនាញ និងអាកប្បកិរិយាចាំបាច់ ព្រមទាំងគុណវុឌ្ឍិ និងក្រមសីលធម៌វិជ្ជាជីវៈ ស្របតាមគោលការណ៍ណែនាំស្តីពីសមត្ថភាពមូលដ្ឋានសម្រាប់កម្លាំងសេវាសង្គមឆ្នាំ២០១៩ ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជាឆ្នាំ២០១៤ និងមុខងាររបស់មន្ត្រីដែលបានកំណត់។ |

ចង្កោមសកម្មភាព និងសកម្មភាពអនុវត្ត៖

| ល.រ | ចង្កោមសកម្មភាព | | សកម្មភាពអនុវត្ត |
|---|---|---|---|
| ២.១ | រៀបចំផែនការបណ្តុះបណ្តាលកម្លាំងសេវាសង្គមផ្អែកលើតារាងទី១១ | ២.១.១ | សហការជាមួយស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស ដើម្បីសិក្សារៀបចំផែនការបណ្តុះបណ្តាលកម្លាំងសេវាសង្គម |
| | | ២.១.២ | បង្កើតក្រុមគ្រូបង្គោល និងគ្រូជំនាញដែលមានសមាសភាពមកពីគ្រឹះស្ថានអប់រំ អង្គភាពចំណុះក្រសួង ស.អ.យ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេស |
| ២.២ | តម្រឹមកម្មវិធីបណ្តុះបណ្តាលកម្លាំងសេវាសង្គមឱ្យស្របតាមអាទិភាពនិងតម្រូវការជាក់ស្តែង | ២.២.១ | រៀបចំកម្មវិធីបណ្តុះបណ្តាលឱ្យស្របទៅនឹងស្ថានភាពជាក់ស្តែងនៃកម្លាំងសេវាសង្គម និងស្របតាមគុណវុឌ្ឍិកម្រិតវិញ្ញាបនបត្រវិជ្ជាជីវៈ សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១ ២ និង៣ |
| | | ២.២.២ | រៀបចំប្រព័ន្ធ(ក្រេឌីតអនឡាញ)សម្រាប់បណ្តុះបណ្តាលមន្ត្រីរាជការស៊ីវិល និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលដែលមានបំណងបន្តការសិក្សា |
| ២.៣ | បណ្តុះបណ្តាលកម្លាំងសេវាសង្គមកម្រិត វិញ្ញាបនបត្រ វិជ្ជាជីវៈ សញ្ញាបត្របច្ចេក | ២.៣.១ | រៀបចំផែនការបណ្តុះបណ្តាលកម្លាំងសេវាសង្គមដែលជាមន្ត្រីរាជការនិងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស |
| | | ២.៣.២ | បណ្តុះបណ្តាលបុគ្គលិកសង្គមប៉ារ៉ាវិជ្ជាជីវៈ កម្រិតវិញ្ញាបនបត្រវិជ្ជាជីវៈ |

| ល.រ | ចង្កោមសកម្មភាព | | សកម្មភាពអនុវត្ត |
|---|---|---|---|
| | ទេសនិងវិជ្ជាជីវៈ១ ២ និង៣ | ២.៣.៣ | បណ្តុះបណ្តាលបុគ្គលិកសង្គមប៉ារ៉ាអាជីព កម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១ |
| | | ២.៣.៤ | បណ្តុះបណ្តាលបុគ្គលិកសង្គមប៉ារ៉ាអាជីពកម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ២ |
| | | ២.៣.៥ | បណ្តុះបណ្តាលបុគ្គលិកសង្គមប៉ារ៉ាអាជីព កម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ៣ |
| | | ២.៣.៦ | បណ្តុះបណ្តាលបុគ្គលិកសម្ព័ន្ធសង្គមកិច្ច កម្រិតវិញ្ញាបនបត្រស្តីពីកិច្ចការពារកុមារ |

| | |
|---|---|
| **គោលដៅយុទ្ធសាស្ត្រទី៣៖** | **ពង្រឹងសមត្ថភាពគ្រឹះស្ថានអប់រំ បណ្តុះបណ្តាលកម្លាំងសេវាសង្គម** |
| **គោលបំណង៖** | អភិវឌ្ឍសមត្ថភាពគ្រឹះស្ថានអប់រំ បណ្តុះបណ្តាល និងបំពាក់គរុកោសល្យ ចំណេះដឹង និងជំនាញការងារសង្គមកិច្ចដល់គ្រូបង្គោល និងគ្រូជំនាញឆ្លើយតបនឹងតម្រូវការជាក់ស្តែង និងទ្រឹស្តីរបស់សហព័ន្ធការងារសង្គមកិច្ចអន្តរជាតិ(IFSW) ឬសមាគមសាលាសង្គមកិច្ចអន្តរជាតិ(IASSW) គោលការណ៍ណែនាំស្តីពីសមត្ថភាពមូលដ្ឋានសម្រាប់កម្លាំងសេវាសង្គម និងក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា។ |
| **លទ្ធផលរំពឹងទុក៖** | គ្រឹះស្ថានអប់រំ និងអង្គភាពបណ្តុះបណ្តាលកម្លាំងសេវាសង្គមមានសមត្ថភាពនិងធនធានគ្រប់គ្រាន់សម្រាប់បណ្តុះបណ្តាលកម្លាំងសេវាសង្គម។ |

ចង្កោមសកម្មភាព និងសកម្មភាពអនុវត្ត៖

| ល.រ | ចង្កោមសកម្មភាព | | សកម្មភាពអនុវត្ត |
|---|---|---|---|
| ៣.១ | រៀបចំផែនទីសមត្ថភាពគ្រូជំនាញ និងគ្រូបង្គោលការងារសង្គមកិច្ចនិងកិច្ចការពារកុមារ | ៣.១.១ | ពិនិត្យ និងវិភាគកម្រិតគុណវុឌ្ឍិចំណេះដឹងនិងជំនាញវិជ្ជាជីវៈការងារសង្គមកិច្ចនិងកិច្ចការពារកុមាររបស់មន្ត្រីរាជការដែលកំពុងបម្រើការនៅតាមអង្គភាពពាក់ព័ន្ធ |
| | | ៣.១.២ | ពិនិត្យ និងវិភាគកម្រិតគុណវុឌ្ឍិចំណេះដឹងនិងជំនាញវិជ្ជាជីវៈសង្គមកិច្ចនិងកិច្ចការពារកុមាររបស់មន្ត្រីអង្គការមិនមែនរដ្ឋាភិបាល |
| | | ៣.១.៣ | ពិនិត្យ និងវិភាគអំពីគុណវុឌ្ឍិបុគ្គលិកអប់រំនៅ NISA និងគ្រឹះស្ថានអប់រំផ្សេងទៀត រួមទាំងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេសដើម្បីធានាគុណភាពបណ្តុះបណ្តាលកម្លាំងសេវាសង្គម |
| | | ៣.១.៤ | សិក្សាអំពីធនធានថវិការបស់វិទ្យាស្ថានជាតិសង្គមកិច្ច គ្រឹះស្ថានអប់រំ និងអង្គការមិនមែនរដ្ឋាភិបាលសម្រាប់អប់រំកម្លាំងសេវាសង្គម |
| | | ៣.១.៥ | រៀបចំរបាយការណ៍ស្តីពីផែនទីសមត្ថភាពគ្រូបង្គោល គ្រូជំនាញ និងធនធានគ្រឹះស្ថានអប់រំ និងអង្គភាពមិនមែនរដ្ឋាភិបាល |
| ៣.២ | ពង្រឹងសមត្ថភាពគរុកោសល្យ និងចំណេះដឹងសង្គមកិច្ចដល់គ្រូជំនាញ និងគ្រូបង្គោល | ៣.២.១ | រៀបចំកម្មវិធីពង្រឹងសមត្ថភាពគរុកោសល្យគ្រូបង្គោល និងគ្រូជំនាញការងារសង្គមកិច្ចនៅតាមគ្រឹះស្ថានអប់រំសង្គមកិច្ចវិទ្យា |
| | | ៣.២.២ | បង្កើនសមត្ថភាពផ្នែកគរុកោសល្យ ចំណេះដឹង និងជំនាញការងារសង្គមកិច្ចដល់គ្រូបង្គោល និងគ្រូជំនាញ |

| ល.រ | ចង្កោមសកម្មភាព | | សកម្មភាពអនុវត្ត |
|---|---|---|---|
| | | ៣.២.៣ | បណ្តុះបណ្តាលគ្រូបង្គោល និងគ្រូជំនាញលើប្រធានបទថ្មីដែលបង្កើតឡើងដោយ IASSW, IFSW និងលិខិតបទដ្ឋានគតិយុត្ត ដែលធ្វើបច្ចុប្បន្នភាព និងបង្កើតថ្មី |
| | | ៣.២.៤ | រៀបចំកម្មវិធីផ្លាស់ប្តូរបទពិសោធន៍ការអប់រំបណ្តុះបណ្តាលកម្លាំងសេវាសង្គមជាមួយបណ្តាប្រទេសក្នុងតំបន់ និងពិភពលោក |
| ៣.៣ | ពង្រឹងសមត្ថភាពគ្រឹះស្ថានអប់រំបណ្តុះបណ្តាលកម្លាំងសេវាសង្គមនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ | ៣.៣.១ | បង្កើតក្រុមគ្រូបង្គោល និងក្រុមគ្រូជំនាញដើម្បីទទួលបន្ទុកបណ្តុះបណ្តាលកម្លាំងសេវាសង្គមនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ |
| | | ៣.៣.២ | រៀបចំយន្តការបន្ថែមក្នុងការបង្កើតសមាគមគ្រូសង្គមកិច្ចវិទ្យា ដើម្បីសម្របសម្រួលជំនាញសង្គមកិច្ចវិទ្យា និងជំរុញឱ្យមានការទទួលស្គាល់វិជ្ជាជីវៈសង្គមកិច្ច |
| | | ៣.៣.៣ | បញ្ចូលកម្មវិធីបណ្តុះបណ្តាលកម្លាំងសេវាសង្គមទៅក្នុងកម្មវិធីសិក្សារបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន |
| | | ៣.៣.៤ | បញ្ចូលគម្រោងចំណាយទៅក្នុងផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធីដើម្បីគាំទ្រការពង្រឹងសមត្ថភាពមន្ត្រីរាជការលើជំនាញសុខុមាលភាពសង្គមនិងកិច្ចការពារកុមារ |
| | | ៣.៣.៥ | បង្កើតប្រព័ន្ធគ្រប់ទិន្នន័យកម្លាំងសេវាសង្គម១.បុគ្គលិកសង្គមប៉ារ៉ាវិជ្ជាជីវៈ ២.បុគ្គលិកសង្គមប៉ារ៉ាអាជីព ៣.បុគ្គលិកសម្ព័ន្ធសង្គមកិច្ច និង ៤.បុគ្គលិកសង្គមអាជីព |

## ៥. ការរៀបចំស្ថាប័នសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រ

វិទ្យាស្ថានជាតិសង្គមកិច្ចបង្កើតឡើងអនុក្រឹត្យក្រឹត្យលេខ ២៣៣ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ ស្តីពីការបង្កើតវិទ្យាស្ថានជាតិសង្គមកិច្ចមានបេសកកម្មបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្ររង បរិញ្ញាបត្រលើមុខជំនាញសង្គមកិច្ច វិស្វកម្មឧបករណ៍សិប្បនិម្មិតនិងរណប និងវិជ្ជាជីវៈសង្គមកិច្ច រួមទាំងធ្វើការស្រាវជ្រាវលើផ្នែកសង្គមកិច្ច ឆ្លើយតបទៅនឹងតម្រូវការប្រទេសជាតិ។[65] ប្រកាសលេខ ៧២៥ ស.អ.យ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១២ ឆ្នាំស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់វិទ្យាស្ថានជាតិសង្គមកិច្ច មានបេសកកម្មដូចជាៈ ១.សិក្សាស្រាវជ្រាវអំពើវិទ្យាសាស្ត្រសង្គមនិងផែនការយុទ្ធសាស្ត្រ អភិវឌ្ឍផ្នែកសង្គមកិច្ចដើម្បីផ្តល់នូវគោលនយោបាយអភិវឌ្ឍលើវិស័យសង្គមកិច្ច ២.អប់រំបណ្តុះបណ្តាលធនធានមនុស្សលើវិស័យសង្គមកិច្ចនិងវិស័យផ្សេងទៀតដោយភ្ជាប់នឹងតម្រូវការរបស់សង្គមកិច្ច ៣.គ្រប់គ្រងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈរយៈពេលខ្លី ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ៤.សហការជាមួយអង្គភាពពាក់ព័ន្ធផ្តល់ការបណ្តុះបណ្តាលរយៈពេលខ្លី ការបើកវគ្គផ្សព្វផ្សាយ និងសិក្ខាសាលាតាមជំនាញនានា និង៥.ទំនាក់ទំនង ពង្រឹងពង្រីកសហប្រតិបត្តិការ និងសមាហរណកម្មលើកម្មវិធីអប់រំបណ្តុះបណ្តាលជាមួយស្ថាប័នជាតិ អន្តរជាតិ ទាំងក្នុងក្របខណ្ឌជាតិ តំបន់ និងពិភពលោក ព្រមទាំងកៀគរប្រភពធនធាន សម្ភារ បច្ចេកទេសដើម្បីអភិវឌ្ឍវិទ្យាស្ថាន។[66]

[65] មាត្រា ២ និងមាត្រា ៦ នៃអនុក្រឹត្យលេខ ២៣៣ ស្តីពីការបង្កើតវិទ្យាស្ថានជាតិសង្គមកិច្ច

[66] ប្រការ ២ នៃប្រកាសលេខ ៧២៥ ស.អ.យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់វិទ្យាស្ថានជាតិសង្គមកិច្ច

វិទ្យាស្ថានជាតិសង្គមកិច្ចជាសេនាធិការឱ្យក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាមានភារកិច្ចទទួលខុសត្រូវនិងសម្របសម្រួលជាមួយនាយកដ្ឋាន អង្គភាពចំណុះក្រសួង អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេស ដៃគូអភិវឌ្ឍន៍ គ្រឹះស្ថានអប់រំដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រនេះឱ្យទទួលបានប្រសិទ្ធិភាពនិងប្រសិទ្ធិផលប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

# ៦. យុទ្ធសាស្ត្រគៀរគរហិរញ្ញប្បទាន និងតម្រូវការថវិកា

## ៦.១. យុទ្ធសាស្ត្រគៀគរហិរញ្ញប្បទាន

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នឹងលើកគម្រោងចំណាយដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធីប្រចាំឆ្នាំដើម្បីស្នើសុំថវិកាជាតិគាំទ្រសកម្មភាព។ ក្រសួង ស.អ.យ បានយកចិត្តទុកដាក់លើភាពជាដៃគូក្នុងកិច្ចសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធនានាដែលធ្វើសកម្មភាពរបស់ខ្លួនលើការបណ្តុះបណ្តាលកម្លាំងសេវាសង្គម ដើម្បីស្នើសុំការគាំទ្រទាំងថវិកា និងបច្ចេកទេសដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រនេះឱ្យសម្រេចបានជោគជ័យ។

## ៦.២. តម្រូវការថវិកាសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រ

ផែនការយុទ្ធសាស្ត្រដើម្បីបណ្តុះបណ្តាលកម្លាំងសេវាសង្គមនេះ រួមមានការប៉ាន់ប្រមាណថ្លៃចំណាយនៅឧបសម្ព័ន្ធទី១ នឹងជួយផ្តល់ជាព័ត៌មានមូលដ្ឋានសម្រាប់នីតិវិធីគណនាថ្លៃចំណាយក្នុងផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធីប្រចាំឆ្នាំ។ ក្រសួងនឹងលើកសកម្មភាព និងគម្រោងចំណាយនៅក្នុងថវិកាកម្មវិធីសម្រាប់ថវិកាជាតិ និងស្នើសុំការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន។ ការប៉ាន់ប្រមាណថ្លៃចំណាយសម្រាប់សកម្មភាពជាយុទ្ធសាស្ត្ររយៈពេលវែងប្រាំឆ្នាំ(៥ឆ្នាំ)ជួយគាំទ្រដល់ការអនុវត្តតាមរយៈការជួយកំណត់ពីរបៀបក្នុងការវិភាជន៍ថវិកាដ៏ប្រសើរបំផុតនិងចាត់អាទិភាពទៅលើធនធានដែលមានកម្រិតនិងតាមរយៈការកំណត់រកចន្លោះប្រហោងធនធានដើម្បីធ្វើការចង្អុលទិសចំពោះសកម្មភាពស្វែងរកមូលនិធិ។ ផែនការយុទ្ធសាស្ត្រនេះត្រូវការថវិកាគាំទ្រចំនួនប្រមាណ ១៦.៧១១.៧២០ USD ទាំងថវិការដ្ឋ និងថវិកាដៃគូដើម្បីចំណាយតាមគោលដៅយុទ្ធសាស្ត្រក្នុងរយៈពេល៥ឆ្នាំ(២០២១-២០២៥) ដូចមានចែងនៅក្នុងតារាងទី១២ ខាងក្រោម៖

តារាងទី១២៖ តារាងតម្រូវការថវិកាសម្រាប់អនុវត្តគោលដៅយុទ្ធសាស្ត្រឆ្នាំ២០២១-២០២៥

| ល.រ | គោលដៅយុទ្ធសាស្ត្រ | ប៉ាន់ប្រមាណតម្រូវការថវិកា(USD) | | |
|---|---|---|---|---|
| | | សរុបរួម | ថវិការដ្ឋ | ថវិកាដៃគូ |
| ១ | អភិវឌ្ឍកម្មវិធី និងកញ្ចប់មេរៀនសម្រាប់បណ្តុះបណ្តាលកម្លាំងសេវាសង្គម | ៩៩.០០០ | ៤០% | ៦០% |
| ២ | បណ្តុះបណ្តាលកម្លាំងសេវាសង្គម និងបង្កើនប្រសិទ្ធភាព | ១៦.៣៨៦.៧២០ | ៣០% | ៧០% |
| ៣ | ពង្រឹងសមត្ថភាពគ្រឹះស្ថានអប់រំបណ្តុះបណ្តាលកម្លាំងសេវាសង្គម | ២២៦.០០០ | ៤០% | ៦០% |
| | សរុបថវិកាចំណាយរួម | ១៦.៧១១.៧២០ | ៣៦.៧% | ៦៣.៣% |

## ៧. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

ដើម្បីឱ្យការអនុវត្តផែនការយុទ្ធសាស្ត្រដើម្បីបណ្តុះបណ្តាលកម្លាំងសេវាសង្គម ២០២១-២០២៥ សម្រេចបានតាមគោលដៅយុទ្ធសាស្ត្រ លទ្ធផលរំពឹងទុក និងចំណុចដៅនៃសូចនាករដែលបានកំណត់។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នឹងបង្កើតប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃមួយជាក់លាក់សម្រាប់វាស់វែងវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រ។ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃផែនការយុទ្ធសាស្ត្រគឺជាការងារដ៏សំខាន់តម្រូវឱ្យក្រសួងរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ ដោយមានការពិគ្រោះយោបល់គ្រប់ជ្រុងជ្រោយជាមួយអ្នកពាក់ព័ន្ធនានាផ្អែកលើផែនការយុទ្ធសាស្ត្រនេះ។

### ៧.១. ត្រួតពិនិត្យតាមដាន

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នឹងតាមដានត្រួតពិនិត្យវឌ្ឍនភាពសម្រេចបានក្នុងការអនុវត្តយុទ្ធសាស្ត្រប្រចាំឆ្នាំនីមួយៗធៀបទៅនឹងលទ្ធផលរំពឹងទុក និងចំណុចដៅនៃសូចនាករ និងធនធានប្រចាំឆ្នាំ។ ការតាមដានត្រួតពិនិត្យត្រូវផ្អែកលើឧបករណ៍ដូចជាផែនការសកម្មភាពនិងរបាយការណ៍ប្រចាំឆ្នាំ។ វិទ្យាស្ថានជាតិសង្គមកិច្ចនឹងធ្វើរបាយការណ៍ពីលទ្ធផលតាមដានត្រួតពិនិត្យប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីកែលម្អ និងផ្តល់អនុសាសន៍។

### ៧.២. ការវាយតម្លៃ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានឹងវាយតម្លៃលទ្ធផលសម្រេចបានដោយផ្អែកលើសូចនាករដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រ។ ការវាយតម្លៃនឹងធ្វើចំនួន០២ដង គឺការវាយតម្លៃពាក់កណ្តាលអាណត្តិនៅឆមាសទី២ ឆ្នាំ២០២៣ និងការវាយតម្លៃបញ្ចប់អាណត្តិនៅឆមាសទី២ ឆ្នាំ២០២៥។ ការវាយតម្លៃនេះនឹងផ្អែកលើឧបករណ៍ដូចជា ផែនការសកម្មភាពប្រចាំឆ្នាំ និងរបាយការណ៍លទ្ធផលប្រចាំត្រីមាស ឆមាស ប្រចាំឆ្នាំនីមួយៗ របាយការណ៍វាយតម្លៃវឌ្ឍនភាពពាក់កណ្តាលអាណត្តិ និងរបាយការណ៍វាយតម្លៃវឌ្ឍនភាពបញ្ចប់អាណត្តិ ២០២១-២០២៥។

## ៨. សេចក្តីសន្និដ្ឋាន

ផែនការយុទ្ធសាស្ត្រដើម្បីបណ្តុះបណ្តាលកម្លាំងសេវាសង្គមឆ្នាំ ២០២១-២០២៥ ត្រូវបានរៀបចំកសាងឡើងនៅឆ្នាំ២០២០ ក្រោមការដឹកនាំពីនាយកវិទ្យាស្ថានជាតិសង្គមកិច្ច និងការចូលរួមពីអ្នកពាក់ព័ន្ធនានា ដោយមានការសម្របសម្រួលពិគ្រោះយោបល់និងពិភាក្សាគ្រប់ជ្រុងជ្រោយជាមួយភាគីពាក់ព័ន្ធនានា។ ផែនការយុទ្ធសាស្ត្រនេះ គឺជាផែនទីចង្អុលផ្លូវសម្រាប់អនុវត្តរបស់វិទ្យាស្ថានជាតិសង្គមកិច្ច គ្រឹះស្ថានអប់រំ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធ ដើម្បីរួមចំណែកអនុវត្ត យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ២០១៩-២០២៣ ក្របខ័ណ្ឌគុណវុឌ្ឍិជាតិ ២០១៤ និងឯកសារពាក់ព័ន្ធជាតិ និងអន្តរជាតិនានា។

ផែនការយុទ្ធសាស្ត្រនេះគ្របដណ្តប់លើគោលដៅយុទ្ធសាស្ត្រចំនួន៣គឺ៖១.អភិវឌ្ឍកម្មវិធី និងកញ្ចប់មេរៀនសម្រាប់បណ្តុះបណ្តាលកម្លាំងសេវាសង្គម ២.បណ្តុះបណ្តាលកម្លាំងសេវាសង្គមនិងបង្កើនប្រសិទ្ធភាព ៣.ពង្រឹងសមត្ថភាពគ្រឹះស្ថានអប់រំបណ្តុះបណ្តាលកម្លាំងសេវាសង្គម។ ផែនការយុទ្ធសាស្ត្រនេះតម្រូវឱ្យមានការចូលរួមគាំទ្រពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គ្រឹះស្ថានអប់រំ និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធនានា ដើម្បីធ្វើឱ្យសម្រេចបាននូវសូចនាករដែលបានលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្រនេះ។

## ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១៖ តារាងម៉ាទ្រីច ចង្កោមសកម្មភាព សកម្មភាព និងសូចនាករលទ្ធផល**

## ឧបសម្ព័ន្ធទី១៖ តារាងម៉ាទ្រីច ចង្កោមសកម្មភាព សកម្មភាព និងសូចនាករលទ្ធផល

### គោលដៅយុទ្ធសាស្ត្រទី១៖អភិវឌ្ឍកម្មវិធី និងកញ្ចប់មេរៀនសម្រាប់បណ្តុះបណ្តាលកម្លាំងសេវាសង្គម

| ល.រ | ចង្កោមសកម្មភាព | សកម្មភាព | | ថវិកាចំណាយ (USD) | ពេលវេលាអនុវត្ត(ឆ្នាំ) | | | | | ស្ថាប័ន/អង្គភាពអនុវត្ត | សូចនាករលទ្ធផល |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ១ | ២ | ៣ | ៤ | ៥ | | |
| ១.១ | ការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលសម្រាប់កម្រិតវិញ្ញាបនបត្រវិជ្ជាជីវៈ និងសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១ ២ និង៣ | ១.១.១ | ពិនិត្យមុខងារចំណុចទី១.៥ ទី២ និងភាពខ្វះចន្លោះសម្ថភាពរបស់មន្រ្តីពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ[67] | 5000 | x | | | | | NISA អង្គភាពចំណុះក្រសួង ស.អ.យ | (១)កម្មវិធីបណ្តុះបណ្តាលសម្រាប់កម្រិតវិញ្ញាបនបត្រវិជ្ជាជីវៈ និងសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ១ ២ និង៣ ត្រូវបានបង្កើតឡើង |
| | | ១.១.២ | ពិនិត្យមើលកម្មវិធីបណ្តុះបណ្តាលដែលបានរៀបចំដោយក្រសួង ស.អ.យ NISA RUPP SPI និងអង្គការមិនមែនរដ្ឋាភិបាលកន្លងមករួមទាំងកម្មវិធីបណ្តុះបណ្តាល BSST PSST MSST | 5500 | x | | | | | NISA RUPP SPI | |
| | | ១.១.៣ | ពិនិត្យ និងវិភាគលើកម្មវិធីបណ្តុះបណ្តាលដែលបានកំណត់ដោយ IFSW,IASSW និងគ្រឹះស្ថានអប់រំ ASEAN និងអន្តរជាតិ | 6000 | x | | | | | NISA RUPP SPI NGOs | |
| | | ១.១.៤ | ពិនិត្យសូចនាករនៅក្នុងគោលការណ៍ណែនាំស្តីពីសមត្ថភាពមូលដ្ឋានសម្រាប់កម្លាំងសេវាសង្គម ក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា និងមុខងាររបស់អង្គភាពឬស្ថាប័នដើម្បីជាមូលដ្ឋានសម្រាប់បង្កើតកម្មវិធីបណ្តុះបណ្តាល | 7500 | x | | | | | NISA RUPP SPI NGOs | |

[67] (១) ចំណេះដឹងជំនាញនិងឥរិយាបទ ឬសមត្ថភាពពឹងទុកសម្រាប់មន្ត្រី (២)ធ្វើការវាស់ស្ទង់សមត្ថភាពរបស់មន្ត្រីជំនាញដើម្បីផ្តល់វគ្គបណ្តុះបណ្តាលដែលសាកសម្ប និង(៣)ត្រូវកំណត់លក្ខខ័ណ្ឌជាក់លាក់ ឬលក្ខណៈវិនិច្ឆ័យ (eligible criteria)ដើម្បីឱ្យមន្ត្រីណាម្នាក់អាចចូលរួមវគ្គបណ្តុះបណ្តាលសម្រាប់កម្រិតវិញ្ញាបនបត្រវិជ្ជាជីវៈ និងសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១ ២ និង៣

| ល.រ | ចង្កោមសកម្មភាព | សកម្មភាព | ថវិកាចំណាយ (USD) | ពេលវេលាអនុវត្ត(ឆ្នាំ) | | | | | ស្ថាប័ន/អង្គភាពអនុវត្ត | សូចនាករលទ្ធផល |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | |
| | | ១.១.៥ រៀបចំបង្កើតកម្មវិធីបណ្តុះបណ្តាលសម្រាប់វិញ្ញាបនបត្រវិជ្ជាជីវៈ សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១ ២ និង៣ | 15000 | x | | | | | NISA NGOs | |
| ១.២ | ការអភិវឌ្ឍកញ្ចប់មេរៀនសម្រាប់បណ្តុះបណ្តាលកម្លាំងសេវាសង្គមដោយផ្តោតលើកិច្ចការពារកុមារផ្អែកលើកម្មវិធីបណ្តុះបណ្តាល | ១.២.១ រៀបចំកញ្ចប់មេរៀន៖ កម្រិតវិញ្ញាបនបត្រវិជ្ជាជីវៈសម្រាប់បណ្តុះបណ្តាល "បុគ្គលិកសង្គមប៉ារ៉ាវិជ្ជាជីវៈ" | 12000 | x | | | | | NISA TWG | (២)កញ្ចប់មេរៀនសម្រាប់បណ្តុះបណ្តាលកម្លាំងសេវាសង្គម ស្របតាមគោលការណ៍ណែនាំស្តីពីសមត្ថភាពមូលដ្ឋានសម្រាប់កម្លាំងសេវាសង្គម ក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា និងមុខងាររបស់ស្ថាប័ន និងទទួលស្គាល់ពីក្រសួង ស.អ.យ និងក្រសួងអប់រំ យុវជន និងកីឡា។ |
| | | ១.២.២ បង្កើតកម្មវិធី និងកញ្ចប់មេរៀន៖ កម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈកម្រិតទី១ សម្រាប់បណ្តុះបណ្តាល "បុគ្គលិកសង្គមប៉ារ៉ាអាជីព" | 12000 | x | | | | | NISA TWG | |
| | | ១.២.៣ បង្កើតកម្មវិធី និងកញ្ចប់មេរៀន៖ កម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈកម្រិតទី២ សម្រាប់បណ្តុះបណ្តាល "បុគ្គលិកសង្គមប៉ារ៉ាអាជីព" | 12000 | x | | | | | NISA TWG | |
| | | ១.២.៤ បង្កើតកម្មវិធី និងកញ្ចប់មេរៀន៖ កម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈកម្រិតទី៣ សម្រាប់បណ្តុះបណ្តាល "បុគ្គលិកសង្គមប៉ារ៉ាអាជីព" | 12000 | x | | | | | NISA TWG | |
| | | ១.២.៥ ជ្រើសរើសមេរៀន៖កម្រិតវិញ្ញាបនបត្រសម្រាប់បណ្តុះបណ្តាលបុគ្គលិកសម្ព័ន្ធសង្គមកិច្ច | 12000 | | | | | | NISA TWG | |
| | | **សរុបថវិកាចំណាយសម្រាប់គោលដៅយុទ្ធសាស្ត្រទី១** | **99.000** | | | | | | | |

## គោលដៅយុទ្ធសាស្ត្រទី២៖ ការបណ្តុះបណ្តាលកម្លាំងសេវាសង្គម និងបង្កើនប្រសិទ្ធភាព

| ល.រ | ចង្កោមសកម្មភាព | សកម្មភាព | | ថវិកាចំណាយ (USD) | ពេលវេលាអនុវត្ត (ឆ្នាំ) | | | | | ស្ថាប័ន/អង្គភាពអនុវត្ត | សូចនាករលទ្ធផល |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ១ | ២ | ៣ | ៤ | ៥ | | |
| ២.១ | រៀបចំផែនការបណ្តុះបណ្តាលកម្លាំងសេវាសង្គមផ្អែកលើតារាងទី១១ | ២.១.១ | សហការជាមួយស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស ដើម្បីសិក្សារៀបចំផែនការបណ្តុះបណ្តាលកម្លាំងសេវាសង្គម | 20000 | x | | | | | NISA | (១)ផែនការបណ្តុះបណ្តាលកម្លាំងសេវាសង្គមផ្អែកលើតារាងទី១១ត្រូវបានរៀបចំបង្កើតឡើង។ |
| | | ២.១.២ | បង្កើតក្រុមគ្រូបង្គោល និងគ្រូជំនាញដែលមានសមាសភាពមកពីគ្រឹះស្ថានអប់រំ អង្គភាពចំណុះក្រសួង ស.អ.យ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេស | 16000 | x | | | | | NISA | |
| ២.២ | តម្រឹមកម្មវិធីបណ្តុះបណ្តាលកម្លាំងសេវាសង្គមឱ្យស្របតាមអាទិភាពនិងតម្រូវការជាក់ស្តែង | ២.២.១ | រៀបចំកម្មវិធីបណ្តុះបណ្តាលឱ្យស្របទៅនឹងស្ថានភាពជាក់ស្តែងនៃកម្លាំងសេវាសង្គម និងស្របតាមគុណវុឌ្ឍិកម្រិតវិញ្ញាបនបត្រវិជ្ជាជីវៈ សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១ ២ និង៣ | 15500 | | x | | | | NISA<br>TWG | (២)កម្មវិធីបណ្តុះបណ្តាលកម្លាំងសេវាសង្គមត្រូវបានតម្រឹមតាមស្ថានភាពនិងតម្រូវការជាក់ស្តែងរបស់មន្ត្រីរាជការ និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល។ |
| | | ២.២.២ | រៀបចំប្រព័ន្ធ(ក្រេឌីតអនឡាញ)សម្រាប់បណ្តុះបណ្តាលមន្ត្រីរាជការស៊ីវិល និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលដែលមានបំណងបន្តការសិក្សា | 45000 | | x | x | x | x | NISA | |
| ២.៣ | បណ្តុះបណ្តាលកម្លាំងសេវាសង្គមកម្រិត វិញ្ញាបនបត្រវិជ្ជាជីវៈ សញ្ញាបត្របច្ចេក | ២.៣.១ | រៀបចំផែនការបណ្តុះបណ្តាលកម្លាំងសេវាសង្គមដែលជាមន្ត្រីរាជការ និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស | 15000 | x | x | | | | NISA<br>TWG | (៣)កម្លាំងសេវាសង្គមមានចំណេះដឹងនិងជំនាញទទួលបានប័ណ្ណសំគាល់ជា៖ |

| ល.រ | ចង្កោមសកម្មភាព | សកម្មភាព | ថវិកាចំណាយ (USD) | ពេលវេលាអនុវត្ត(ឆ្នាំ) | | | | | ស្ថាប័ន/អង្គភាពអនុវត្ត | សូចនាករលទ្ធផល |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | |
| | ទេសនិងវិជ្ជាជីវៈ១ ២ ៣ | ២.៣.២ បណ្តុះបណ្តាលបុគ្គលិកសង្គមប៉ារ៉ាវិជ្ជាជីវៈ កម្រិតវិញ្ញាបនបត្រវិជ្ជាជីវៈ[68] | 11977350 | | x | x | x | x | NISA RUPP SPI NGOs | ១.បុគ្គលិកសង្គមប៉ារ៉ាវិជ្ជាជីវៈ ២.បុគ្គលិកសង្គមប៉ារ៉ាអាជីព ៣.បុគ្គលិកសម្ព័ន្ធសង្គមកិច្ច និង៤.បុគ្គលិកសង្គមអាជីព |
| | | ២.៣.៣ បណ្តុះបណ្តាលបុគ្គលិកសង្គមប៉ារ៉ាវិជ្ជាជីវៈ កម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១[69] | 1207850 | | x | x | x | x | NISA RUPP SPI NGOs | |
| | | ២.៣.៤ បណ្តុះបណ្តាលបុគ្គលិកសង្គមប៉ារ៉ាវិជ្ជាជីវៈ កម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ២[70] | 1401225 | | x | x | x | x | NISA RUPP SPI NGOs | |
| | | ២.៣.៥ បណ្តុះបណ្តាលបុគ្គលិកសង្គមប៉ារ៉ាវិជ្ជាជីវៈ កម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ៣[71] | 1487500 | | x | x | x | x | NISA RUPP SPI NGOs | |

[68] សិក្ខាកាមកម្រិតវិញ្ញាបនបត្រវិជ្ជាជីវៈចំនួន ៤០២៦នាក់( តារាងទី១១) សិក្សា៣០ក្រេឌីត(៤៥០ម៉ោង=៧៥ថ្ងៃ) ថ្លៃសិក្ខាកាមម្នាក់ (បេសកកម្ម ៣៤$ អាហារសម្រន់ ៣$ ធ្វើដំណើរ២$ ក្នុង១ថ្ងៃ) សម្ភារៈសិក្សា១០$/វគ្គ/៥វគ្គ។ សរុបថ្លៃចំណាយបេសកកម្ម អាហារសម្រន់ និងធ្វើដំណើ ៤០២៦នាក់ x៣៩$ = ១៥៧០១៤$/១ថ្ងៃ x ៧៥ថ្ងៃ= ១១.៧៧៦.០៥០$ សម្ភារៈសិក្សា ៤០២៦នាក់x១០$x៥វគ្គ= ២០១.៣០០$ សរុបថ្លៃចំណាយ **១១៩៧៧៣៥០$**

[69] សិក្ខាកាមកម្រិតកម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១ ចំនួន ៤០៦នាក់( តារាងទី១១)សិក្សា ៣០ក្រេឌីត (៤៥០ម៉ោង=៧៥ថ្ងៃ) ថ្លៃសិក្ខាកាមម្នាក់(បេសកកម្ម៣៤$ អាហារសម្រន់៣$ ធ្វើដំណើរ២$ ក្នុង១ថ្ងៃ) សម្ភារៈសិក្សា១០$/វគ្គ/៥វគ្គ។ សរុបថ្លៃចំណាយបេសកកម្ម អាហារសម្រន់ និងធ្វើដំណើរ ៤០៦នាក់ x៣៩$ =១៥៨៣៤$/១ថ្ងៃ x ៧៥ថ្ងៃ=១១៨៧៥៥០$ សម្ភារៈសិក្សា ៤០៦នាក់x១០$x៥វគ្គ=២០៣០០$ សរុបថ្លៃចំណាយ **១២០៧៨៥០$**

[70] សិក្ខាកាមកម្រិតកម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ២ ចំនួន ៤៧១នាក់( តារាងទី១១)សិក្សា ៣០ក្រេឌីត (៤៥០ម៉ោង=៧៥ថ្ងៃ) ថ្លៃសិក្ខាកាមម្នាក់(បេសកកម្ម៣៤$ អាហារសម្រន់៣$ ធ្វើដំណើរ២$ ក្នុង១ថ្ងៃ) សម្ភារៈសិក្សា១០$/វគ្គ/៥វគ្គ។ សរុបថ្លៃចំណាយបេសកកម្ម អាហារសម្រន់ និងធ្វើដំណើរ ៤៧១នាក់ x៣៩$ =$/១ថ្ងៃ x ៧៥ថ្ងៃ=១.៣៧៧.៦៧៥$ សម្ភារៈសិក្សា ៤៧១នាក់x១០$x៥វគ្គ=២៣.៥៥០$ សរុបថ្លៃចំណាយ **១៤០១២២៥$**

[71] សិក្ខាកាមកម្រិតកម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ៣ ចំនួន ៥០០ នាក់( តារាងទី១១)សិក្សា ៣០ក្រេឌីត (៤៥០ម៉ោង=៧៥ថ្ងៃ) ថ្លៃសិក្ខាកាមម្នាក់(បេសកកម្ម៣៤$ អាហារសម្រន់៣$ ធ្វើដំណើរ២$ ក្នុង១ថ្ងៃ) សម្ភារៈសិក្សា១០$/វគ្គ/៥វគ្គ។ សរុបថ្លៃចំណាយបេសកកម្ម អាហារសម្រន់ និងធ្វើដំណើរ ៥០០នាក់ x៣៩$ =$/១ថ្ងៃ x ៧៥ថ្ងៃ=១.៤៦២.៥០០$ សម្ភារៈសិក្សា ៥០០នាក់x១០$x៥វគ្គ=២៥០០០$ សរុបថ្លៃចំណាយ **១.៤៨៧.៥០០$**

| ល.រ | ចង្កោមសកម្មភាព | សកម្មភាព | ថវិកាចំណាយ (USD) | ពេលវេលាអនុវត្ត(ឆ្នាំ) | | | | | ស្ថាប័ន/អង្គភាពអនុវត្ត | សូចនាករលទ្ធផល |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | |
| | | ២.៣.៦ បណ្តុះបណ្តាលបុគ្គលិកសម្ព័ន្ធសង្គមកិច្ចកម្រិតវិញ្ញាបនបត្រស្តីពីកិច្ចការពារកុមារ[72] | 201295 | | x | x | x | x | NISA | |
| **សរុបថវិកាចំណាយសម្រាប់គោលដៅយុទ្ធសាស្ត្រទី២** | | | **16.386.720** | | | | | | | |

**គោលដៅយុទ្ធសាស្ត្រទី៣៖ពង្រឹងសមត្ថភាពគ្រឹះស្ថានអប់រំ បណ្តុះបណ្តាលកម្លាំងសេវាសង្គម**

| ល.រ | ចង្កោមសកម្មភាព | សកម្មភាព | ថវិកាចំណាយ (USD) | ពេលវេលាអនុវត្ត(ឆ្នាំ) | | | | | ស្ថាប័ន/អង្គភាពអនុវត្ត | សូចនាករលទ្ធផល |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | |
| ៣.១ | រៀបចំផែនទីសមត្ថភាពគ្រូបង្គោលនិងគ្រូជំនាញការងារសង្គមកិច្ចនិងកិច្ចការពារកុមារ | ៣.១.១ ពិនិត្យ និងវិភាគកម្រិតគុណវុឌ្ឍិចំណេះដឹង និងជំនាញវិជ្ជាជីវៈការងារសង្គមកិច្ចនិងកិច្ចការពារកុមាររបស់មន្ត្រីរាជការដែលតែកំពុងបំរើការនៅតាម អង្គភាពពាក់ព័ន្ធ | 5000 | x | | | | | NISA<br>TWG | (១)របាយការណ៍ស្តីពីផែនទីសមត្ថភាពគ្រូបង្គោល គ្រូជំនាញ និងធនធានរបស់គ្រឹះស្ថានអប់រំបណ្តុះបណ្តាល និងអង្គការមិនមែនរដ្ឋាភិបាលត្រូវបានរៀបចំឡើង។ |
| | | ៣.១.២ ពិនិត្យ និងវិភាគកម្រិតគុណវុឌ្ឍិចំណេះដឹង និងជំនាញវិជ្ជាជីវៈសង្គមកិច្ចនិងកិច្ចការពារកុមាររបស់មន្ត្រីអង្គការមិនមែនរដ្ឋាភិបាល | 4500 | x | | | | | NISA<br>TWG | |

[72] សិក្ខាកាមកម្រិតវិញ្ញាបនបត្រចំនួន ៣១៧នាក់ (តារាងទី១១) សិក្សា ១៥ថ្ងៃ ថ្លៃសិក្ខាកាមម្នាក់ (បេសកកម្ម ៣៤$ អាហារសម្រន់៣$ ធ្វើដំណើរ២$ ក្នុង១ថ្ងៃ) សម្ភារៈសិក្សា១០$/វគ្គ/៥វគ្គ។ សរុបថ្លៃចំណាយបេសកកម្ម អាហារសម្រន់ និងធ្វើដំណើរ ៣១៧នាក់ x៣៩$ =១២៣៦៣$/១ថ្ងៃ x ១៥ថ្ងៃ=១៨៥.៤៤៥$ សម្ភារៈសិក្សា ៣១៧នាក់x១០$x៥វគ្គ=១៥៨៥០$ សរុបថ្លៃចំណាយ **២០១២៩៥$**

| ល.រ | ចង្កោមសកម្មភាព | សកម្មភាព | ថវិកាចំណាយ (USD) | ពេលវេលាអនុវត្ត (ឆ្នាំ) | | | | | ស្ថាប័ន/អង្គភាពអនុវត្ត | សូចនាករលទ្ធផល |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | | |
| | | ៣.១.៣ ពិនិត្យ និងវិភាគអំពីគុណវុឌ្ឍិបុគ្គលិកអប់រំនៅ NISA និងគ្រឹះស្ថានអប់រំផ្សេងទៀត រួមទាំងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេសដើម្បីធានាគុណភាពបណ្តុះបណ្តាល | 3500 | x | | | | | NISA<br>TWG | |
| | | ៣.១.៤ សិក្សាអំពីធនធានថវិការបស់វិទ្យាស្ថានជាតិសង្គមកិច្ច គ្រឹះស្ថានអប់រំ និងអង្គការមិនមែនរដ្ឋាភិបាលសម្រាប់អប់រំកម្លាំងសេវាសង្គម | 4500 | x | | | | | NISA | |
| | | ៣.១.៥ រៀបចំរបាយការណ៍ស្តីពីផែនទីសមត្ថភាពគ្រូបង្គោល គ្រូជំនាញ និងធនធានគ្រឹះស្ថានអប់រំ និងអង្គភាពមិនមែនរដ្ឋាភិបាល | 12000 | | x | | | | NISA | |
| ៣.២ | ពង្រឹងសមត្ថភាពគរុកសល្យ និងចំណេះដឹងសង្គមកិច្ចដល់គ្រូជំនាញ និងគ្រូបង្គោល | ៣.២.១ រៀបចំកម្មវិធីពង្រឹងសមត្ថភាពគរុកសល្យគ្រូបង្គោល និងគ្រូជំនាញការងារសង្គមកិច្ចនៅតាមគ្រឹះស្ថានអប់រំសង្គមកិច្ចវិទ្យា | 7500 | | x | | | | NISA | (២) គ្រូបង្គោល និងគ្រូជំនាញត្រូវបានពង្រឹងសមត្ថភាពលើគរុកសល្យ ផ្នែកចំណេះដឹង និងជំនាញសង្គមកិច្ច។ |
| | | ៣.២.២ បង្កើនសមត្ថភាពផ្នែកគរុកសល្យ ចំណេះដឹង និងជំនាញការងារសង្គមកិច្ចដល់គ្រូបង្គោល និងគ្រូជំនាញ | 12000 | x | x | x | x | x | NISA | |
| | | ៣.២.៣ បណ្តុះបណ្តាលគ្រូបង្គោល និងគ្រូជំនាញលើប្រធានបទថ្មីដែលបង្កើតឡើងដោយ IASSW, IFSW និងលិខិតបទដ្ឋានគតិយុត្តដែលធ្វើបច្ចុប្បន្នភាព និងបង្កើតថ្មី | 20000 | x | x | x | x | x | NISA | |
| | | ៣.២.៤ រៀបចំកម្មវិធីផ្លាស់ប្តូរបទពិសោធន៍ការអប់រំបណ្តុះបណ្តាលកម្លាំងសេវាសង្គមជាមួយ | 65000 | x | | x | | x | NISA | |

| ល.រ | ចង្កោមសកម្មភាព | សកម្មភាព | | ថវិកាចំណាយ (USD) | ពេលវេលាអនុវត្ត(ឆ្នាំ) ១ | ២ | ៣ | ៤ | ៥ | ស្ថាប័ន/អង្គភាពអនុវត្ត | សូចនាករលទ្ធផល |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | បណ្តាប្រទេសក្នុងតំបន់ និងពិភពលោក | | | | | | | | |
| ៣.៣ | ពង្រឹងសមត្ថភាពគ្រឹះស្ថានអប់រំបណ្តុះបណ្តាលកម្លាំងសេវាសង្គមនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ | ៣.៣.១ | បង្កើតក្រុមគ្រូបង្គោល និងក្រុមគ្រូជំនាញដើម្បីទទួលបន្ទុកបណ្តុះបណ្តាលកម្លាំងសេវាសង្គមនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | 4500 | x | x | | | | NISA | (៣)គ្រឹះស្ថានអប់រំបណ្តុះបណ្តាលកម្លាំងសេវាសង្គមនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិត្រូវបានពង្រឹងសមត្ថភាព។ |
| | | ៣.៣.២ | រៀបចំយន្តការបន្ថែមក្នុងការបង្កើតសមាគមគ្រូសង្គមកិច្ចវិទ្យាដើម្បីសម្របសម្រួលជំនាញសង្គមកិច្ចវិទ្យា និងជំរុញឱ្យមានការទទួលស្គាល់វិជ្ជាជីវៈសង្គមកិច្ច | 7500 | x | x | x | | | MoSVY | |
| | | ៣.៣.៣ | បញ្ចូលកម្មវិធីបណ្តុះបណ្តាលកម្លាំងសេវាសង្គមទៅក្នុងកម្មវិធីសិក្សារបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន | 15000 | | x | x | x | x | MoSVY<br>MoI | |
| | | ៣.៣.៤ | បញ្ចូលគម្រោងចំណាយទៅក្នុងផែនការយុទ្ធសាស្រ្តថវិកា និងថវិកាកម្មវិធីដើម្បីគាំទ្រការពង្រឹងសមត្ថភាពមន្រ្តីរាជការលើជំនាញសុខុមាលភាពសង្គមនិងកិច្ចការពារកុមារ | 35000 | | x | x | x | x | MoSVY | |
| | | ៣.៣.៥ | បង្កើតប្រព័ន្ធគ្រប់ទិន្នន័យកម្លាំងសេវាសង្គម ១.បុគ្គលិកសង្គមប៉ារ៉ាវិជ្ជាជីវៈ ២.បុគ្គលិកសង្គមប៉ារ៉ាអាជីព ៣.បុគ្គលិកសម្ព័ន្ធសង្គមកិច្ច ៤.បុគ្គលិកសង្គមអាជីព | 30000 | | | | | | MoSVY | |
| | | | **សរុបថវិកាចំណាយសម្រាប់គោលដៅយុទ្ធសាស្រ្តទី៣** | **226.000** | | | | | | | |

KINGDOM OF CAMBODIA

Nation Religion King

# STRATEGIC PLAN

## FOR TRAINING THE SOCIAL SERVICE WORKFORCE

### FOCUSING ON CHILD PROTECTION

## 2021-2025

PREPARED BY

NATIONAL INSTITUTE OF SOCIAL AFFAIRS

MINISTRY OF SOCIAL AFFAIRS, VETERANS AND YOUTH REHABILIATION

2020

# PREFACE

Social work in Cambodia formally began in 1947 with the creation of its first governing body, the Ministry of Information and Social Affairs. Since then there have been many changes in the name and leadership of this Ministry, until it took its current form as the Ministry of Social Affairs, Veterans and Youth Rehabilitation. The Ministry is led by HE Vong Sauth as Minister in the Royal Government of the 6th Mandate of the National Assembly, reporting to Samdech Akka Moha Sena Padei Hun Sen, the Prime Minister of the Kingdom of Cambodia.

Over the past few decades, the social sector has undergone significant changes in Cambodia in relation to traditional donors and the provision of social services. Since the advent of The *United Nations Transitional Authority in Cambodia* (*UNTAC*), Non-Government Organization (NGO) staff have played a key role in providing social services in many areas, as Cambodia has worked to rebuild its infrastructure and capabilities.

To strengthen the capacity of civil servants and social service providers in the "Social Service Workforce", the Ministry of Social Affairs, Veterans and Youth Rehabilitation established the National Institute of Social Affairs on October 18, 2009 to educate and train associate degree and degree in area of engineering, prosthetics and orthotic and social work professionals, and conduct research on social work in response to the institution's needs. At the same time, the Ministry also cooperates with development partners and relevant NGOs to provide professional training in social work to civil servants and stakeholders.

While this training has been useful in building social service workers' capacity to perform their specific functions, it needs to be better structured as part of a long-term capacity building plan for civil servants who have responsibility for social service and social work functions. In particular, it must respond to recent changes in administrative reforms such as through sub-decrees 182, 183, 184 and sub-decree 34, as well as the recently endorsed "Guidelines on basic competencies for the social service workforce in Cambodia" and the "Cambodia National Qualifications" framework. Therefore, the Ministry, in collaboration with UNICEF and relevant institutions, has developed this strategic plan for training social service workforce in Cambodia.

The Strategic Plan for Training Social Service Workforce 2021-2025 is the first five-year plan with a focus on strengthening the capacity of social service workers to have knowledge and professional skills to provide social services to vulnerable people. To ensure efficiency, the Plan has three strategic goals, including: (1). Development of social service workforce training curriculum /education programs and training packages (2). training of social service workforces and improvement of its efficiency (3). Strengthened capacity of social service education/training institutions to achieve the vision, mission and expected outcomes of this strategic plan.

I commend the National Institute of Social Affairs, UNICEF, NGOs, educational/training institutions and other stakeholders for their efforts in developing a strategic plan for training the social services workforce. We will continue to provide additional support for the successful development of the social service workforce and strongly hope that all stakeholders will work together to implement this strategic plan responsibly.

Date 2 February 2021

Minister

**VONG SAUTH**

# CONTENTS


PREFACE ..... i
ACRONYMS ..... iv
DEFINITIONS ..... v
1. INTRODUCTION ..... 1
1.1. Background and context ..... 1
1.2. Higher level education for social service workforces ..... 2
1.2.1. Royal University of Phnom Penh ..... 2
1.2.2. National Institute of Social Affairs ..... 2
1.2.3. The Saint Paul Institute ..... 3
1.3. Technical and vocational education and training ..... 3
1.3.1. Vocational training in social work ..... 3
1.3.2. Capacity development of civil servants at the sub-national level ..... 4
1.4. Cambodia Qualifications Framework ..... 4
1.4.1. Levels of qualification ..... 5
1.4.2. Credit hours ..... 5
1.4.3. Learning outcomes ..... 7
1.5. Analysis of social service workforce and function ..... 8
1.5.1. The review of social work practice in Cambodia ..... 9
1.5.2. Guidelines on Basic Competencies for the Social Workforce ..... 9
1.5.3. Guidelines to Strengthen the Social Service Workforce ..... 10
1.5.4. ASEAN Declaration on the Promotion of Social Work ..... 12
1.6. Relationship between strategic plan and related documents ..... 13
1.7. Development of the strategic plan ..... 13
1.8. Strategic plan form ..... 14
2. MAP OF SOCIAL SERVICE INSTITUTES AND CHILD PROTECTION MECHANISMS ..... 14
2.1. Ministry of Social Affairs, Veterans and Youth Rehabilitation ..... 14
2.2. Capital/Provincial Department of Social Affairs Veterans and Youth Rehabilitation ..... 15
2.3. Office of Social Affairs and Social Welfare, municipality, district, khan ..... 15
2.4. Child protection coordination mechanisms ..... 17
2.4.1. Cambodia National Council for Children ..... 17
2.4.2. General Secretariat of Cambodia National Council for Children ..... 18
2.4.3. Working group for children ..... 18
2.4.4. Capital/Provincial Cambodia National Council for Children ..... 18
2.4.5. Capital/Provincial Women's and Children's Consultative Committee ..... 19
2.4.6. Municipal, district and khan WCCCs ..... 20
2.4.7. Commune/Sangkat Committee for Women and Children ..... 21
2.4.8. Sub-national child protection coordination mechanism ..... 26
2.4.9. Relevant committees chaired and coordinated by the ministries and institutions ..... 26
2.5. Local and foreign NGOs ..... 27
3. PROGRESS AND CHALLENGES ..... 28
3.1. Progress ..... 28
3.2. Challenges ..... 29
3.2.1. Development of programs and training packages for the social service workforce ..... 29
3.2.2. Child protection social services training ..... 29
3.2.3. Capacity building of trainers, professional teachers and educational institutions ..... 29
4. VISION, MISSION AND STRATEGIC GOALS ..... 30
4.1. Vision ..... 30
4.2. Mission ..... 30

4.3. Policy objective ........ 30
4.4. Strategy ........ 30
4.5. Strategic goals and expected outcomes ........ 33
5. INSTITUTIONAL PREPARATION FOR THE IMPLEMENTATION OF THE STRATEGIC PLAN 35
6. FINANCING MOBILIZATION STRATEGY AND BUDGET REQUIREMENTS ........ 36
6.1. Financing mobilization strategy ........ 36
6.2. Budget requirements ........ 36
7. MONITORING AND EVALUATION ........ 37
7.1. Monitoring ........ 37
7.2. Evaluation ........ 37
8. CONCLUSION ........ 37
ANNEX ........ 0

## ACRONYMS

| | |
|---|---|
